ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ កែវ ធី ស្ត្រីដែលបានសង្គ្រោះជីវិតខ្ញុំ

◆ «ខ្ញុំចង់បានយុត្តិធម៌ សម្រាប់ប្អូនស្រីខ្ញុំ»

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៧០ ខែកុម្ភៈ ឆ្នាំ២០១៤

ស្វែងរកការពិត
លេខ១៧០ ខែកុម្ភៈ ឆ្នាំ២០១៤

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ កែវ ធី ស្ត្រីដែលបានសង្គ្រោះជីវិតខ្ញុំ ........................................ ១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាព ហេង សុងហ៊ី ហៅ គា ........................................ ៣

◆ មតិសំខាន់ៗមួយចំនួនរបស់សមមិត្តលេខាមជ្ឈិម ........................................ ៩

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ពេញមួយរបបក្នុងកងចល័ត ........................................ ២០

◆ គ្រូមន្តអាគមចាម និងសម័យខ្មែរក្រហម ........................................ ២២

◆ មុំបី ៖ មូលដ្ឋានតស៊ូរំដោះខ្មែរក្រហម ........................................ ២៩

**ផ្នែកច្បាប់**

◆ ការរៀបចំសំណង ការប្រឈមរបស់ដើមបណ្តឹង ........................................ ៣៣

◆ ការអនុវត្តវិធាននៃភ័ស្តុតាងនៅអង្គជំនុំជម្រះ ........................................ ៤៥

**វេទិកាពិភាក្សាសាធារណៈ**

◆ ការថែរក្សាឯកសារសិទ្ធិមនុស្សជូវការនៅក្នុងរដ្ឋ ........................................ ៥០

◆ ការវិភាគស្តីពីច្បាប់បណ្ណសារដ្ឋាននៅក្នុងប្រទេសកម្ពុជា ........................................ ៥២

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ការចងចាំពីខ្មែរក្រហមស្ថិតនៅជាដរាប ........................................ ៥៤

◆ គឹម តែម ៖ អតីតកាលតែងលង ........................................ ៥៦

◆ "ខ្ញុំចង់បានយុត្តិធម៌ សម្រាប់ប្អូនស្រីខ្ញុំ" ........................................ ៥៨





អ្នកភូមិស្តាប់ការបកស្រាយរបស់សហព្រះរាជអាជ្ញា

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្មេរលេខនេះ ៖*** *រីកុ គូរ៉ូមីយ៉ា អូកាវ៉ា, លី សុខឃាង, គ្រីស៊ីន ប័រគ័រលី, លីម ជ័យទ័ត្ត, ចន ឆរឆីអារី, ចាយ៉ា រាមជី ណូហ្គាលេស, សា ហ្វាទីលី, មីន សាណាស់, ម៉ុក សិុនហៀង* ***អ្នកនិពន្ធនិងស្រាវជ្រាវ ៖*** *ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា* ***អ្នកបកប្រែ ៖*** *នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត* ***និពន្ធនាយកទូទៅ ៖*** *ឆាំង យុ និង ញាណ សុជាតិ* ***ជំនួយការនិពន្ធនាយក ៖*** *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ ៖*** *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ ៖*** *ឆេង វើង*

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# កែវ ធី (១៩៦២-២០១៤) ស្ត្រីដែលបានសង្គ្រោះជីវិតខ្ញុំ

ខ្ញុំបានមកដល់ភូមិនេះដំបូង ដែលនៅពេលនោះត្រូវបានស្គាល់ថា ជាភូមិខ្មែរលើ ឬភូមិខ្មែរដើម ស្ថិតក្នុងខេត្តតាកែវ នៅឆ្នាំ១៩៦៧-១៩៦៨ ។ ក្នុងនាមជាក្មេងម្នាក់មកពីទីក្រុងភ្នំពេញ ក្មេងៗទាំងអស់នៅក្នុងភូមិចាត់ទុករូបខ្ញុំថាជាមនុស្សពិសេស ។ កែវ ធី ក៏ជាក្មេងម្នាក់ក្នុងចំណោមនោះដែរ ហើយ ធី មានអាយុតិចជាងខ្ញុំមួយឆ្នាំ ។ ខ្ញុំបានវិលត្រឡប់មកកាន់ភូមិនេះម្តងទៀតនៅឆ្នាំ១៩៦៩ ដែលនៅក្នុងឆ្នាំនោះ ខ្ញុំគិតថា ជីតារបស់ខ្ញុំបានទទួលមរណៈភាពបាត់ទៅហើយ ។ ចាប់តាំងពីពេលនោះមក សង្គ្រាមបានធ្លាក់ចូលទៅក្នុងតំបន់នោះ ហើយខ្ញុំមិនអាចវិលត្រឡប់ចូលភូមិវិញបានទេរហូតដល់ឆ្នាំ១៩៧៥ ។

នៅពេលដែលខ្ញុំបានវិលត្រឡប់មកវិញនៅខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានធ្វើដំណើរមកភូមិនេះតែម្នាក់ឯងគត់ ។ ខ្ញុំមានអាយុ១៨ឆ្នាំ ដោយមិនស្គាល់នរណាម្នាក់សោះ ។ ខ្ញុំស្គាល់តែឈ្មោះភូមិប៉ុណ្ណោះ ។ មានតែ កែវ ធី និងបងស្រីរបស់គាត់ឈ្មោះ កែវ សុច ដែលបាននាំខ្ញុំទៅផ្ទះរបស់គាត់ មើលថែរក្សាខ្ញុំ ការពារខ្ញុំ ផ្តល់អាហារដល់ខ្ញុំ និងគិតគូដល់ខ្ញុំប្រកបដោយការគោរពបំផុត ដូចដែលមនុស្សម្នាក់ៗអាចទទួលបាន ។ គាត់ទាំងពីរមិនដែលនិយាយអ្វីទាំងអស់ ដែលប្រហែលជាគាត់ដឹងថា ខ្ញុំមានការភ័យ


កែវ សុច (រូបខាងឆ្វេង) និង កែវ ធី ថតនៅរដូវបុណ្យភ្ជុំបិណ្ឌ ឆ្នាំ២០១៣

ខ្លាចយ៉ាងណាហើយនៅពេលនោះ ។ គាត់ទាំងពីរតែងតែនៅជិតៗខ្ញុំ នៅពេលដែលខ្ញុំត្រូវការទឹក ឬអាហារ ។ ធី មិនដែលស្ទាក់ស្ទើរទេក្នុងការស្វែងរកអ្វីមួយដែលខ្ញុំត្រូវការ ។ ខ្ញុំមិនបានដឹងទេថា ធី បានប្រថុយប្រថានជីវិតក្នុងធ្វើកិច្ចការទាំងអស់នោះសម្រាប់រូបខ្ញុំ ។ នៅពេលនោះ ខ្ញុំត្រូវបានបញ្ជូនតាមរទេះភ្លើងទៅកាន់ខេត្តបាត់ដំបងដែលស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ។

ខ្ញុំបានជួបគាត់ទាំងពីរនៅក្នុងឆ្នាំ១៩៩៥ នៅពេលដែលខ្ញុំបានវិលត្រឡប់មកភូមិនេះដើម្បីមកសួរសុខទុក្ខ ឬនៅពេលណាដែលគាត់ទាំងពីរមកសួរសុខទុក្ខខ្ញុំនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅពេលយើងជួបគ្នា នោះជាការជួបប្រកបដោយក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅ ភាពញញឹម និងភាពជាបងប្អូនដែលមិនអាចរៀបរាប់បានតាមរយៈពាក្យសម្ដី ។ គាត់ទាំងពីរមិនសូវហ៊ានសុំឲ្យខ្ញុំជួយទេ បើទោះជាជីវភាពក្រីក្រយ៉ាងណាក៏ដោយ ។

កាលពីរដូវភ្ជុំបិណ្ឌឆ្នាំមុននេះក្នុងឆ្នាំ២០១៣ ខ្ញុំហាក់ដូចជាមានចិត្តមួយ ជំរុញខ្ញុំឲ្យទៅសួរសុខទុក្ខ ធី ដែលប្រហែលជាមកពីព្រះហើយមើលទៅ ។ ខ្ញុំបានទៅជួបគាត់ ហើយគាត់បាននាំខ្ញុំមើលភូមិជាលើកដំបូងបន្ទាប់ក្នុងរយៈពេល៤០ឆ្នាំ ដោយគាត់បានរៀបរាប់ប្រាប់ខ្ញុំអំពីប្រវត្តិដូនតារបស់យើង ដែលរហូតមកដល់សព្វថ្ងៃនេះ ខ្ញុំដឹងតិចតួចបំផុត ។ ធី បានបង្ហាញខ្ញុំនូវវាលស្រែដែលខ្ញុំធ្លាប់រស់នៅ និងកន្លែងដែលម្ដាយរបស់គាត់ឈ្មោះ កែវ នី ត្រូវបានបញ្ចុះក្នុងអំឡុងសង្គ្រាម ។ នៅថ្ងៃបន្ទាប់ ខ្ញុំបានធ្វើដំណើរទៅទីក្រុងឡុងដ៏ដើម្បីជួបជាមួយលោកស្រី ហ្សាហា ហាឌីដ ដែលជាវិស្វករល្បីឈ្មោះលំដាប់ពិភពលោក ។ មួយរំពេចសោះ ខ្ញុំត្រូវចាកចេញពីភូមិឋានដ៏សុខដុមមួយ ដែលខ្ញុំបានហៅថាជាស្រុកកំណើត ។

វាមិនមែនជាលើកទីមួយទេ ដែលខ្ញុំត្រូវចាកចេញពីអ្នកទាំងនោះ ក្រុមគ្រួសារ និងស្រុកកំណើត ។ តាមពិតទៅ ខ្ញុំត្រូវបែរខ្នងដាក់មិត្តភក្ដិដ៏ជិតស្និទ្ធ និងក្រុមគ្រួសាររបស់ខ្ញុំដើម្បីប្រយោជន៍ជនរងគ្រោះ ការបងប៉ាំ យុត្តិធម៌ និងការផ្សះផ្សា ។

បើទោះជាមានការងារយ៉ាងច្រើននៅចំពោះមុខក៏ដោយ ខ្ញុំមិនអាចឈប់គិតពី ធី ឡើយ ។ ខ្ញុំបានភ្ញាក់នឹកគិតថា ប្រាកដជាមានរឿងអ្វីមួយមិនល្អកើតឡើងចំពោះជីវិតរបស់គាត់ជាមិនខាន ។ ចំណែកចិត្តមួយទៀតចេះតែប្រាប់ខ្លួនឯងថាឈប់បារម្ភទៀតទៅ ។ នោះគ្រាន់តែជាសុបិន្តអាក្រក់តែប៉ុណ្ណោះ ។ ខ្ញុំមិនដឹងសោះថា វាជាគ្រាចុងក្រោយបង្អស់ ដែលខ្ញុំបានជួបគាត់ ។

ឥឡូវនេះ ធី បានចែកឋានទៅហើយ ។ ធី មានជំងឺខួចថ្លើម ដោយសារតែជីគីមីដែលគាត់បានប្រើប្រាស់ដើម្បីដាំដុះស្រូវ ។ កសិករជាច្រើននៅក្នុងប្រទេសកម្ពុជាប្រើប្រាស់ជីប្រភេទនេះដើម្បីដាំដុះស្រូវនាពេលសព្វថ្ងៃនេះ ហើយខ្ញុំមានការជឿងឆ្ងល់ថា បើសិនជា ធី មិនប្រើជីទាំងនោះទេ ម្ល៉េះសម ធី អាចមានជីវិតរស់ដល់សព្វថ្ងៃនេះបាត់ទៅហើយ ។

ឥឡូវនេះ អ្វីៗដែលខ្ញុំនៅសេសសល់នោះគឺភាពសោកស្ដាយ និងទុក្ខក្រៀមក្រំយ៉ាងជ្រាលជ្រៅ ដែលមិនបានមើលថែរក្សាគាត់ដូចដែលគាត់ធ្លាប់បានមើលថែរូបខ្ញុំ ។

មានការនិយាយជាទូទៅថា នៅគ្រាលំបាកបំផុត យើងក៏អាចរកបានមនុស្សល្អបំផុតដែរ ។ ជាការពិតនោះ ជាគ្រាលំបាកបំផុតហើយដែលអាចរកឃើញមនុស្សដែលមានបេះដូងបរិសុទ្ធបំផុត និងទឹកចិត្តសប្បុរសបំផុត ។ កែវ ធី គឺជាមនុស្សម្នាក់ក្នុងចំណោមនោះដែរ ហើយភាពសោកស្ដាយដ៏ជ្រាលជ្រៅបំផុតរបស់ខ្ញុំគឺថា ខ្ញុំលែងអាចផ្ដល់ជូនវិញនូវសេចក្ដីស្រឡាញ់ និងការថែរក្សាដែល ធី ធ្លាប់ផ្ដល់មករូបខ្ញុំ ។ ខ្ញុំសង្ឃឹមថា ធី អត់ឱនឲ្យខ្ញុំ ។ ខ្ញុំនឹងនៅជំពាក់គាត់ជារៀងរហូត ។

ដោយសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅ

**ឆាំង យុ**

# អានទស្សនាវដ្ដីតាមគេហទំព័រ

ទស្សនាវដ្ដីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm . ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

# ចម្លើយសារភាព ហេង សុងហ៊ី ហៅ គា និស្សិតមកពីបារាំង

*ដកស្រង់ចេញពីឯកសារចម្លើយសារភាព D៥៩៦៧៦*

ហេង សុងហ៊ី ហៅ គា ជានិស្សិតរៀននៅប្រទេសបារាំង ។ សុងហ៊ី បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ នៅខែធ្នូ ឆ្នាំ ១៩៧៥ គឺរយៈពេលប្រាំបីខែបន្ទាប់ពីកងទ័ពខ្មែរក្រហមទទួលជ័យជម្នះ ។ សុងហ៊ី ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៦ រួចបញ្ជូនមកឃុំឃាំង និងសួរចម្លើយនៅមន្ទីរសន្តិសុខ ស-២១ ។ សុងហ៊ី ត្រូវបានឆ្មាំគុកឈ្មោះ នៅ នី សួរចម្លើយ ចាប់ពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៦ ដែលសរុបទាំងអស់មានចំនួន១១លើក ។ ចម្លើយសារភាពរបស់ សុងហ៊ី ត្រូវបានឈ្មោះ យីវ ស្រ៊ិ វាយអង្គុលីលេខបញ្ចប់នៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៧ ។

នៅក្នុងឯកសារចម្លើយសារភាពនេះ សុងហ៊ី បានរៀបរាប់ពីសកម្មភាពរបស់គាត់ដែលប្រឆាំងជាមួយនឹងបដិវត្តន៍ ការចូលរួមជាមួយ សេ.អ៊ី.អា និងឈ្មោះអ្នកដែលពាក់ព័ន្ធនៅក្នុងសកម្មភាពក្បត់ ទាំងនៅក្នុងស្រុក និងពេលគាត់ទៅសិក្សានៅប្រទេសបារាំង ។ ប៉ុន្តែយើងមិនដឹងថា ការសារភាពរបស់គាត់ពិតឬយ៉ាងណានោះទេ ព្រោះគាត់ត្រូវឆ្លងកាត់ការវាយធ្វើទារុណកម្ម



បរិវេណនៅក្នុងមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង ក្រោយរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩

ពីអ្នកសួរចម្លើយ ។ ខាងក្រោមនេះ ជាការរៀបរាប់របស់ សុងហ៊ី ផ្ទាល់ ៖

ខ្ញុំមានអាយុ២៨ឆ្នាំ មានស្រុកកំណើតនៅឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ខ្ញុំមានឪពុកឈ្មោះ ហេង យួន និងម្តាយឈ្មោះ សំ នាង និងមានបងប្អូនបង្កើត៧នាក់ ។

នៅឆ្នាំ១៩៦៥ ខ្ញុំរៀននៅថ្នាក់ទី នៅវិទ្យាល័យត្បូងឃ្មុំ ។ នៅឆ្នាំនោះ ខ្ញុំចូលចិត្តរឿងនយោបាយ ចូលចិត្តជជែក និងចង់ដឹងចង់ឮពីរឿងនយោបាយ ។ ខ្ញុំបានដាក់ខ្លួនស្រឡាញ់សម្តេច សីហនុ យ៉ាងខ្លាំង ។ ខ្ញុំគិតឃើញថា សម្តេច សីហនុ ដែលខស្សរ៉ាហ៍និយាយតាមវិទ្យុ ធ្វើអ្វីក៏ត្រូវ និងនិយាយអ្វីក៏ត្រូវដែរ ហើយខ្ញុំមានចិត្តស្អប់ខ្មែរក្រហមតាំងពីពេលនោះមក ។ បន្ទាប់ពីមានការឃោសនាប្រឆាំងនឹងខ្មែរក្រហម ខ្ញុំនិងមិត្តភក្តិឈ្មោះ អ៊ឹម ប៊ុនហ៊ិត, ឃៃ ហោមេង និង ជាវ ឆេងហ៊ិត បានចូលរួមធ្វើបាតុកម្មជាមួយសិស្សនៅអនុវិទ្យាល័យសួង ប្រឆាំងនឹងខ្មែរក្រហម ។ ខ្ញុំបានស្រែកជេរខ្មែរក្រហម តាមខគ្សោសនាសព្ទ ព្រមទាំងធ្វើបដាជេរខ្មែរក្រហមទៀត ដោយគាំទ្រនយោបាយ សម្តេច សីហនុ ។ ស្របពេលនោះមានសាស្ត្រាចារ្យម្នាក់ឈ្មោះ គង់ នឿន (ក្រោយមកជានាយកវិទ្យាល័យព្រះស៊ីសុវត្ថិ) តែងតែនិយាយប្រាប់ខ្ញុំថា “ខ្មែរក្រហមសុទ្ធតែអ្នកក្បត់ជាតិ” ។ ដូច្នេះ នៅក្នុងការជជែកជាមួយមិត្តភក្តិ ខ្ញុំតែងតែវាយប្រហារសាស្ត្រាចារ្យ ដែលមាននិន្នាការទៅរកខ្មែរក្រហម ដូចជា ជាវ ណាត, ឌឹប ហ៊ិន និង សារឹម ។

បន្ទាប់ពីខ្ញុំប្រលងជាប់ឌីប្លូម ខ្ញុំបានមករៀននៅថ្នាក់ទី២ នៅវិទ្យាល័យកំពង់ចាម ។ ព្រមជាមួយគ្នានោះ មិត្តភក្តិបីនាក់ (អ៊ឹម ប៊ុនហ៊ិត, ឃៃ ហោមេង និង ជាវ ឆេងហ៊ិត) ក៏មករៀនជាមួយខ្ញុំដែរ ។ ខ្ញុំមិនបានធ្វើសកម្មភាពនយោបាយទេ ដោយខ្ញុំត្រូវខំរៀនដើម្បីប្រលងឆ្លងថ្នាក់ ។ ប៉ុន្តែខ្ញុំនៅតែមានគំនុំជាមួយខ្មែរក្រហមដែលហ៊ានប្រមាថមើលងាយ សម្តេច សីហនុ ។

តមកទៀត ខ្ញុំបានប្រលងជាប់បាក់អង ហើយនៅឆ្នាំនោះនៅភូមិខ្ញុំនៅត្បូងឃ្មុំ បានកើតមានព្រឹត្តិការណ៍រន្ធត់ជាច្រើន ។ ខ្ញុំបានឮដំណឹងថា ខ្មែរក្រហមលួចបាញ់អ្នកដំណើរនៅតាមផ្លូវ ។ ខ្មែរក្រហម និងវៀតកុង តែងតែលបចាប់មេឃុំ ឬអ្នកមានក្នុងភូមិយកទៅសម្លាប់ស្ទើររាល់យប់ ។ ខ្ញុំយល់ថា ខ្មែរក្រហមត្រូវរ៉ូវជាមួយយួន ហើយសម្លាប់ខ្មែរគ្នាឯង ។

ខ្ញុំតែងតែរួមធ្វើសកម្មភាពប្រឆាំងនឹងខ្មែរក្រហមជានិច្ច ហើយដោយសារខ្ញុំជាប្រធានថ្នាក់ ខ្ញុំតែងតែសួរនាំសាស្ត្រាចារ្យបារាំងពីគំនិតរបស់គាត់ចំពោះខ្មែរក្រហម ។ ដោយឡែក នៅពេលខ្ញុំទៅ ទទួលសម្តេច សីហនុ ម្តងៗ ខ្ញុំតែងតែចូលរួមធ្វើបដាទាំងយប់ទាំងថ្ងៃ ដើម្បីប្រឆាំងនឹងខ្មែរក្រហម ។ នៅពេលនោះដែរ ខ្ញុំបានទាក់ទងជាមួយ អ៊ាត ចន្ទ, ហ៊ាន វុឌ្ឍា, លី ហេង និង សំ ណុល ទៀត ។

នៅឆ្នាំ១៩៦៨ ខ្ញុំបានប្រលងជាប់បាក់ឌុប ហើយខ្ញុំបានមករៀនបន្តនៅមហាវិទ្យាល័យវិទ្យាសាស្ត្រ នៅភ្នំពេញ ។ នៅឆ្នាំដដែលនោះ ខ្មែរក្រហម និង សម្តេច សីហនុ ឈ្លោះគ្នាខ្លាំង ហើយជាឆ្នាំដែលខ្ញុំដឹងថា ខ្មែរក្រហមកំពុងធ្វើសកម្មភាពយោធាខ្លាំងនៅសំឡូត និងតំបន់ផ្សេងទៀត ។

នៅដើមឆ្នាំនោះ លន់ នល់ បានផ្តើមគំនិតឲ្យនិស្សិតទាំងអស់នៅមហាវិទ្យាល័យហាត់ហ្វឹកហ្វឺនក្បួនយោធា ចំនួនពីរសប្តាហ៍ ។ ខ្ញុំបានចូលរួមហាត់ដោយរីករាយ ។ នៅពេលចប់វគ្គ រដ្ឋាភិបាលមានធ្វើពិធីបុណ្យមួយនៅសំរោង ដោយមានការសម្តែងសិល្បៈនៅពេលយប់ ។ ឆ្លៀតពេលនោះ សម្តេច ប៉ែន នុត ជានាយករដ្ឋមន្ត្រី និង លន់ នល់ ជាឧបនាយករដ្ឋមន្ត្រី ក៏បានទៅចូលរួមពិធីនោះដែរ ហើយបានឆ្លៀតឱកាសធ្វើការឃោសនាប្រឆាំងនឹងខ្មែរក្រហម ដោយបានគាំទ្រ សម្តេច សីហនុ ។ ខ្ញុំពេញចិត្តនឹងសកម្មភាពនេះយ៉ាងខ្លាំង ។

ប៉ុន្មានថ្ងៃក្រោយមក ពេលត្រឡប់មកភ្នំពេញ មានបាតុកម្មមួយនៅមុខវាំងសុំឲ្យ សម្តេច សីហនុ នៅកាន់ដំណែងដដែល ។ នៅពេលនោះ ខ្ញុំមានគំនិតថា នឹងខិតខំរៀនសូត្រឲ្យបានសញ្ញាប័ត្រខ្ពស់ ធ្វើការមានបុណ្យសក្តិធំ មាននាទី មានមុខមាត់ និងមានលទ្ធភាពធ្វើនយោបាយដើម្បីប្រឆាំង ចេញមុខទល់នឹងនយោបាយរបស់ខ្មែរក្រហម ។

នៅក្នុងឆ្នាំ១៩៦៨ដដែល ខ្ញុំមានការប្រែប្រួលខ្លះក្នុងការប្រកាន់តវិយាបថនយោបាយចំពោះ សម្តេច សីហនុ ព្រោះខ្ញុំឃើញជាក់ស្តែងថា សម្តេច សីហនុ ត្រូវរ៉ូវជាមួយយៀកកុង ។ ខ្ញុំឃើញអំពើពុករលួយ ឃើញវិបត្តិគណៈរដ្ឋមន្ត្រីជាបន្តបន្ទាប់ ។ ផ្ទុយទៅ

វិញ ខ្ញុំឃើញ លន់ នល់ ដែលជានាយករដ្ឋមន្ត្រី បានខិតខំខ្នះខ្នែងដោះស្រាយបញ្ហាជាតិ ក្តាប់សភាពការណ៍ក្នុងប្រទេសបាន ។ ខ្ញុំមានការកក់ក្តៅ ពេញចិត្ត និងទុកចិត្តរដ្ឋាភិបាលនោះថា ជារដ្ឋាភិបាលមួយល្អ និងមានសមត្ថភាព ។

ខ្ញុំបានជជែកជាមួយសាស្ត្រាចារ្យ ឡុង បុត្តា, ឃឹះ ជៀវ, ស៊ូ ឃឹម និង តាន់ ប៊ុនស៊ួរ ពីរឿងនេះ ហើយក៏បានចុះសម្រុងគ្នាគាំទ្ររដ្ឋាភិបាលស្រោចស្រង់ជាតិ ។ ខ្ញុំបានធ្វើសកម្មភាពញឹកញាប់ជាមួយសមាគមនិស្សិតនៅភ្នំពេញដើម្បីគាំទ្ររដ្ឋាភិបាលនេះ ។

នៅឆ្នាំ១៩៧០ ខ្ញុំរៀននៅថ្នាក់ទី៣ (ឆ្នាំទី៣) នៃមហាវិទ្យាល័យវិទ្យាសាស្ត្រ ហើយនៅមុន ពេលរដ្ឋប្រហារ ថ្ងៃ១៨ ខែមីនា ខ្ញុំបានចូលរួមយ៉ាងសកម្មក្នុងបាតុកម្មប្រឆាំងនឹងយៀកកុងដែលមកបោះទីតាំងនៅតាមបណ្តោយព្រំដែនលើទឹកដីខ្មែរ ។ នៅថ្ងៃទី១៨ ខែមីនា ជាថ្ងៃដែលធ្វើឲ្យខ្ញុំរីករាយ ជាថ្ងៃដែលប្រទេសយើងអាចដោះស្រាយបញ្ហាយៀកកុងដោយចំហ និងដោយវិធីក្តៅ ហើយខ្មែរក្រហម ក៏ជាបញ្ហាមួយដែលនឹងអាចដោះស្រាយជាមួយបញ្ហាយៀកកុង ។

ខ្ញុំបានចូលរួមយ៉ាងសកម្មក្នុងបាតុកម្មគាំទ្ររដ្ឋប្រហារ គាំទ្រ លន់ នល់, សិរិ មតៈ និង អ៊ិន តាំ ។ នៅក្នុងមិទ្ទីញ និងនៅតាមសកលវិទ្យាល័យ ខ្ញុំតែងតែឡើងធ្វើការចាប់អារម្មណ៍ និងពេញចិត្តនឹងរដ្ឋប្រហារនោះជានិច្ច ។

នៅខែមេសា ឆ្នាំ១៩៧០ ខ្ញុំសម្រេចចូលជាសមាជិក សេ.អ៊ី.អា ។ កាលនោះ ឡុង បុត្តា ជាមេ សេ.អ៊ី.អា នៅភ្នំពេញ ទទួលបន្ទុកប្រមូលនិស្សិតឲ្យចូល សេ.អ៊ី.អា ។ ចូលដំបូង ខ្ញុំពុំទាន់ធ្វើសកម្មភាពអ្វីសំខាន់ទេ ហើយអង្គការឲ្យខ្ញុំ៥.០០០រៀលក្នុងមួយខែ ។ ក្រៅពីទៅរៀននៅមហាវិទ្យាល័យ ខ្ញុំក៏បានទទួលការអប់រំនយោបាយបន្ថែមពីអង្គការ សេ.អ៊ី.អា ។

ខ្ញុំបានទៅចូលរួមក្នុងបាតុកម្មនេះដែរ ដោយអត់ងងុយច្រើនថ្ងៃ ច្រើនយប់ ដើម្បីធ្វើបដាគាំទ្រការប្រកាសសាធារណរដ្ឋនៅខែវិច្ឆិកា ឆ្នាំ១៩៧០ និងធ្វើបណ្ណចែកផ្សាយ ដល់និស្សិតទាំងអស់ឲ្យយល់ និងឲ្យចូលរួមឲ្យបានច្រើន ។

នៅពេលនោះ ខ្ញុំរៀននៅឆ្នាំទី៤ នៅមហាវិទ្យាល័យវិទ្យាសាស្ត្រ និងជាសិស្សសាលាគរុវិជ្ជាជាន់ខ្ពស់ ។ ខ្ញុំរួមជាមួយមិត្តភក្តិ ប៊ូ នឹម និង ប៉ែន ម៉ានីល បានទទួលការណែនាំឲ្យរៀបចំដឹកនាំ និងធ្វើសកម្មភាពនយោបាយ នៅក្នុងសមាគមសិស្សសាលាគរុវិជ្ជាជាន់ខ្ពស់ ។

ខ្ញុំបានរួមធ្វើញត្តិប្រឆាំងនឹងការផ្លោងគ្រាប់បែករបស់ខ្មែរក្រហម មកលើប្រជាជននៅភ្នំពេញ ដោយថ្កោលទោសថាខ្មែរក្រហមជាពួកព្រៃសម្លាប់តែប្រជាជន ។ ខ្ញុំក៏បានសរសេរក្នុងទស្សនាវដ្តីរបស់សមាគម ដោយទម្លាក់កំហុសលើខ្មែរក្រហមថាជាពួកស៊ីសាច់ ហុតឈាម ខុះមនុស្សធម៌ កាប់សម្លាប់ឥតអាណិតអាសូរ និងហ៊ានប្រើប្រាស់គ្រប់មធ្យោបាយដើម្បីខ្លួនឡើងកាន់អំណាច ។

ក្រៅពីនោះ ខ្ញុំស៊ើបយកការណ៍ពីនិស្សិតណាដែលមាននិន្នាការ ទៅរកខ្មែរក្រហមមាន យុន ស៊្រុន, ស៊ុន ដារា និង ទេព ស៊ុនជា និស្សិតនៅមហាវិទ្យាល័យអក្សរសាស្ត្រ ។ ខ្ញុំបានយកព័ត៌មានទាំងនោះទៅឲ្យ ឡុង បុត្តា ។ ក្រោយមក ខ្ញុំបានឮមិត្តភក្តិខ្ញុំឈ្មោះ យ៉ៃ ហោម៉េង ជាអធិការប៉ូលីស ពិសេសនៅភ្នំពេញ ប្រាប់ខ្ញុំថា អ្នកទាំងនេះត្រូវបានចាប់ខ្លួន ហើយយកទៅឃុំឃាំង និងវាយធ្វើបាបនៅក្រសួងកិញ ។ ទន្ទឹមនឹងនោះ មានសាស្ត្រាចារ្យមួយចំនួនដូចជា សុខ ឃី, លឹម នា, វ៉ាន់ស ក៏ត្រូវបានចាប់ខ្លួនដោយសារខ្ញុំឲ្យព័ត៌មានដែរ ។

នៅឆ្នាំ១៩៧២ ជាឆ្នាំដែលត្រូវបោះឆ្នោតជ្រើសរើសប្រធានាធិបតី ។ ខ្ញុំជាសមាជិកក្នុង គណបក្សសង្គមសាធារណរដ្ឋរបស់ លន់ នល់ និងជាអនុប្រធានទីពីរនៅសាលាគរុវិជ្ជាជាន់ខ្ពស់ បានចេញមុខយ៉ាងសកម្មដើម្បីគាំទ្របេក្ខភាពរបស់ លន់ នល់ ។ កាលនោះអង្គការ សេ.អ៊ី.អា ឲ្យខ្ញុំ១០.០០០រៀល ក្នុងមួយខែ ។ ខ្ញុំបានទៅប្រជុំជាច្រើនដងនៅការិយាល័យរបស់គណបក្ស មាន ឡុង បុត្តា ជាអ្នកដឹកនាំ ដើម្បីជជែកពីគម្រោងគាំទ្របេក្ខភាព លន់ នល់ ធ្វើយ៉ាងណាកុំឲ្យ អ៊ិន តាំ ទទួលសំឡេងច្រើន ។

កាលនោះខ្ញុំបានទទួលភារកិច្ចឲ្យមកស៊ើបការណ៍ពីសកម្មភាពរបស់គណបក្សប្រជាធិបតេយ្យគាំទ្រ អ៊ិន តាំ ។ ខ្ញុំបានបន្លំខ្លួនថាខ្ញុំចេញពីគណបក្សសង្គមសាធារណរដ្ឋ ដោយសារទំនាស់បុគ្គល ។ ខ្ញុំបានធ្វើការទាក់ទងយ៉ាងជិតស្និទ្ធជាមួយសមាជិកគណបក្សប្រជាធិបតេយ្យ រហូតដល់បក្សនេះបំរុងឲ្យខ្ញុំឈរឈ្មោះធ្វើជា

តំណាងរាស្ត្រ តែខ្ញុំពុំទាន់គ្រប់អាយុ ។ ខ្ញុំស៊ើបបានព័ត៌មានពីទំនាស់នៅក្នុងគណបក្ស ជាពិសេសពីទំនាស់របស់ អ៊ិន តាំ ជាមួយសមាជិកគណបក្ស ។ ភារកិច្ចនេះខ្ញុំបានទទួលបំពេញរហូតដល់ពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ។

ចំណែកសកម្មភាពប្រឆាំងនឹងខ្មែរក្រហម ខ្ញុំនៅតែបំពេញធម្មតារហូតដល់ដំណាច់ឆ្នាំ១៩៧២ ទើបខ្ញុំទៅប្រទេសបារាំង ដោយរដ្ឋាភិបាលសាធារណរដ្ឋផ្តល់អាហារូបករណ៍ឲ្យខ្ញុំចំនួន ៧៥០ហ្វ្រង់ ក្នុងមួយខែ ។

នៅឆ្នាំ១៩៧៣ ខ្ញុំបានទទួលការណែនាំឲ្យទាក់ទងជាមួយ នឹង ផាន់ មួយហាក់ នៅប្រទេសបារាំងដែលជាអ្នកទទួលខុសត្រូវនិស្សិត ហើយជា សេ.អ៊ី.អា ធ្វើការនៅស្ថានទូតខ្មែរ ។ ពេលទៅដល់ប្រទេសបារាំងភ្លាម ផាន់ មួយហាក់ បានណែនាំខ្ញុំឲ្យទៅនៅខេត្តណង់ស៊ី ដែលមានខ្មែរច្រើន ហើយភាគច្រើនសុទ្ធតែជាអ្នកមាននិន្នាការគាំទ្ររបបសាធារណរដ្ឋ ។ នៅណង់ស៊ី មានសមាគមឈ្មោះសមាគមនិស្សិតខ្មែរនៅណង់ស៊ី ។ ខ្ញុំត្រូវបានណែនាំឲ្យចូលជាសមាជិកធម្មតា ប៉ុន្តែខ្ញុំពុំមានធ្វើសកម្មភាពអ្វីទេ ព្រោះជាឆ្នាំដំបូងដែលខ្ញុំមកនៅស្រុកគេ ។

មកដល់ឆ្នាំ១៩៧៤ ខ្ញុំទទួលបានប្រាក់១.៥០០ហ្វ្រង់ ក្នុងមួយខែ ។ ខ្ញុំក៏ត្រូវបានជ្រើសរើសឲ្យធ្វើជាអគ្គលេខាធិការនៃសមាគមនិស្សិតនៅណង់ស៊ី ទទួលបន្ទុកពីប្រធានឈ្មោះ ជ័យ សឿន ។ នៅក្នុងការបំពេញសកម្មភាពនយោបាយក្នុងក្របខណ្ឌសមាគមក្តី ក្នុងក្របខណ្ឌ សេ.អ៊ី.អា ក្តី ខ្ញុំទាក់ទងជិតស្និទ្ធជាមួយ សារីស៊ីផាន់គីផាត់, មៀចសួន, ហូដែរ៉ត់, លាងលីមហេង និង កើតសាវ៉ាត ។ នៅឆ្នាំនោះ ខ្ញុំបានធ្វើសកម្មភាពប្រឆាំងជាមួយនឹងសមាជិករណសិរ្សរួបរួមជាតិកម្ពុជានៅប្រទេសបារាំង គឺបំផុសឲ្យខ្មែរទាំងអស់នៅណង់ស៊ីរួមសាមគ្គីគ្នា កុំបណ្តោយឲ្យសមាជិករណសិរ្សមកឃោសនាឲ្យចូលបដិវត្តន៍ ។ ខ្ញុំបានសរសេរថ្កោលទោសខ្មែរក្រហមដែលបណ្តោយឲ្យប្រទេសធ្លាក់នៅក្នុងមហន្តរាយនៅក្នុងទស្សនាវដ្តីសមាគម ដែលមាន សារីស៊ីផាន់ គីផាត់ ជាចាងហ្វាង ។ ខ្ញុំបានរៀបចំជាសិល្បៈដោយ មានឆាករៀបជាក្បាច់បូរាណឲ្យបរទេសមើលឲ្យចូលចិត្តខ្មែរ (ចូលចិត្តសាធារណរដ្ឋ) ដោយមានដាក់ទង់ជាតិពាសពេញកន្លែងសិល្បៈ ។

នៅក្នុងពេលខ្ញុំជួបសមាជិករណសិរ្ស ដែលជាខ្មែរក្រហមនៅបារាំងឈ្មោះ វណ្ណា និង ភុត ខ្ញុំបានប្រឆាំង និងពេបជ្រាយអ្នកទាំងនោះថា សុទ្ធតែជាកូនចៅ ហូជីមិញ ឬកូនចៅ ម៉ៅ សេទុង ។ នៅពេលខ្ញុំឮថា គ្រាប់បែកផ្លោងចូលភ្នំពេញម្តងៗ ខ្ញុំតែងស្ទុះស្ទាកោះប្រជុំសមាជិកសមាគមដើម្បីធ្វើញត្តិថ្កោលទោសខ្មែរក្រហម រួចនាំគ្នាអង្គាសលុយដើម្បីផ្តល់ជាជំនួយមនុស្សធម៌តាមរយៈទូតខ្មែរនៅប៉ារីសមកឲ្យអ្នករងគ្រោះនៅភ្នំពេញ ។ ខ្ញុំបានធ្វើញត្តិចុះហត្ថលេខា ផ្ញើទៅអង្គការសហប្រជាជាតិដើម្បីសុំឲ្យមានការចរចាគ្នារវាងខ្មែរក្រហម និងសាធារណរដ្ឋដើម្បីបញ្ចប់សង្គ្រាម ។

នៅក្នុងខែសីហា ឆ្នាំ១៩៧៤ ខ្ញុំត្រូវបានសាលាអនុញ្ញាតឲ្យទៅបំពេញកម្មសិក្សានៅប្រទេសកាណាដា ។ ខ្ញុំបានទៅជួបខ្មែរមួយចំនួន មានឈ្មោះ លី ប៊ុណ្ណៈ, ជិន ឌី, សិទ្ធី, សុធា និង ប៉េង ស្រ៊ុន ដែលមាននិន្នាការនយោបាយដូចខ្ញុំ ។ ខ្ញុំបានឆ្លៀតពេលនោះធ្វើការផ្សាយពីអំពើព្រៃផ្សៃរបស់ខ្មែរក្រហមមកលើប្រជាជនស្លូតត្រង់នៅភ្នំពេញ ។ ខ្ញុំបានផ្សាយបំភាន់ថា សិស្សនៅក្នុងប្រទេសមានការបែកបាក់រវាង អៀង សារី និង ខៀវ សំផន ហើយថារណសិរ្សនៅប្រទេសបារាំងក៏ដូច្នេះដែរ ។

នៅឆ្នាំ១៩៧៥ ខ្ញុំបានទទួលការណែនាំឲ្យធ្វើជាប្រធាននិស្សិតនៅណង់ស៊ី ហើយបានជាប់ជា ប្រធានសមាគមនេះនៅដើមឆ្នាំនោះ ។ ជាមួយស្ថានទូត ខ្ញុំបានទាក់ទងជិតស្និទ្ធជាមួយ កេង វ៉ាន់សាក់ ជំនួស ផាន់ មួយហាក់ ដែលវិលមកប្រទេសវិញជាមួយ ដុង ម៉ានយ៉ា, ហុង ហឿងឡឿង (ឯកអគ្គរដ្ឋទូតនៅអេស្ប៉ាញ) ។ ពេលនោះ ខ្ញុំមិនបានធ្វើសកម្មភាពអ្វីក្រៅតែពីសម្តែងសិល្បៈ និងប្រឆាំងតាមទស្សនាវដ្តី តាមការប្រជុំទល់នឹងខ្មែរក្រហមដូចកាលខ្ញុំធ្វើពីឆ្នាំមុនទេ ព្រោះខ្ញុំឃើញសភាពការណ៍នៅក្នុងប្រទេសហាក់ដូចជាអនុគ្រោះឲ្យខ្មែរក្រហមច្រើនឡើងៗ ។ ម្យ៉ាងទៀត កេង វ៉ាន់សាក់ បានណែនាំខ្ញុំឲ្យបោះបង់ដំណែងជាប្រធានសមាគមនេះឲ្យទាន់ពេលវេលាដើម្បីទុកលទ្ធភាព ធ្វើសកម្មភាពប្រឆាំងខ្មែរក្រហម និងកុម្មុយនីស្ត ។ សមាគមនិស្សិតនៅណង់ស៊ីនេះ មានសមាជិកជាង១០០នាក់ ហើយជាសមាគមខ្លាំងជាងគេនៅក្នុងប្រទេសបារាំង ក្នុងការធ្វើសកម្មភាពនយោបាយប្រឆាំងនឹងខ្មែរក្រហម ហើយគាំទ្ររបបសាធារណរដ្ឋខ្មែរ ។

នៅពេលដែលខ្ញុំលាលែងពីដំណែងនេះ បានធ្វើឲ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅក្នុងមជ្ឈដ្ឋាននិស្សិតក្នុងសមាគម ។ ខ្ញុំបានទទួលការណែនាំឲ្យធ្វើយ៉ាងណាដើម្បីបំភាន់មតិមហាជនឲ្យឃើញថាខ្ញុំមាន ការផ្លាស់ប្តូរនិន្នាការនយោបាយ គឺងាកពីសាធារណរដ្ឋមកខ្មែរក្រហមវិញ ។ ខ្ញុំបានថ្កោលទោសអ្នក និយមសាធារណរដ្ឋខ្លះដែលពុករលួយ មានឈ្មោះ ជាវ ស៊ាងលាន និង ផុង ម៉ានយ៉ា ។

ក្រោយពីលាឈប់ពីប្រធានសមាគម ខ្ញុំផ្អាកសកម្មភាពនយោបាយជាចំហ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ក្នុងរយៈពេលនោះ ខ្ញុំមិនដែលនិយាយអ្វីប្រឆាំងនឹងខ្មែរក្រហមទេ ។ ប៉ុន្តែជាទស្សនៈ ជាគោលជំហរ ខ្ញុំនៅតែមានគំនិតប្រឆាំងនឹងលទ្ធិកុម្មុយនីស្ត ។

នៅក្រោយថ្ងៃជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ អ៊ិន សុការ ដែលជាប្រធានរណសិរ្សរួបរួមជាតិ នៅប្រទេសបារាំង បានធ្វើការឃោសនាពីជ័យជម្នះ នៅខេត្តណង់ស៊ី ។ នៅពេលនោះ ដោយមិនអាចលាក់កំហឹងបាន ខ្ញុំបានធ្វើឲ្យលេចចេញជាអាកប្បកិរិយាពេបជ្រាយ ដល់ពាក្យបដិវត្តន៍ ដែលខ្ញុំមិនធ្លាប់ឮដូចជាពាក្យ មហាអស្ចារ្យ ឯករាជ្យម្ចាស់ការ មិត្ត និង មហាលោតផ្លោះ ជាដើម ។

នៅខែឧសភា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបាន កេង វ៉ាន់សាក់ កោះហៅឲ្យទៅជួបដើម្បីធ្វើការណែនាំ ឲ្យរៀបចំខ្លួនវិលត្រឡប់មកប្រទេស និងបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍ ។ ខ្ញុំបានទទួលបញ្ជាឲ្យមកបំពេញភារកិច្ចមួយចំនួនក្នុងប្រទេសដើម្បីវាយប្រហារបដិវត្តន៍ប្រឆាំងនឹងលទ្ធិកុម្មុយនីស្ត ។ ពេលនោះ ខ្ញុំបានជួប កេង វ៉ាន់សាក់ លើកទីមួយ ជាមួយ មៀច សួន និង សារីស៊ីផាន់ គឺជាត់ ដែលមានភារកិច្ចមកប្រទេសមុន ហើយរហូតដល់ដាច់ខែឧសភា ឆ្នាំ១៩៧៥ ទើបខ្ញុំមានបញ្ជាឲ្យទៅជួប ម្តងទៀត ។ លើកទីពីរនេះមានមិត្ត ជ័យ សួន, ហូ ដែរ៉ត, កើត សារ៉ាត, លាង លឹមហេង មកចូលរួមថែមទៀត ។ មិត្តទាំងបួននាក់នេះត្រូវវិលមកប្រទេសវិញ នៅដើមឆ្នាំ១៩៧៨ ។

មកដល់ខែសីហា ឆ្នាំ១៩៧៥ ទើបខ្ញុំបានធ្វើពាក្យសុំទៅបេសកកម្មនៃរាជរដ្ឋាភិបាលកម្ពុជា នៅទីក្រុងប៉ារីស ដើម្បីវិលត្រឡប់មកក្នុងប្រទេសវិញឲ្យបានឆាប់ក្នុងគោលបំណងមកបម្រើប្រទេស និងបម្រើបដិវត្តន៍ ។ ខ្ញុំបានអនុញ្ញាតឲ្យវិលត្រឡប់មកមាតុភូមិវិញ នៅថ្ងៃ១៧ ខែធ្នូ ឆ្នាំ១៩៧៥ ។

ពេលមកដល់ពោធិ៍ចិនតុងភ្លាម ខ្ញុំមានការស្ទុតចិត្តពន់ពេកព្រោះឃើញសភាពស្ងាត់ប្លែក នៅចំណតយន្តហោះ ។ នៅតាមផ្លូវចូលមកភ្នំពេញ ខ្ញុំមានការក្រៀមក្រំចិត្តយ៉ាងខ្លាំងដោយនឹកគិតទៅដល់ប្រជាជននៅភ្នំពេញដែលត្រូវបានជម្លៀសចេញ ។ អង្គការបាននាំខ្ញុំមកនៅអគារមួយជាផ្ទះរបស់សាស្ត្រាចារ្យ សូវៀតអស់រយៈពេលជិត៥ខែ ។

នៅក្នុងពេលធ្វើប្រវត្តិរូប ខ្ញុំបានបន្លំ ភូតភរច្រើនពីអត្តចរិតវណ្ណៈភាព គុណវិបត្តិ និងគុណ សម្បត្តិ ផ្ទាល់ខ្លួន ។ ខ្ញុំបានបំពេញដោយចង់បំភាន់អង្គការឲ្យឃើញថា ខ្ញុំជាអ្នកបដិវត្តន៍មួយរូបដែរ ។ នៅក្នុងការឆ្លើយសំណួរពាក់ព័ន្ធក្នុងជីវទស្សន៍ ទោះបីអង្គការមានការណែនាំឲ្យធ្វើតាមរបៀបដែលត្រូវធ្វើយ៉ាងណា ក៏ខ្ញុំបានប្រកាន់អាកប្បកិរិយារឹងរូស បែរទៅនិយាយពីទ្រឹស្តីទៅវិញ ។ ខ្ញុំមិនហ៊ាននិយាយការពិត បារម្ភក្រែងអង្គការស្គាល់ទស្សនៈ និងឧត្តមគតិរបស់ខ្ញុំច្បាស់ ។

នៅខណៈនោះដែរ ខ្ញុំធ្វើដូចជាមិនទម្លាក់កំហុសចំពោះអាមេរិកាំងទេក្នុងសង្គ្រាមប្រាំឆ្នាំនោះ បែរទៅនិយាយពីបារាំងទៅវិញ ។ ខ្ញុំមិនចង់ថ្កោលទោស លន់ នល់ ទេ ។ ជារួមជីវទស្សន៍ដែលខ្ញុំបំពេញកាល លើកទីមួយនេះ មានលក្ខណៈមិនពិតច្រើន ភូតភរច្រើន ហើយដោយមិនអាចទប់កំហឹង បានខ្ញុំបានធ្វើឲ្យចេញជាពាក្យសម្តី អាកប្បកិរិយាវាយប្រហារអង្គការបដិវត្តន៍ខ្លះ ។

នៅក្នុងការទាក់ទងជាមួយមិត្តភក្តិ ខ្ញុំនៅតែមានគំនុំជាមួយសមាជិករណសិរ្សដែលត្រឡប់មកជាមួយគ្នា ហើយខ្ញុំសេពគប់តែមិត្តណាដែលមិនមែនជាខ្មែរក្រហម ។ នៅក្នុងការជជែកគ្នាខ្ញុំបានវាយប្រហារអង្គការច្រើនចោទអង្គការថា ជិះជាន់ ធ្វើបាបយកអង្ករលាយចេកឲ្យហូប សម្ងសាប អត់សាច់រាល់ពេល ហូបបបរព្រឹកល្ងាច ធ្វើឲ្យស្គីក ឥតកម្លាំង ។ ប៉ុន្តែជារូបភាព ខ្ញុំបានខិតខំធ្វើការយ៉ាងសកម្មដើម្បីឲ្យអង្គការទុកចិត្ត ដើម្បីខ្ញុំឆាប់បានចេញពីមន្ទីរនេះទៅជនបទ ។

នៅទីនោះ ខ្ញុំបានលួចធ្វើការជាសម្ងាត់ជាមួយ ប៊ុន ចន្ទសេរី សេ.អ៊ី.អា មកពីបារាំង (ស្នាក់នៅអគារជាមួយគ្នា) ដើម្បីរំពុកពី

ផែនការដែលបានទទួល ។ ប៉ុន្តែខ្ញុំមិនបានទាក់ទងជាមួយ សេ.អ៊ី.អា ដែលជានាយទាហានដូចជា តុល, ខុក ជី, សុខា, តាន់ ឈុនម៉េង និង ដាញ់ ទេ ដើម្បីកុំឲ្យអង្គការចាប់អារម្មណ៍ ។ ផ្ទុយទៅវិញ នៅពេលប្រជុំស្វ័យទិតៀនម្ដងៗ ខ្ញុំតែងតែធ្វើការទិតៀនយ៉ាងខ្លាំងដល់អ្នកទាំងនេះ ដើម្បីបង្ហាញឲ្យឃើញថា យើងមិនស៊ីមគ្រលំនឹងគ្នា ។

ក្រោយមក អង្គការបានចាត់តាំងខ្ញុំឲ្យទៅនៅឯតាលៃ រយៈពេលមួយខែ ។ នៅទីនោះ ខ្ញុំបានធ្វើការបំផុសមិត្តដែលមិនមែនជាសមាជិករណសិរ្ស មានឈ្មោះ គឹម វ៉ាទ្រី, វ៉ាន់ ហាន, ឌិក យង់ជាតិ, ចាំង សេងណុង, ណុប សារុំ, ឈូក សាគុន និង វង់ ម៉ុងស្រេង មិនឲ្យពេញចិត្តនឹងការចាត់តាំងរបស់អង្គការ ។

ខ្ញុំបានវាយប្រហារអង្គការថា កៀបសង្កត់ តឹងរ៉ឹង ធ្វើអ្វីបន្តិចបន្តួច ក៏ចោទប្រកាន់ថា សេរី ។ អង្គការបំបិទសិទ្ធិ មិនឲ្យមានសេរីភាពបន្តិចសោះឡើយ ។ គំនុំកំហឹងរបស់ខ្ញុំចំពោះលទ្ធិកុម្មុយនីស្តនៅតែមានដដែល ។

នៅពេលនោះ មានមិត្តយើងដែលមកពីបារាំងក្រោយខ្ញុំ បានប្រាប់ខ្ញុំថា នៅប្រទេសបារាំង មានកាសែតផ្សាយថា អង្គការបានចាប់បញ្ញាជនជាច្រើនពាន់នាក់ទៅសម្លាប់ ។ ដំណឹងនេះបានធ្វើឲ្យខ្ញុំគិតច្រើន ហើយក៏មានជំនឿថា ដំណឹងនេះជាដំណឹងពិត ឈរលើការតឹងរ៉ឹងរបស់អង្គការមកលើបញ្ញាជនដែលវិលមករស់នៅក្នុងមាតុភូមិសព្វថ្ងៃ ។

ក្រោយមក អង្គការចាត់តាំងខ្ញុំឲ្យទៅនៅឯព្រៃកប្បាស ។ នៅទីនោះ ខ្ញុំតែងប្រកាន់បក្សពួក ហើយនៅតែមានការពិបាកក្នុងការទាក់ទងជាមួយមិត្តជាអតីតសមាជិករណសិរ្ស នៅប្រទេសបារាំង ។ មិនតែប៉ុណ្ណោះ ខ្ញុំតែងបានបង្កើតរឿងធ្វើឲ្យកើតជាទំនាស់ជាពិសេសគ្រួសារ ដើម្បីធ្វើឲ្យបរិយាកាសរស់នៅក្នុងមន្ទីរមានសភាពមិនល្អ ។

ខ្ញុំបានញុះញង់មិត្ត យ៉ា ខុន, ឌិក យង់ជាតិ, វង់ ម៉ុងស្រេង, ចាំង សេងណុង, មៀច សួន, សារ៉េត មិនឲ្យឯកភាពជាមួយមាគ៌ារបស់អង្គការទេ ដូចជាការមិនព្រមទទួលជំនួយបរទេស ការមិនព្រមចំណាយកម្លាំងសម្រាប់រកស្បៀង និងផ្ដល់ស្បៀងដល់កន្លែងខ្វះខាត គឺត្រីសាច់ដែល (មានយ៉ាងសម្បូរនៅក្នុងបឹង) ការធ្វើការងារទាំងថ្ងៃទាំងយប់ស្ទើរមិនមានពេលសម្រាក និងប្រើមនុស្ស ឲ្យធ្វើការដោយមិនគិតដល់កម្លាំងបន្តិចសោះ ។

ខ្ញុំមិនពេញចិត្តនឹងការចាត់តាំងរបស់អង្គការទេ ក្នុងការជ្រើសតាំងប្រធានក្រុមក្រោយនេះ ។ ខ្ញុំយល់ថា អង្គការប្រើអំណាចមួយដែលគ្មានលក្ខណៈប្រជាធិបតេយ្យ ។ ខ្ញុំបានចាត់ទុកប្រធានមន្ទីរនៅព្រៃកប្បាស (ក៩) ថាជាមនុស្សគ្មានសមត្ថភាពក្នុងការដឹកនាំមន្ទីរ ។

ខ្ញុំតែងរំពឹងពីការអស់សង្ឃឹមទៅលើអនាគតរបស់ប្រទេសយើងផង និងទៅលើយើងជាបញ្ញាជន ដែលវិលមកប្រទេសផងក្នុងចំណោមមិត្តភក្តិដូចមានរៀបរាប់ខាងលើ ។ ខ្ញុំបានចាត់ទុកថាអង្គការគ្មានការស្មោះត្រង់ ដោយថា យកបញ្ញាជនទៅប្រើតាមបច្ចេកទេស តែការពិតខ្ញុំយល់ថា អង្គការភូតកុហកទៅវិញ ។

ជារួម ក្នុងការរស់នៅឯព្រៃកប្បាសនេះ ខ្ញុំមានសុទិដ្ឋិនិយមច្រើនលើអនាគតរបស់ខ្លួនលើអនាគតរបស់ប្រទេស ។ ខ្ញុំនៅតែមានកំហឹងនឹងលទ្ធិកុម្មុយនីស្តដដែល ហើយត្រៀមខ្លួនថានឹងរួមសកម្មភាពយ៉ាងសកម្មនៅថ្ងៃណាដែលមានការវិលត្រឡប់នៃរបបសេរីមកវិញ ។ ឯភារកិច្ចដែលខ្ញុំបានទទួល ពី សេ.អ៊ី.អា នៅ បារាំង ខ្ញុំបានយល់ថា ខ្ញុំពុំមានលទ្ធភាពបំពេញឡើយ ។ ខ្ញុំតែងមានការនឹកស្ដាយជារៀងរាល់ថ្ងៃថា ពុំគួរបណ្ដោយខ្លួនឲ្យធ្លាក់ចូលក្នុងអន្ទាក់របស់ខ្មែរក្រហមយ៉ាងនេះសោះ ។

ខ្ញុំដឹងខ្លួនដែរថា អង្គការកំពុងស៊ើបរកអ្នក សេ.អ៊ី.អា ។ ប៉ុន្តែខ្ញុំមិនជឿថា អង្គការរកឃើញខ្ញុំជា សេ.អ៊ី.អា សោះឡើយ ។

ទីបំផុត ខ្ញុំត្រូវអង្គការរកឃើញ ហើយចាប់ខ្លួនបាននៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៦ នៅព្រៃកប្បាសនេះ ។

**សោម ប៊ុនថន**

**◆ និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**

**◆ រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# មតិសំខាន់ៗមួយចំនួនរបស់សមមិត្តលេខាមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ក្នុងសន្និបាតប្រចាំឆ្នាំ១៩៧៧ របស់ភូមិភាគបស្ចិម

*ដកស្រង់ចេញពីឯកសារ ទង់បដិវត្តន៍លេខ៣ ខែមីនា ឆ្នាំ១៩៧៨*

## មតិលើសេចក្តីរាយការណ៍របស់ភូមិភាគ

ខ្ញុំសូមឯកភាពលើសេចក្តីរាយការណ៍របស់គណបក្សភូមិភាគ លើគ្រប់ទិដ្ឋភាពៈ ទាំងផ្នែកការពារប្រទេស ទាំងផ្នែកបន្តធ្វើបដិវត្តន៍សង្គមនិយម និងទាំងផ្នែកកសាងសង្គមនិយម ហើយលើភារកិច្ចស្នូលរបស់ភូមិភាគ ក្នុងឆ្នាំ១៩៧៧នេះ ។

យើងឃើញថា គុណសម្បត្តិលើគ្រប់ផ្នែកដើរតួគ្របដណ្តប់ជាមូលដ្ឋាន ។ ឯគុណវិបត្តិក៏មាន តែគុណសម្បត្តិវាមានប្រៀបលើគុណវិបត្តិ ។ គុណវិបត្តិ និងការខ្វះខាតខ្លះរបស់ភូមិភាគ មិនមែនធ្វើឲ្យសភាពការណ៍ភូមិភាគខាងកិច្ចការពារក្តី ខាងកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយមក្តី ខាងកសាងសង្គមនិយមក្តី វាត្រឡប់ត្រឡិន រយីករយាកនោះទេ ។

ដូច្នេះ ឃើញថាមានការរីកចម្រើនឈានទៅមុខ លើគ្រប់ផ្នែក ហើយដោយឡែកចំពោះតែកិច្ចការពារប្រទេសនេះឃើញថាវាលឿនទៅមុខច្រើនដែរ ។



កងចល័តកាស់គល់ឈើ នៅក្នុងរបបខ្មែរក្រហម

ឯផ្នែកដទៃទៀត ក៏រីកចម្រើន ដូចជាផលិតផលខាងស្រូវ ៣តោន និង៦តោនសម្រេចបានពី៨០ ទៅ៩០ភាគរយ ។ នេះជាមហាជ័យជម្នះរបស់បក្សភូមិភាគរបស់ប្រជាជនភូមិភាគ និងកងទ័ព ភូមិភាគបស្ចិមទាំងមូល ហើយក៏ជាជ័យជម្នះរបស់បក្សទូទាំងប្រទេស ហើយក៏ជាជ័យជម្នះរបស់មិត្តភក្តិ លើសកលលោក ដែលគេអបអរសាទរ ចំពោះជ័យជម្នះរបស់យើងផងដែរ ។

តាមតួលេខរបស់គណបក្សភូមិភាគ បានប្រកាសអម្បាញ់មិញ គឺភូមិភាគបស្ចិម សម្រេចផ្តល់ជូនរដ្ឋ នាំចេញបានតាមផែនការដែលបក្សកំណត់ ។ ដូច្នេះ គឺសម្រេចបាន១០០ភាគរយ ក្រោយពីទូទាត់នូវស្បៀង តាមរបបរបស់បក្សកំណត់ និងពូជដែលត្រូវទុកធ្វើម្តង និងពីរដង ក្នុងឆ្នាំ១៩៧៨ ។ នេះជាជ័យជម្នះធំណាស់ ។

ជ័យជម្នះធំក្នុងការដោះស្រាយជីវភាពប្រជាជនឲ្យបានគ្រប់គ្រាន់ តាមសំណូមពររបស់បក្ស ព្រោះយើងចង់លើកស្ទួយជីវភាពប្រជាជនយើងឲ្យបានឆាប់រហ័ស ។ម្យ៉ាងទៀត ការនាំចេញជាស្រូវ អង្ករទៅក្រៅប្រទេស វាមានន័យសេដ្ឋកិច្ចផង មានន័យនយោបាយផង ។ យើងនាំស្រូវអង្ករចេញទៅក្រៅប្រទេស ដើម្បីនាំចូលមកវិញនូវវត្ថុធាតុដើមផ្សេងៗ សម្រាប់បម្រើឧស្សាហកម្ម និងជីវភាព ប្រជាជនរបស់យើង ។

ឯន័យនយោបាយ គឺយើងនាំចេញទៅក្រៅប្រទេស នាំឲ្យជះឥទ្ធិពលល្អទៅលើសកលលោក គឺថា ប្រជាជនកម្ពុជានាំអង្ករចេញក្នុងសភាពដែលសកលលោកកំពុងខ្វះស្បៀង ។ យើងនាំចេញក្រោយសង្គ្រាមមហាវិនាសកម្មត្រឹម២ឆ្នាំ ប៉ុណ្ណោះ ។ ដូច្នេះ គេឃើញនូវកម្លាំងប្រជាជនយើង កម្លាំងបដិវត្តន៍យើង ។ ន័យនយោបាយនេះ ធំទូលាយណាស់ ។

នេះចង់បញ្ជាក់អំពីជ័យជម្នះរបស់បណ្តាសមមិត្ត សម្រេចផែនការ៣តោន និង៦តោន ទាំង ដោះស្រាយជីវភាពប្រជាជនទាំងនាំចេញ ។ នេះមានអត្ថន័យបដិវត្តន៍ធំណាស់ ទាំងក្នុងប្រទេសទាំងក្រៅប្រទេស ។

តទៅនេះ ខ្ញុំសូមសង្កត់នូវបញ្ហាខ្លះជាពិសោធផង ឬក៏ជាលាក់ការណ៍លើបញ្ហាមួយចំនួន ។ ក្នុងសេចក្តីរាយការណ៍ គណបក្សភូមិភាគ បានលើកឡើងនូវគុណវិបត្តិមួយចំនួន ។ ខ្ញុំយល់ឃើញថាការលើកឡើងនូវគុណវិបត្តិជាការត្រឹមត្រូវដើម្បីអ្វី? ដើម្បីឃើញចំណុចខ្លាំងយើងឲ្យច្បាស់ ហើយឃើញចំណុចខ្សោយយើងឲ្យច្បាស់ ដើម្បីឈានទៅមុខទៀត ។ កុំឲ្យឃើញតែចំណុចខ្លាំង ហើយភ្លេចចំណុចខ្វះខាត ។ ដូច្នេះ យើងឃើញចំណុចខ្លាំង ហើយភ្លេចចំណុចខ្វះខាត ។ ដូច្នេះ យើងឃើញចំណុចខ្លាំង ដើម្បីយើងរីករាយ ពេញចិត្តរៀនសូត្រពីជ័យជម្នះរបស់យើង ដើម្បីឈានទៅមុខទៀត


កម្មាភិបាលខ្មែរក្រហមដកសំណាប

ហើយយើងឃើញចំណុចខ្វះខាតរបស់យើង ដើម្បីយើងដោះស្រាយដកពិសោធ ខុសកែប្រែ ដើម្បីឈានទៅមុខទៀត ។

ការវិភាគក្នុងសេចក្តីរាយការណ៍នេះត្រឹមត្រូវមានតុល្យភាព ផ្នែកត្រូវក៏ឲ្យឃើញ ផ្នែកខុសក៏ឲ្យឃើញ ដើម្បីឈានទៅមុខ ។ តែតាមយោបល់ខ្ញុំ ការខ្វះខាតនេះ វាធម្មតាទេ ។ មានការខ្វះខាតក្នុង



សភាពឈានទៅមុខ មានការខ្វះខាត ក្នុងភាពនៅនឹងថ្កល់ ហើយមានការខ្វះខាតក្នុងសភាពថយក្រោយ ។

ក្រឹត្យក្រមនៃបដិវត្តន៍ និយាយរួមតែងមាន ពីរ ទិដ្ឋភាព ៈ

◆ ទិដ្ឋភាពមួយផ្នែកគុណសម្បត្តិ

◆ ទិដ្ឋភាពមួយទៀតផ្នែកគុណវិបត្តិ ប៉ុន្តែយើងថ្លឹងគុណសម្បត្តិនិងគុណវិបត្តិនេះ ទៅលើមួយណាធំជាង ។ ថ្លឹងនៅក្នុងក្រុមមួយ កងមួយ ស្រុកមួយ សហករណ៍មួយអ៊ីចឹង ។ សំខាន់កុំច្របូកច្របល់ ។ ឧបមាថា ស្រុកមួយខ្លាំង បង្ហាញនូវគុណសម្បត្តិរបស់ខ្លួនបង្ហាញនូវគុណវិបត្តិរបស់ខ្លួន ។ គុណវិបត្តិច្បាស់ជាមានហើយ ។ ស្រុកមួយទៀត ក៏បង្ហាញនូវគុណសម្បត្តិរបស់ខ្លួន បង្ហាញនូវគុណវិបត្តិរបស់ខ្លួន ប៉ុន្តែ ថ្លឹងវាមិនត្រូវ ។ ថ្លឹងទៅមិនដឹងណាធ្ងន់ជាង ណាស្រាលជាង ។ ស្រុកហ្នឹង មើលទៅឃើញតែគុណសម្បត្តិ គុណវិបត្តិប្រហែលគ្នា ។ ការនេះ មកពីយើងថ្លឹងមិនត្រូវ ។ បើថ្លឹងត្រូវទើបឃើញថា ស្រុកណាឈានទៅមុខ ស្រុកណានៅដដែល ស្រុកណាថយក្រោយ ។

បើគុណសម្បត្តិច្រើន ទោះជាមានគុណវិបត្តិក៏ដោយ ស្រុកនោះវាលឿនទៅមុខហើយ ។ ពិតមែន តែវាមានគុណវិបត្តិ តែជាគុណវិបត្តិ ក្នុងការឈានទៅមុខ ។ នេះយើងមិនព្រួយទេ ព្រោះគុណវិបត្តិនេះ វាជាការធម្មតាក្នុងសភាពឈានឡើង ។ តែស្រុកខ្លះ មានគុណសម្បត្តិហើយ ប៉ុន្តែ មានគុណវិបត្តិថ្លឹងទៅប្រហាក់ប្រហែលគ្នា វានៅច្របូកច្របល់ ។ ពិនិត្យឃើញថា ស្រុកហ្នឹងវាមិនលឿន វាទៅមុខផង ថយក្រោយផង មួយជំហានទៅមុខ ថយក្រោយវិញមួយជំហាន ជួនកាលមួយជំហានទៅមុខពីរជំហានថយក្រោយ ។ ស្រុកហ្នឹង គឺថយក្រោយត្រូវដោះស្រាយហើយ ។ យើងលើកបញ្ហានេះឡើង ដើម្បីពង្រឹងខ្លួនតទៅទៀត ។ នៅក្នុងក្របខណ្ឌសហករណ៍ក៏ត្រូវចេះវិភាគក្របខណ្ឌស្រុក ក៏ត្រូវចេះវិភាគខ្លួនឯង ។ កុំឲ្យអត្តនោម័តិ ។ វិភាគខ្លួនឯងអ៊ីចឹង ដើម្បីឈានទៅមុខទៀត ។ ឯតំបន់ក៏ត្រូវចេះវិភាគ ក៏ត្រូវចេះវិភាគអ៊ីចឹង ដើម្បីដោះស្រាយស្រុកនេះ ឲ្យទាន់ពេលវេលា ។ បើមិនអ៊ីចឹងទេ បន្ទាយពេលឲ្យស្រុកហ្នឹង មានតែគុណវិបត្តិ ។ ឆ្នាំនេះ គុណសម្បត្តិផង គុណវិបត្តិផង ឆ្នាំក្រោយគុណវិបត្តិផង ឆ្នាំក្រោយគុណវិបត្តិផង គុណសម្បត្តិផង ប៉ុន្តែ ចេះតែថយក្រោយ ។ ជីវភាពប្រជាជនក៏ដោះស្រាយមិនខ្លាំង ។ បញ្ហានាំចេញក៏មិនខ្លាំង ។ល ។ ប៉ុន្តែ ចេះតែមានគុណសម្បត្តិ និងគុណវិបត្តិ

ប្រហែលគេ ប្រហែលឯងដែរ ។ ប៉ុន្តែ បើពិនិត្យមែនទែន ថ្លឹងមែនទែន ទើបឃើញថា ជីវភាពប្រជាជនមិនបានដោះស្រាយ ។ នាំចេញក៏មិនបាន ឬក៏នាំចេញបានបន្តិចបន្តួច ដោយបេះបោចយកពីរបបប្រជាជន ដែលបក្សកំណត់ ។ ចំណាយមួយរយភាគ ចំណូលវិញបានតែដប់ភាគ ។ បើយ៉ាងនេះធ្ងន់ណាស់ ដោះស្រាយមិនរួច ។

ដូច្នេះ ខ្ញុំយល់ឃើញថា ការដែលលើកឡើងក្នុងសេចក្តីរាយការណ៍ថា មានគុណវិបត្តិនៅក្នុងភូមិ ភាគទាំងមូល នេះជាការធម្មតា ព្រោះជាគុណវិបត្តិ ដែលស្ថិតក្នុងសភាពកំពុងឈានឡើង ។ នេះខ្ញុំនិយាយទូទាំងភាគ អាចក្នុងតំបន់មិនទាន់ស្មើគ្នា អាចក្នុងស្រុកនីមួយ ៗ មិនទាន់ស្មើគ្នា ប៉ុន្តែ និយាយរួម ក្នុងភូមិភាគទាំងមូល យើងកំពុងឈានឡើងខ្លាំងដែរ ព្រោះយើងសម្រេចផែនការរបស់បក្សបាន ។

## អំពីភារកិច្ចការពារ

តាមសេចក្តីរាយការណ៍របស់គណបក្សភូមិភាគ និងតាមយើងខ្ញុំដឹងខ្លះ សភាពការណ៍ក្នុងភូមិភាគ នៅតាមតំបន់នីមួយ ៗ ឃើញថា ឆ្នាំ១៩៧៧ នេះ ជាការប្រយុទ្ធរវាងខ្មាំង និងយើងខ្លាំងក្លាជ្រាលជ្រៅ តឹងតែង ស្មុគស្មាញ ។ មិនមែនការពារភូមិភាគបស្ចិមនេះបាន ដោយសភាពធម្មតាទេ ។ យើងការពារបានក្នុងសភាពប្រយុទ្ធតឹងតែង ស្មុគស្មាញ រវាងយើង និងខ្មាំង ។ ប្រយុទ្ធក្នុងក្របខណ្ឌភូមិភាគ ទាំងមូល ទាំងផ្នែកក្រសួង មន្ទីរ ទាំងផ្នែកសហករណ៍ស្រុក តំបន់ ទាំងផ្នែកយោធា ពេទ្យ បច្ចេកទេសផ្សេងៗ ហើយក្នុងការប្រយុទ្ធនេះ យើងឈ្នះ យើងវាយខ្មាំងឲ្យបរាជ័យ ។ បើក្នុងឆ្នាំ១៩៧៧ កន្លងមក យើងមិនវាយខ្មាំងឲ្យបរាជ័យទេ គឺវាពង្រឹងកម្លាំងវាបានពង្រីកកម្លាំងវាបានទៀត នាំឲ្យសភាពការណ៍នៅក្នុងភូមិភាគរយីករយាក ហើយស្មុគស្មាញ ។ យើងលើកបញ្ហាប្រយុទ្ធនឹងខ្មាំងតឹងតែងនេះ ចង់បញ្ជាក់ថា ការប្រយុទ្ធការពារភូមិភាគការពាររដ្ឋអំណាច កម្មករ កសិកររបស់បក្ស ការពារបដិវត្តន៍ ការពារបក្ស ការពារប្រជាជន សហករណ៍ ជាការប្រយុទ្ធតឹងតែងរាល់ថ្ងៃរាល់ពេល ហើយតាមគ្រប់រូបភាព ។ ចំហក៏ប្រយុទ្ធ សម្ងាត់ក៏ប្រយុទ្ធខាងយោធាក៏ប្រយុទ្ធ នយោបាយក៏ប្រយុទ្ធ ខាងសតិអារម្មណ៍



កងយោធា និងកម្មាភិបាលខ្មែរក្រហម នៅពហុកីឡដ្ឋានអូឡាំពិក

ក៏ប្រយុទ្ធ ខាងចាត់តាំងក៏ប្រយុទ្ធ ខាងសេដ្ឋកិច្ចក៏ប្រយុទ្ធ ខាងវប្បធម៌ សង្គមកិច្ច ខាងសុខាភិបាលក៏ប្រយុទ្ធ ប្រយុទ្ធតឹងតែង ហើយបើយើងមិនមោះមុតប្រយុទ្ធទេ ខ្មាំងវាពង្រីង និងពង្រីកកម្លាំងវាបាន ។

ក្នុងខែឧសភា ឆ្នាំ១៩៧៦ សមាសភាពខ្មាំង នៅកាន់កាប់អំណាចច្រើននៅឡើយ ។ មាគ៌ារបស់បក្សគ្រប់ផ្នែក មិនបានផ្សាយចុះដល់មូលដ្ឋាន ហើយក៏មិនបានអនុវត្តនៅក្នុងមូលដ្ឋានទៀតផង ។ មកពីអ្វី? មកពីយើងមិនបានដោះស្រាយបញ្ហាចាត់តាំង ។ ប៉ុន្តែដល់ឆ្នាំ១៩៧៧ យើងដោះស្រាយបញ្ហាចាត់តាំងបាន ។ ក្រោយពីប្រយុទ្ធខាងនយោបាយ ខាងសតិអារម្មណ៍ យើងប្រយុទ្ធខាងចាត់តាំង យើងសម្រិតសម្រាំងខាងចាត់តាំង ។ លុះដល់កាលណាយើងបានសម្រិតសម្រាំងខាងចាត់តាំងបាន ច្រើនជាមូលដ្ឋានទៅខាងនយោបាយ សតិអារម្មណ៍របស់បក្ស ក៏បានអនុវត្តនៅក្នុងមហាជន ។ ដូច្នេះ សមាសភាពនៅក្នុងឆ្នាំនេះ វាខុសកាលពីឆ្នាំ១៩៧៦ ច្រើនណាស់ ហើយវាខុសពីកាលខែកុម្ភៈ ឆ្នាំ១៩៧៧ ឆ្ងាយណាស់ទៀតផង ។ អ៊ីចឹង បានយើងឃើញថា ការប្រយុទ្ធនេះ វាតឹងតែងណាស់ ប្រែក្រឡាប់ចាក់ ព្រោះហេតុអី? ព្រោះអ្នកកាន់អំណាចនៅក្នុងកងទ័ពនៅក្នុងបក្ស នៅក្នុងក្រសួង មន្ទីរ មួយចំនួន ហើយដែលចូលធ្វើសកម្មភាពបដិវត្តន៍មកយូរហើយ ខ្លះតាំងពីជំនាន់តស៊ូហិង្សានយោបាយរាប់សិបឆ្នាំហើយ ហៅថា មានស្លាក មានយីហោល្បីល្បាញ ហើយមកលួចបង្កប់នៅក្នុងជួររដ្ឋអំណាចដើម្បីបំផ្លាញបក្សបដិវត្តន៍យើង ។ យើងរកឃើញខ្សែទាំងអស់នេះហើយ កម្ចាត់វាអស់ជាមូលដ្ឋាន ធ្វើឲ្យមុខមាត់ភូមិភាគនេះ ប្រែប្រួលថ្មីស្រឡាងច្រើនណាស់ អាចសន្មតថា ជាក្រឡាប់ចាក់បាន ។

សុំលើកបញ្ហាទាំងនេះឡើង ដើម្បីពង្រឹងគោលជំហរប្រយុទ្ធ ។ នៅក្នុងសន្និបាតនេះ យើងរៀនសូត្រពិសោធអំពីការប្រយុទ្ធនៅឆ្នាំ១៩៧៧នេះ ជាការប្រយុទ្ធយ៉ាងម៉េច ដើម្បីពង្រឹងបំពាក់ជំហរឲ្យរឹង ហើយប្រយុទ្ធតទៅទៀត ក្នុងក្របខណ្ឌកងតូច កងធំ សហករណ៍ មន្ទីរ ក្រសួង អង្គភាពផ្សេងៗ ឬក៏ស្រុក តំបន់ សម្រាប់ប្រយុទ្ធតទៅមុខទៀត ។ នេះជាការកសាងគោលជំហរ កិច្ចការពារប្រទេស ការពាររដ្ឋអំណាច កុំឲ្យខ្មាំងវាដណ្តើមបាន ។ តទៅមុខទៀត យើងបំពាក់ជំហរប្រយុទ្ធនេះតទៅទៀត កុំឲ្យវាទៅជាធម្មតា ព្រោះវាជាការប្រយុទ្ធតឹងតែង ។

យើងត្រូវអប់រំក្នុងបក្ស ប្រជាជន កងទ័ពទាំងមូលឲ្យយល់ ហើយឲ្យយល់ថែមទៀត តើខ្មាំងវាបំផុសអី វាប្រឆាំងអី វាបំផ្លាញរបៀបយ៉ាងម៉េច ដើម្បីលើកគុណភាពនយោបាយ សតិអារម្មណ៍ឲ្យខ្លាំងថែមទៀត ដើម្បីបន្តការប្រយុទ្ធតទៅទៀត ថ្ងៃនេះ ឆ្នាំមុខ និងតៗជំនាន់ទៅទៀត ភារកិច្ចនេះ មិនមែនជាភារកិច្ចដោយឡែករបស់អ្នកណាម្នាក់ទេ ជាភារកិច្ចរបស់យើងទាំងអស់គ្នា ។ ថ្ងៃក្រោយយើងបន្តភារកិច្ចនេះ យើងមានជំហររឹងប៉ឹង ។ បើយើងមិនប្រយុទ្ធកម្ចាត់វាទេ ខ្មាំងវាប្រយុទ្ធកម្ចាត់យើង វាឈ្នះយើង ។ បើយើងមិនបោសសម្អាតវាទេ វាលេងយើងហើយ ។ ៣គោន និង៦គោនបានតែ១ ឬ ២គោន ។ យ៉ាងនេះ ប្រជាជនមុខជាអត់បាយ ។ វាបំផ្លាញអ្វីទាំងអស់ ដែលអាចបំផ្លាញបាន ហើយវានឹងកាន់អំណាចតទៅទៀត ។

ឆ្នាំ១៩៧៧នេះ រាប់ជាខែ តែ១២ខែទេ តែការប្រយុទ្ធនេះដូចជារាប់សិបឆ្នាំអ៊ីចឹង ។ មួយឆ្នាំ១៩៧៧នេះ ហាក់ដូចជាដោះស្រាយប៉ុន្មានជណ្តប់ឆ្នាំអ៊ីចឹង ។ វាប្រែប្រួលក្រឡាប់ចាក់ ។ មួយភ្លែតទេ តែប្រែប្រួលសម្បើមណាស់ ។ នេះបានហៅថា បដិវត្តន៍ជ្រាលជ្រៅ បើយើងសម្រុះសម្រួលជាមួយខ្មាំង ស្ថានការណ៍មិនក្រឡាប់ចាក់អ៊ីចឹងទេ ។ ខ្មាំងវានៅជាមួយយើងតទៅទៀត ។ វាមិនគ្រាន់តែនៅក្នុងសហករណ៍ទេ វានៅក្នុងគណៈស្រុក គណៈតំបន់ និងគណៈខ្ពស់ៗតទៅទៀត ។ បញ្ហានេះធ្ងន់ធ្ងរណាស់ ព្រោះស្រុក តំបន់ មានសិទ្ធិគ្រប់គ្រងរហូតដល់សហករណ៍ ដូច្នេះ រឹតតែធ្ងន់ធ្ងរទៅទៀត ។ មជ្ឈិមក៏រៀនសូត្រអំពីការប្រយុទ្ធឆ្នាំ១៩៧៧នេះ ។ បក្សយើងធ្វើម្ចាស់ការវាយខ្មាំងខាងក្នុងមុន ឯខ្មាំងខាងក្រៅក៏យើងវាយ តែខ្មាំងខាងក្នុង យើងកម្ទេចអស់ជាមូលដ្ឋានស្រេចទៅហើយ ដល់ខ្មាំង ខាងក្រៅវាយមក អាខ្មាំងខាងក្នុងវាងើបក្បាលមិនរួច វាគ្មានកម្លាំង ។ តើមកពីអ្វី? មកពីយើងដោះស្រាយទំនាស់ជាមួយខ្មាំងបានទាន់ពេលវេលា ។ យើងវាយខ្មាំងបានទាន់ពេលវេលា ។ យើងវាយសម្រុកខ្មាំងជាប់ ។ យើងវាយក្នុងឋានៈជាម្ចាស់ការ ជាន់ក្បាលខ្មាំងជាប់ ។ តទៅមុខទៀត យើងត្រូវឈរលើពិសោធនេះ ។ បើពន្យារពេលវាយខ្មាំង គឺសម្រុះសម្រួលជាមួយខ្មាំងហើយ ។ បើសម្រុះសម្រួលជាមួយខ្មាំងហើយ ខ្មាំងវាមុខជាពង្រឹងពង្រីកកម្លាំង

វាបាន ។ នៅសល់ម្នាក់ វាពង្រីងពង្រីក២ ឬ ៣នាក់ ។ បញ្ហានេះគ្រោះថ្នាក់ណាស់ ។ គ្រោះថ្នាក់ដល់ឆ្នាំ៨០ ឆ្នាំ៨៥ ឆ្នាំ៩០ ឆ្នាំ៩៥ ឆ្នាំ២០០០ ។ ការប្រយុទ្ធនេះ វាយ៉ាងហ្នឹង អនុគ្រោះឲ្យខ្មាំង មិនបាន ដាដាច់ខាត ។ និយាយយ៉ាងនេះ មិនមែនថាយើងចេះតែកម្ទេចចេះតែបោសសំអាតប៉ាតណាប៉ាតណីនោះទេ ។ បក្សយើងមានមាគ៌ា វិភាគបែងចែកប្រភេទទី១ ត្រូវអប់រំយ៉ាងម៉េច ប្រភេទទី២ ត្រូវកសាងយ៉ាងម៉េច ប្រភេទទី៣ អប់រំ និងកសាងយ៉ាងម៉េច ដើម្បីអូសទាញគេមកកសាង ។ ឯពួកភាន់ច្រឡំកសាងដែរ ។ ប៉ុន្តែ ត្រូវដាច់ខាត បើមិនដាច់ខាត វាវាយយើងត្រឡប់ត្រឡិនឥឡូវហើយ ព្រោះខ្មាំងខាងក្រៅក៏វាយ ខ្មាំងខាងក្នុងក៏វាយ ។

នេះជាចំណុចដែលត្រូវលើកឡើង ដើម្បីជាពិសោធនៅក្នុងភូមិភាគ តំបន់របស់យើង ទុកសម្រាប់ឆ្លុះបញ្ចាំងទៅថ្ងៃក្រោយ ។ ដើមឆ្នាំ១៩៧៧ យើងយល់ខ្មាំងបានមួយកម្រិត ចុងឆ្នាំ១៩៧៧ យើងយល់ខ្មាំងកាន់តែច្រើន ។ ឈរលើទុននេះ ដល់ដើមឆ្នាំ១៩៧៨ យើងពង្រីងពង្រីកទុននេះតទៅទៀត ប្រយុទ្ធវាយខ្មាំងតទៅទៀត ។

ឧទាហរណ៍ ខ្មាំងយួនវាវាយយើងភ្លាម ផ្នែកខាងកើតបក្សចេញសារាចរភ្លាម ឲ្យតាមដានគ្រប់មូលដ្ឋាន តើមានសមាសភាពខាងក្នុងយ៉ាងម៉េច? វាឃោសនាឲ្យយួនវាយយើងយ៉ាងម៉េច? យើងណែនាំភ្លាម យើងម្ចាស់ការភ្លាម ណែនាំឲ្យមានវិធានការភ្លាម ។ ដល់យួនវាយយើង ភ្នាក់ងារយួនក៏លេចមុខ ភ្នាក់ងារ សេ.អ៊ី.អា ក៏លេចមុខ ។ សេ.អ៊ី.អា និងយួន វាដូចតែគ្នា វាវាយបដិវត្តន៍កម្ពុជាដូចគ្នា ។ វាគ្រាន់តែមួយស្លាកយួន មួយស្លាក សេ.អ៊ី.អា ។ ខ្លឹមសារតែមួយភារកិច្ចតែមួយ ។ សមាសភាពដែល មិនល្អ សមាសភាពដែលបំផ្លិចបំផ្លាញមកឃោសនា ឬក៏មកធ្វើវិទ្ធំសនកម្មអីផ្សេងៗ ក៏ត្រូវប្រយុទ្ធដោះស្រាយឲ្យទាន់ពេលវេលា បើយើងពិនិត្យឲ្យទាន់ពេលវេលា យើងឃើញខ្មាំងភ្លាម ។

សូមជម្រាបថា យួនដែលវាឈ្លានពានយើងសព្វថ្ងៃនេះ វាវាយមិនឈ្នះយើងទេ ។ កត្តាដែលត្រូវប្រុងប្រយ័ត្នឲ្យខ្ពស់ គឺ ខ្សែចាត់តាំងចារកម្មរបស់ខ្មាំង ។ ខ្មាំងវាវាយយើងបាន អាស្រ័យខ្សែចារកម្ម ដែលវាបង្កប់នៅក្នុងផ្ទៃក្នុងយើង ។ វាចូលមកបានលុះត្រាតែមានខ្សែរបស់វា ខ្សែនៅតាមមូលដ្ឋាន ខ្សែនៅក្នុងកងទ័ព ។ បើគ្មានបញ្ហាហ្នឹងទេបញ្ហាយោធា យើងគ្មានអ្វីគួរឲ្យព្រួយបារម្ភទេ ។ ខ្មាំងចូលមក យើងវាយខ្ទេច ដូច្នេះ ការប្រយុទ្ធទាំងនយោបាយ សតិអារម្មណ៍ ចាត់តាំង សេដ្ឋកិច្ច វប្បធម៌ ទាំងយោធា ពេទ្យ សុខាភិបាល អប់រំ សិក្សាធិការទាំងអស់នេះ សុទ្ធតែត្រូវប្រយុទ្ធហើយ ។ គ្រប់មូលដ្ឋាន គ្រប់កន្លែង សុទ្ធតែមានការប្រយុទ្ធរវាងខ្មាំង និងយើង ដូច្នេះគ្រប់កន្លែងត្រូវម្ចាស់ការ និងប្រុងប្រយ័ត្នគ្រប់កាលៈទេសៈ ។ ឃើញភាពអីលេចឡើង ត្រូវវិភាគភ្លាម វិភាគខ្លួនឯងមិនចេញ ត្រូវរាយការណ៍ជូនថ្នាក់លើ ដើម្បីថ្នាក់លើវិភាគ ។

នេះចង់បញ្ជាក់ថា នៅកន្លែងណាក៏ដោយ ផ្នែកណាក៏ដោយ ត្រូវតែប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ ហើយម្ចាស់ការជាមុន ដោយអប់រំជីវភាព ប្រជុំតិទៀន ស្វ័យតិទៀន ធ្វើជីវទស្សន៍បដិវត្តន៍សម្រិតសម្រាំងការចាត់តាំង ពិនិត្យតាមដានជាបន្តបន្ទាប់ទៅ ។ ធ្វើយ៉ាងនេះ យើងម្ចាស់ការបានមួយកម្រិតខ្ពស់ ប៉ុន្តែ បើយើងបណ្តែតបណ្តោយគិតថាយើងនៅខាងពេទ្យ ឥតមានអីទេ ខ្ញុំនៅខាងកាត់ដេរ អត់មានអីទេ ខ្ញុំនៅខាងដីដែក អត់មានអីទេ ។ យ៉ាងនេះ គឺគោលជំហរប្រយុទ្ធរវាងខ្មាំង និងយើងនៅមិនទាន់រឹងប៉ឹង ។ ទំនាស់រវាងខ្មាំង និងយើងទំនាស់រវាងបដិវត្តន៍ មិនបដិវត្តន៍ យើងយល់មិនច្បាស់លាស់ ហើយមិនមានជំហររឹងប៉ឹង ។ បើយើងមានជំហររឹងប៉ឹង យើងប្រុងប្រយ័ត្នជាប់ នៅពេទ្យក៏ប្រុងប្រយ័ត្ន នៅកន្លែងណាក៏ប្រុងប្រយ័ត្ន កងតូច កងធំ សហករណ៍ ស្រុក ក៏ប្រុងប្រយ័ត្នបដិវត្តន៍ ។

សូមជម្រាបថា ការប្រយុទ្ធនេះ វានៅយូរតទៅទៀត យូរនេះមិនមែនរាប់ខែទេ ហើយក៏មិន រាប់ឆ្នាំដែរ យូរនេះ គឺរាប់សិបឆ្នាំហើយរាប់រយឆ្នាំតទៅទៀត ជាការតស៊ូវណ្ណៈនៅយូរទៀត ។ យើងថាយូរនេះ ដោយសារប្រយុទ្ធរវាងខ្មាំង និងយើង ប៉ុន្តែការពិត ជាការប្រយុទ្ធ រវាងវណ្ណៈអធន និងវណ្ណៈនាយទុន និងពួកវណ្ណៈជិះជាន់ផ្សេងៗ ។ តាមធម្មតា វណ្ណៈជិះជាន់វាចង់វាយយើងដើម្បីដណ្តើមរដ្ឋអំណាច ។ ដូច្នេះ ការតស៊ូវណ្ណៈនៅយូរណាស់ ។ បើនៅយូរ តើដោះស្រាយយ៉ាងម៉េច? ទាល់តែមានវិធានការត្រឹមត្រូវ ។ ដូច្នេះរាល់ថ្ងៃត្រូវប្រយុទ្ធ ភ្ញាក់ឡើងត្រូវប្រយុទ្ធ ប៉ុន្តែជួនណា សម្រាន្តលក់ហើយក៏ត្រូវប្រយុទ្ធទៀត ព្រោះការប្រយុទ្ធវាតឹងតែងជាប់ ត្រូវគិតរាល់ពេលរាល់វេលា ដើម្បីដោះស្រាយឲ្យឈ្នះខ្មាំង បើភ្លាត់ស្នៀតអាចចាញ់ខ្មាំង ។ ឧទាហរណ៍ នៅក្នុងសហករណ៍មួយ ការជ្រើសរើសសមាជិកសហករណ៍ជាគណៈសហករណ៍ ឬជាសមាជិក

ទទួលខុសត្រូវមុខព្រួញអ្វីមួយ ក៏ជាការប្រយុទ្ធដែរ ។ ជួនកាល គណៈកម្មាធិការស្រុកឯកភាពគ្នា ជួនណានៅក្នុងគណៈសហករណ៍ឯកភាពគ្នាថា យកសមមិត្តនេះ ជួនណាវាត្រូវទៅតាមមាគ៌ាវណ្ណៈ តាមមាគ៌ាចាត់តាំងរបស់បក្ស ។ ប៉ុន្តែ ជួនណា គណៈមិនឯកភាពគ្នា គណៈសហករណ៍មិនឯកភាពគ្នា សមមិត្តមួយថា យកមិត្តនេះ សមមិត្តមួយទៀតថា យកសមមិត្តនោះ នេះក៏ជាការតស៊ូដើម្បីការពារមាគ៌ាចាត់តាំងតាមមាគ៌ាវណ្ណៈរបស់បក្ស ឧបមាថា បានអ្នកមិនល្អចូលជាគណៈសហករណ៍ គឺយើងចាញ់ខ្មាំងខាងចាត់តាំង ពីព្រោះយើងឲ្យសមាសភាពមួយ ដែលមិនត្រឹមត្រូវចូល ។ ដូច្នេះ បានជាត្រូវប្រយុទ្ធតាំងពីសមរភូមិប្រយុទ្ធតូចៗអ៊ីចឹងទៅ តើអ្នកណា ត្រូវកាន់កាប់ជង្រុកស្រូវ អ្នកណាកាន់កាប់ចង្ក្រានបាយ អ្នកណាកាន់កាប់ខាងពេទ្យ ខាងកាត់ដេរ នៅក្នុងសហករណ៍ ។ យើងត្រូវដណ្តើមចាញ់ឈ្នះតាំងពីអ៊ីចឹងទៅ ។ យើងលើកបញ្ហានេះឡើង ដើម្បីឲ្យឃើញគ្រប់ទិដ្ឋភាព គ្រប់ផ្នែកដើម្បីប្រយុទ្ធឲ្យឈ្នះខ្មាំង ។ ភូមិភាគបស្ចិមបានដោះស្រាយបញ្ហានេះល្អជាបន្ទួរ ដោយប្រៀបធៀបដោយដាច់ខាតប្រយុទ្ធ ហើយដាច់ខាតជ្រើសរើសវណ្ណៈមូលដ្ឋានមកទទួលខុសត្រូវ ត្រូវពង្រីងពង្រីកទៅទៀតឲ្យកាន់តែល្អឡើង ។

ប៉ុន្តែកន្លែងខ្លះនៅស្មុគស្មាញច្រើនដែរ ត្រូវចាប់អារម្មណ៍អំពីបញ្ហានេះថែមទៀត ។ អំពីបញ្ហាទាំងអស់នេះ ដើម្បីការពារឲ្យបានល្អ មានតែសម្រិតសម្រាំងបក្សផ្ទៃក្នុងកងទ័ព ផ្ទៃក្នុងប្រជាជនឲ្យល្អឲ្យស្អាត ។ បញ្ហានេះ ជាបញ្ហាគន្លឹះ ។ ទោះបីមានកងទ័ពច្រើនយ៉ាងណាក៏ដោយ មានអាវុធច្រើនយ៉ាងណាក៏ដោយ បើបក្សមិនស្អាត បើកងទ័ពមិនស្អាត បើប្រជាជនមិនស្អាតទេ នោះការពារក៏មិនបានដែរ ។ ដូច្នេះ បញ្ហាគន្លឹះដែលត្រូវក្តាប់បច្ចុប្បន្ន និងទៅអនាគតឲ្យជាប់ គឺក្តាប់សមាសភាពនៅក្នុងបក្សឲ្យល្អ គឺបក្សភាគ បក្សតំបន់ បក្សស្រុក បក្សមូលដ្ឋាន បក្សក្នុងសហករណ៍ បក្សក្នុងកងទ័ព បក្សមន្ទីរ ឲ្យស្អាតទាំងអស់ នេះជាបញ្ហាគន្លឹះ បើបក្សស្អាតហើយ សមាសភាពផ្ទៃបក្សស្អាតហើយ នោះកិច្ចការពារមុខជាល្អហើយ ។

សរុបទៅគន្លឹះនៃបញ្ហាការពារ គឺនៅត្រង់ហ្នឹង បើបក្សស្អាតហើយសមាភាពផ្ទៃក្នុងស្អាត ហើយ កិច្ចការពារមុខជាល្អហើយ ។

### អំពីបដិវត្តន៍សង្គមនិយម

តទៅមុខទៀត ដើម្បីធ្វើបដិវត្តន៍សង្គមនិយមឲ្យបានខ្លាំង ឲ្យលឿនតទៅទៀត តើត្រូវធ្វើអ្វីខ្លះ? បញ្ហានេះ ក៏ដូចជាបញ្ហាកិច្ចការពារដែរ ដើម្បីបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យបានល្អ លុះត្រាតែមានអ្នកល្អ ទៅអនុវត្តមាគ៌ាបដិវត្តន៍សង្គមនិយមរបស់បក្សបានជាងគេ គឺកសិករក្រ និងកសិករកណ្តាលក្រោម បានសេចក្តីថាអ្នកដែលមានវណ្ណៈភាពល្អ ជាអ្នកអនុវត្តមាគ៌ារបស់បក្សបានល្អជាងគេ ។ ដូច្នេះ តទៅមុខទៀត ដើម្បីបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យបានល្អ ឲ្យបានខ្លាំងគឺត្រូវឈរលើសមាសភាពវណ្ណៈជាមូលដ្ឋាន ។ ក្នុងបក្ស នៅក្នុងប្រជាជន នៅក្នុងកងទ័ព នៅក្នុងមូលដ្ឋាននៅក្នុងសហករណ៍ ក៏ត្រូវជ្រើសរើសវណ្ណៈមូលដ្ឋាន ធ្វើជាស្នូលធ្វើជាសមាសភាពដឹកនាំ ទើបធានាដឹកនាំទាំងបច្ចុប្បន្ន និងទៅអនាគតបាន បើពុំនោះសោតទេ វានឹងនាំបដិវត្តន៍សង្គមនិយមដើរទៅផ្លូវវេរផងបង្វែរបន្តិចម្តងៗ ខុសពីមាគ៌ាបដិវត្តន៍សង្គមនិយមរបស់បក្ស ដូចជាក្នុងឆ្នាំ១៩៧៥-៧៦ កន្លងទៅនេះ មានសមាសភាពមិនល្អខ្លះ វាកាន់កាប់ដឹកនាំក្នុងតំបន់ នៅក្នុងស្រុក នៅក្នុងសហករណ៍ ដូច្នោះ វាបំភ្លៃមាគ៌ារបស់បក្ស ដឹកនាំខុសអំពីមាគ៌ារបស់បក្ស ។ ដូច្នោះ វាមិនឆ្ពោះទៅកាន់បដិវត្តន៍ សង្គមនិយម ទាំងនយោបាយ ទាំងសតិអារម្មណ៍ ទាំងចាត់តាំង ។ ជាពិសេស ខាងចាត់តាំង បើខុសអំពីមាគ៌ាចាត់តាំងរបស់បក្ស ហើយទោះជារយៈដំបូងខុសបន្តិចបន្តួចក្តី តែយូរៗទៅក៏ចេះតែខុស ច្រើនឡើងៗ ។ ឧបមាៈ ជ្រើសរើសសមាសភាពដឹកនាំនៅក្នុងសហករណ៍មួយ បើអ្នកមានជំហរបដិវត្តន៍សង្គមនិយមមិនល្អទេ អ្នកនេះឯងទៅពង្រីកអ្នកថ្មីទៀត ក៏បានអ្នកជំហរមិនល្អទៀត ហើយបើចេះតែពង្រីកតៗទៅទៀត យ៉ាងនេះ គ្រោះថ្នាក់ជាបន្តបន្ទាប់ដល់បដិវត្តន៍សង្គមនិយម ។

ដូច្នេះ គឺត្រូវយកចិត្តទុកដាក់ខាងចាត់តាំង ដោយឈរលើមាគ៌ាចាត់តាំងរបស់បក្ស ។ សមាសភាពដែលមិនល្អ គឺត្រូវកសាងសមាសភាពដែលកសាងហើយ មិនកែប្រែត្រូវផ្លាស់ប្តូរសម្រិតសម្រាំង ដើម្បីធ្វើឲ្យស្នូលដឹកនាំរបស់យើងស្អាតបរិសុទ្ធ បើស្នូលស្អាតបរិសុទ្ធហើយ គេដឹកនាំ តស៊ូក៏បរិសុទ្ធដែរ ។ នេះគឺសុំបញ្ជាក់អំពីកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយម គឺយ៉ាងនេះ ។ បញ្ហានេះ ជាអាយុជីវិតនៃបក្សបដិវត្តន៍យើង អាយុជីវិតក្នុងពេលចំពោះមុខនេះ និងអាយុជីវិតទៅអនាគតទៀត រាប់ជំនាន់ទៀត ។ បើមិនរៀបចំបញ្ហានេះ ឲ្យស្រួលតាំងពីបច្ចុប្បន្ននេះទេ ថ្ងៃក្រោយវាទៅសើរើ

វិញ ទៅមូលធននិយមវិញ ទៅឯកជនវិញទៅនាយទុនវិញ ចង់យើងនិយាយថា ទៅសង្គមនិយមយ៉ាងម៉េចក៏ដោយ មុខជាទៅឯកជនវិញមិនខានឡើយ បើយើងមិនរៀបចំ អ្នកទទួលកាន់កាប់សង្គមនិយមឲ្យរឹងមាំ ។ ឯអ្នកកាន់កាប់សង្គមនិយមនេះ មិនមែនគ្រាន់តែនៅថ្នាក់ខាងលើទេ គឺនៅគ្រប់ថ្នាក់ ពីព្រោះ នៅក្នុងមជ្ឈិមបក្ស មិនអាចជ្រើសរើសបក្ខជនបានច្រើនប៉ុន្មានទេ ជ្រើសរើសបាន៤-១០នាក់ នៅក្នុងអង្គភាពជុំវិញខ្លួនប៉ុណ្ណោះ ។ នៅក្នុងអង្គភាពជុំវិញខ្លួន ឯជ្រើសរើសបានច្រើនពាសពេញ គឺនៅក្នុងតំបន់ស្រុក សហករណ៍ អនុសេនាធំរបស់កងទ័ព ដែលពង្រីកអង្គការស្នូលដែលពង្រីកបក្ខជនបានច្រើន ហើយបើអ្នកអស់ទាំងនេះរឹងប៉ឹងគឺពង្រីកមាគ៌ាវណ្ណៈរបស់បក្ស ទៅតាមមាគ៌ាចាត់តាំងរបស់ បក្ស ។ តែបើអ្នកនេះមិនល្អគឺពង្រីកខុសពីមាគ៌ាចាត់តាំងរបស់បក្ស ហើយបើបេះតែពង្រីកមួយឆ្នាំបន្តិចៗ យូរឆ្នាំទៅ កម្លាំងមិនល្អកាន់តែច្រើនឡើងៗ ដូច្នេះបង្កើតបរិយាកាសខុសអំពីមាគ៌ារបស់បក្សតែម្តង ត្រង់នេះហើយដែលយើងត្រូវប្រុងប្រយ័ត្ន ។ បើយើងផ្អែកលើវណ្ណៈក្រីក្រ ផ្អែកលើកសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោម យើងមិនចង់ឲ្យរដ្ឋអំណាចរបស់កសិករក្រ និងកណ្តាលថ្នាក់ក្រោម ធ្លាក់ក្នុងកណ្តាប់ដៃអ្នកដទៃទៀត យើងត្រូវរៀបចំអ្នកកាន់អំណាចតាំងពីឥឡូវនេះទៅ ។ អ្នកកាន់អំណាច តាំងពីក្នុងផ្ទះបាយក្នុងក្រោលគោ ក្នុងពេទ្យ ក្នុងការអប់រំ ក្នុងមណ្ឌលកុមារ ទារក និងគ្រប់សមរភូមិ អ្វីផ្សេងៗទាំងអស់ ទោះជាយុទ្ធជន យុទ្ធនារីក្តីគឺត្រូវឲ្យមានជំហររឹងមាំ ទើបបដិវត្តន៍សង្គមនិយមវា ខ្លាំងក្លាជាបន្តបន្ទាប់ ហើយធានាអះអាងបាន ។ នេះហៅថា ការតស៊ូវណ្ណៈក្នុងគោលជំហររបស់យើង បើយើងអនុគ្រោះ បានន័យថា ជំហររបស់យើងមិនរឹង ខាងជំហរវណ្ណៈអធនរបស់បក្ស ។ បើយើងបណ្តែតបណ្តោយ មិនខំកសាងជំហរវណ្ណៈអធនរបស់បក្សឲ្យជួយយើងក្នុងក្របខណ្ឌយើង ក្នុងអង្គភាពយើង គឺបានសេចក្តីថាយើងបណ្តែតបណ្តោយមិនខំកសាងជំហរវណ្ណៈអធនរបស់បក្សឲ្យជួយយើង ក្នុងក្របខណ្ឌយើង ក្នុងអង្គភាពយើង គឺបានសេចក្តីថាយើងបណ្តែតបណ្តោយ បើកទ្វារ ប្តូបង្ហើបទ្វារឲ្យវណ្ណៈដទៃទៀតចូល ដូច្នេះ គ្រប់ពេលវេលាត្រូវខ្ទប់ទារឲ្យជាប់ ត្រូវប្រុងប្រយ័ត្នបដិវត្តន៍ឲ្យជាប់ ។ បើគ្រប់កន្លែងប្រុងប្រយ័ត្នបដិវត្តន៍ជាប់ ជ្រើសរើសយកតែវណ្ណៈមូលដ្ឋាន តាមមាគ៌ាចាត់តាំងរបស់បក្សនោះភាគច្រើនច្បាស់ជាល្អ ។ ក៏ប៉ុន្តែបើកន្លែងជាច្រើន បេះតែបង្ហើបទ្វារអ្នកណាក៏ចូល អ្នកណាក៏ចូលនោះគ្រោះថ្នាក់ធំណាស់ ។ ឃើញយ៉ាងនេះ ដើម្បីឃើញថាខ្មាំង វាមិនមែនវាយ យើងខាងសង្គ្រាមឈ្នះទេ តែវាវាយយើងខាងគោលជំហរវណ្ណៈ ។

## បញ្ហា៣តោន និង៦តោន តាមផែនការ៧៦ និងផែនការចុង៧៧



កម្មាភិបាលខ្មែរក្រហមរៀបចំដំឡើងម៉ាស៊ីនបូមទឹកបញ្ចូលស្រែ

មូលហេតុដែលភាគសម្រេច៣តោន និង៦តោន បានមានមូលហេតុច្រើនៗ ប៉ុន្តែក្នុងមូលហេតុច្រើននេះ មានមូលហេតុមួយជាគន្លឹះ គឺភូមិភាគបានដោះស្រាយនូវសមាសភាពកម្មាភិបាលគ្រប់ថ្នាក់ គឺសម្អាតនៅក្នុងភាគ សម្អាតនៅក្នុងតំបន់ សម្អាតនៅក្នុងស្រុក សម្អាតនៅក្នុងសហករណ៍ សម្អាតនៅក្នុងមន្ទីរ ក្រសួងនីមួយៗគ្រប់ផ្នែក ។ យើងសម្អាតបានប៉ុណ្ណឹង យើងសម្រេចតាមផែនការបានន័យថា ជួរបដិវត្តន៍របស់យើងបានស្អាតជាបន្តូរ បានជាយើងសម្រេចផែនការ ។ ប្រជាជនមហាជនសស្រោកសស្រាំយ៉ាងខ្លាំងក្លា ក្នុងការអនុវត្តមាគ៌ារបស់បក្ស ។ បើគ្មានស្នូលជំរុញ និងដឹកនាំ

*ចលនានេះទេ យើងមិនបានសម្រេច៣តោន និង៦តោនទេ ។*

*ឈរនៅលើពិសោធនេះ ក្នុងឆ្នាំ១៩៧៨នេះ គឺត្រូវតែសម្រេចឲ្យបាន៣តោនកន្លះ និង៧តោន យើងសម្រេច៣តោនកន្លះ និង៧តោន អាស្រ័យមកពីអ្វី? គឺអាស្រ័យមកពីទឹក ដី ពូជដី កម្លាំងពលកម្មរបស់មនុស្ស កម្លាំងពលកម្មរបស់សត្វ ។ ប៉ុន្តែ កត្តាគន្លឹះនៅតែកត្តាមនុស្ស គឺបក្សដឹកនាំ គឺភាគកាន់តែខ្លាំង តំបន់កាន់តែខ្លាំង ស្រុកកាន់តែខ្លាំង សហករណ៍កាន់តែខ្លាំង ក្នុងសហករណ៍មួយៗ មុខព្រួញមួយៗ កាន់តែខ្លាំង មុខព្រួញដីកាន់តែខ្លាំង មុខព្រួញសាប ស្ទូងកាន់តែខ្លាំង បានសេចក្តីថា ដឹកនាំគ្រប់ផ្នែកកាន់តែខ្លាំងទាំងអស់ ហើយចង់ឲ្យខ្លាំងយ៉ាងនេះ ទាល់តែមានស្នូលល្អ បានទៅរួច ។*

*ដូច្នោះ ភារកិច្ចរបស់យើងដើម្បីនឹងពិនិត្យកសាងសង្គមឲ្យកាន់តែខ្លាំង ជាងឆ្នាំ១៩៧៧នេះ ថែមទៀត គឺនៅក្នុងឆ្នាំ១៩៧៨នេះ ត្រូវយកចិត្តទុកដាក់អនុវត្តពិសោធឆ្នាំ១៩៧៧ កន្លងមកនេះ គឺ គិតគូរគ្រប់ផ្នែក ប៉ុន្តែយកចិត្តទុកដាក់ជាគន្លឹះ គឺបញ្ហាមនុស្ស មនុស្សនេះបានសេចក្តីថា បក្សគ្រប់ថ្នាក់ ហើយនិងសហករណ៍ ហើយនិងស្នូលគ្រប់មុខព្រួញ ។ ដូច្នេះ យើងត្រូវយកចិត្តទុកដាក់ឲ្យខ្លាំងក្លា ខំកសាងបក្សដឹកនាំ ឲ្យបានច្រើន ឲ្យបានល្អ ពីព្រោះក្នុងសហករណ៍នីមួយៗ នៅក្នុងភូមិភាគនេះគឺសមាជិកពេញសិទ្ធិគឺមានចំនួនច្រើន សមាជិកត្រៀមក៏មានចំនួនល្មម ហើយមានគុណភាពខ្លាំងក្លាគួរសម អាចជ្រើសរើស ធ្វើជាស្នូលបានច្រើននៅក្នុងសហករណ៍ ។*

*ម្យ៉ាងទៀត ខ្ញុំសុំស្នើថា ក្នុងសហករណ៍មួយៗ ត្រូវរៀបចំជាប្រព័ន្ធចាត់តាំងគ្រប់ផ្នែក ឲ្យកាន់តែល្អឡើង ជាស្រែ ជាដំណាំដាំដុះផ្សេងៗ សិប្បកម្ម សិប្បកម្មដែក សិប្បកម្មតម្បាញ មន្ទីរពេទ្យ កន្លែងធ្វើថ្នាំពេទ្យ កន្លែងចិញ្ចឹមទារក កន្លែងចិញ្ចឹមកុមារ ។ យើងត្រូវរៀបចំឲ្យកាន់តែសមរម្យឡើង ។ បញ្ហានេះបក្សបានណែនាំជាបន្តបន្ទាប់ហើយ ពិសេសនៅពាក់កណ្តាលឆ្នាំ១៩៧៧នេះ ធ្វើយ៉ាងម៉េចឲ្យសហករណ៍របស់យើង ដែលជាអង្គភាពមូលដ្ឋានមួយ មានគ្រប់ផ្នែក សេដ្ឋកិច្ចក៏មាននយោបាយក៏មាន សិក្សាក៏មាន សុខាភិបាលក៏មាន កសិកម្មក៏មាន សិប្បកម្មក៏មាន រហូតដល់ឡូតដូឡក្បឿងក៏មាន ។ យើងត្រូវរៀបចំឲ្យស្រួល ឲ្យកាន់តែល្អថែមទៀត ដើម្បីឲ្យសហករណ៍មួយៗ ទៅជាអង្គភាពពេញលេញ មានអ្វីៗទាំងអស់ ។*

## មតិបញ្ជាក់លើភារកិច្ចនយោបាយរបស់ភូមិភាគ និងផែនការឆ្នាំ១៩៧៨

***អំពីភារកិច្ចរួម*** ៖ *គឺមានភារកិច្ចការពារភូមិភាគ មានភារកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយម មានភារកិច្ចកសាងសង្គមនិយម មានភារកិច្ចស្នូល៣ ហើយមានភារកិច្ចកសាងកម្លាំងគ្រប់ផ្នែក ដូចជាកសាងកម្លាំងបក្ស កសាងកម្លាំងប្រជាជន កសាងកម្លាំងរដ្ឋអំណាចបដិវត្តន៍ ទប់ទល់ចារកម្ម ។ ដូច្នេះ ក្នុងភារកិច្ចនយោបាយរួមរបស់យើង មានច្រើនបញ្ហាណាស់ បើមានច្រើនបញ្ហាយ៉ាងនេះ តាមការពិសោធកន្លងមក យើងតែងក្តាប់មិនជាប់ ។*

*ដូច្នេះ បានជាសុំលើកបញ្ជាក់ថែមទៀត អំពីភារកិច្ចនយោបាយរួមនេះ ។ ភារកិច្ចនយោបាយរួមនេះ យើងធ្លាប់ធ្វើមកហើយ កាលពីឆ្នាំ១៩៧៧ ។ ប៉ុន្តែ ឆ្នាំ១៩៧៨ យើងលើកមកទៀត មានបញ្ហាច្រើនទៀត តើក្នុងសភាពច្រើនយ៉ាងនេះ យើងត្រូវក្តាប់យ៉ាងម៉េច? គឺភារកិច្ចនយោបាយរួមនេះជាទិស លំនាំជាមាគ៌ា ដែលយើងត្រូវដើរក្នុងឆ្នាំ១៩៧៨ ។ ជាមាគ៌ារបស់បក្សទាំងមូល ដែលភូមិភាគត្រូវដើរ គឺត្រូវដើរតាមភារកិច្ច នយោបាយរួម ការពារភូមិភាគយ៉ាងម៉េច បន្តធ្វើបដិវត្តន៍សង្គម និយមយ៉ាងម៉េច នៅក្នុងភូមិភាគ កសាងសង្គមនិយមយ៉ាងម៉េច នៅក្នុងភូមិភាគ ហើយទាំងអស់នេះ មានភារកិច្ចស្នូលយ៉ាងម៉េច កសាងរដ្ឋអំណាចបដិវត្តន៍យ៉ាងម៉េច គឺត្រូវដំណើរការក្នុងឆ្នាំ១៩៧៨ យ៉ាងនេះ ។ និយាយឲ្យខ្លី គឺជាមាគ៌ារបស់បក្សសម្រាប់ឆ្នាំ១៩៧៨ របស់ភូមិភាគ ។ ដូច្នេះ ខ្ញុំយល់ឃើញថា យើងត្រូវក្តាប់ភារកិច្ចទាំងអស់នេះ ។ បើយើងមិនក្តាប់ ក៏យើងមិនដឹងទិសក្នុងឆ្នាំ១៩៧៨ នេះ ។ ប៉ុន្តែ ក្តាប់នេះ គឺក្តាប់តាមថ្នាក់ ឧបមា ថ្នាក់តំបន់ត្រូវក្តាប់ឲ្យជាប់ទាំងមូល ក៏ប៉ុន្តែក្នុងក្របខណ្ឌតំបន់ ។ ថ្នាក់ស្រុកក៏ត្រូវក្តាប់ទាំងមូល ក៏ប៉ុន្តែ ក្នុងក្របខណ្ឌស្រុក ។ សហករណ៍ក៏ត្រូវក្តាប់ទាំងមូល ក៏ប៉ុន្តែ ក្នុងក្របខណ្ឌសហករណ៍ ។ ក៏ប៉ុន្តែ ទាំងអស់គ្នាត្រូវដើរតាមមាគ៌ានេះ ។ ខ្ញុំយល់ឃើញថា ក្នុងការក្តាប់ភារកិច្ចរួមគ្រប់ផ្នែក ជាបញ្ហាលំបាកមួយដែរ ។ ជាពិសោធផ្ទាល់ ក៏ដូច្នេះ ។ ជាពិសោធ សមមិត្តផ្សេងទៀត ក៏ដូច្នេះ ហើយក្នុងការយកទៅអនុវត្ត ជួនភ្លេចឯលិច ភ្លេចឯកើត ។ នេះជាពិសោធ ប៉ុន្តែ បើភ្លេចយើងមិនធ្វើ គឺដំណើរ*

ការមិនបានល្អ ដូច្នេះ តើយើងត្រូវធ្វើយ៉ាងម៉េច? ខ្ញុំ យល់ឃើញថា ភារកិច្ចនយោបាយរួម ដែលភូមិភាគលើកឡើងក្នុងឆ្នាំ១៩៧៨នេះ ស្របទៅតាមសភាពការណ៍របស់ភូមិភាគ ស្របទៅតាមសភាពការណ៍របស់តំបន់ស្រុក សហករណ៍ ហើយស្របទៅតាមសភាពការណ៍ទូទាំងប្រទេស ។ ឯកសារនេះ ត្រឹមត្រូវជាមូលដ្ឋានដែលយកទៅអនុវត្តបានពេញទីនៅក្នុងភាគ នៅក្នុងតំបន់ នៅក្នុងស្រុក នៅក្នុងសហករណ៍ ។ តាមលំនាំ នេះក្នុង “ខ” ស្ដីអំពីភារកិច្ចនយោបាយរួមនេះ មិនមានអ្វីស្នើបន្ថែមទេ ព្រោះត្រឹមត្រូវជាមូលដ្ឋានហើយ ។ ស្នើសមមិត្តតំបន់ក្ដាប់បញ្ហានេះឲ្យច្រើនជាងគេ គឺ១ ក្ដាប់ជាភារកិច្ច ទី២ ត្រូវមានឯកសារ ជាប់ខស្សព្រាហ៍មើល ដើម្បីរំឭកវា គឺភារកិច្ចនយោបាយរួម ជាលេខាតំបន់ ជាសមាជិកតំបន់ ក៏ត្រូវក្ដាប់បញ្ហារួមនេះឲ្យជាប់ ពីព្រោះជាអ្នកចាត់ចែងការងារគ្រប់មុខ មិនមែនធ្វើការងារតែមួយមុខៗទេ ។ ការចាត់ចែងការងារជាបញ្ហារួម ។ យើងធ្លាប់ធ្វើហើយ យើងបានចាំខ្លះហើយ ដូច្នោះ ខំចាំទៀត សម្រាប់ជាទិសឆ្នាំ១៩៧៨នេះ ។ ទី៣ គឺខស្សព្រាហ៍ប្រជុំនៅក្នុងតំបន់របស់ខ្លួន ។ ក្នុងការប្រជុំ គឺយកតាមឯកសារនេះពិនិត្យមើល តើកិច្ចការពារដល់ណាហើយ? ធ្វើបដិវត្តន៍សង្គមនិយមដល់ណា ហើយកសាងសង្គមនិយមដល់ណាហើយ? ភារកិច្ចស្នូលដល់ណាហើយ? កសាងបក្សដល់ណាហើយ? កសាងកម្លាំងប្រជាជនដល់ណាហើយ ។ យើងខស្សព្រាហ៍មើលខស្សព្រាហ៍ពិនិត្យការងារ ខស្សព្រាហ៍ដកពិសោធ ។ បើយើងធ្វើអ៊ីចឹងបាន យើងមិនភ្លេច វាមិនឃ្លាង គឺយើងរំឭកការងារគ្រប់ផ្នែកនេះបានទាំងអស់ ។ សូមជម្រាបថា សមមិត្តនៅក្នុងតំបន់ ត្រូវយកចិត្តទុកដាក់ក្ដាប់ជាងគេ បន្ទាប់មកសមមិត្តស្រុក ។ ឯសមមិត្តនៅក្នុងសហករណ៍ក៏ត្រូវតែក្ដាប់ក្នុងក្របខណ្ឌសហករណ៍របស់ខ្លួនដែរ ។ ឯលំនាំនៃដំណើរការ គឺដូចគ្នា គឺក្ដាប់ដោយជាប្រចាំ ក្ដាប់ជារំឭកឯកសារយកមកមើល ក្ដាប់ដោយយកឯកសារនេះ មកពិភាក្សាជាមួយគ្នា ដកពិសោធជាមួយគ្នា ដើម្បីតាមដានការងារនៅក្នុងសហករណ៍ឲ្យបានគ្រប់ជ្រុងជ្រោយ ទាន់ពេលវេលា ដើម្បីកុំឃើញតែមួយមុខៗ គឺត្រូវឃើញច្រើនមុខ កុំឲ្យឃើញតែវាយខ្លាំង ហើយមិនបានកសាង សង្គមនិយម ឬកសាងសង្គមនិយម មិនបានធ្វើបដិវត្តន៍សង្គមនិយម ។

បញ្ហាមួយទៀតដែលសុំបញ្ជាក់ គឺក្នុងភារកិច្ចនយោបាយរួម ត្រូវចាំអ្វីជាគន្លឹះ ត្រូវយកអ្វីជាគន្លឹះ ។ បើប្រសិនណាភ្លេចអ្វីល្អម តូចតាច អាចភ្លេចបាន ធ្វើវាមិនបានហ្មត់ចត់ ក៏អាចអនុគ្រោះបាន ។ តែមានបញ្ហាខ្លះត្រូវធ្វើដាច់ខាត ហើយជាគន្លឹះ បើធ្វើបានគឺដោះស្រាយបញ្ហាដទៃទៀត ។ តើភារកិច្ចនេះជាភារកិច្ចអ្វី ហើយជាការងារអ្វី?

យើងបានដកពិសោធក្នុងការពិនិត្យការងារក្នុងឆ្នាំ១៩៧៧ ហើយក្នុងការខទ្ទេសនាមភារកិច្ចរួមនេះ បក្សភូមិភាគក៏បានបញ្ជាក់ជាភារកិច្ចរួម ៣យ៉ាង ប៉ុន្តែក្នុងនេះ មានភារកិច្ចស្នូល៣ ។ ខ្ញុំយល់ថា ក្នុង៣នេះ មានអ្វីមួយដែលជាស្នូលជាងគេទៀត ។ និយាយរួមភារកិច្ចទាំងអស់នេះ វាមានស្នូល ប៉ុន្តែស្នូលនោះ មានមួយជាស្នូលជាងគេ គន្លឹះជាងគេ ដែលត្រូវយកចិត្តទុកដាក់មែនទែន ស្នូលជាងគេនេះ គឺ បញ្ហាកសាងកម្មាភិបាល ត្រូវក្ដាប់បញ្ហានេះឲ្យជាប់ ។ ក្ដាប់បញ្ហានេះបានជាប់ ទើបក្ដាប់ចំណងបញ្ហាទាំងអស់បានជាប់ ឯបញ្ហាទាំងអស់វាជាប់មកចំណងនេះ ។ ឯចំណងនេះ វាបន្តកិច្ចការផ្សេងៗទាំងអស់ បើក្ដាប់បញ្ហានេះបាន ដោះស្រាយបញ្ហានេះបាន បានសម្រេចបញ្ហាដទៃទៀតបាន ។ បញ្ហាការពារបញ្ហាកសាងសង្គមនិយម បញ្ហាធ្វើបដិវត្តន៍សង្គមនិយម បញ្ហាកសាងបក្ស បញ្ហាកសាងកម្លាំងប្រជាជន បញ្ហា ៣គោនកន្លះ និង៧គោនទាំងអស់នេះសម្រេចបានលើកម្មាភិបាល ។

ក្នុងភារកិច្ចវាស្មុគស្មាញស្មេកស្មុះក៏ពិតមែន តែត្រូវក្ដាប់បញ្ហាកម្មាភិបាលនេះឲ្យជាប់ ។ បើក្ដាប់បញ្ហាកម្មាភិបាលជាប់ហើយ គឺក្ដាប់បញ្ហាទាំងអស់ ហើយដោះស្រាយបញ្ហាទាំងអស់នេះបាន ទោះជា មានបញ្ហានេះស្មុគស្មាញបន្តិចបន្តួច មានបញ្ហានេះខ្វះខាតខ្លះ ប៉ុន្តែបើមានកម្មាភិបាល យើងក្ដាប់កម្មាភិបាល កសាងពង្រីងពង្រីកកម្មាភិបាល សម្រិតសម្រាំងកម្មាភិបាលបានល្អហើយ នោះភារកិច្ចរួមក៏ អនុវត្តបានល្អ ផែនការឆ្នាំ១៩៧៨ ក៏អនុវត្តបានល្អ ។

តើបញ្ហាកម្មាភិបាលនេះជាអ្វី បើនិយាយនៅក្នុងក្របខណ្ឌភូមិភាគ គឺកម្មាភិបាលភាគ កម្មាភិបាលតំបន់ កម្មាភិបាលស្រុក កម្មាភិបាលសហករណ៍ កម្មាភិបាលទ័ពគ្រប់ថ្នាក់ កម្មាភិបាលតាំងមុខព្រួញនីមួយៗ កម្មាភិបាលមន្ទីរ កម្មាភិបាលក្រសួង ។ នេះតាមថ្នាក់ដែលត្រូវក្ដាប់ ប៉ុន្តែ បើនិយាយឲ្យច្បាស់ថែមទៀត គឺមានតែ

កសាងបក្ខជនឲ្យល្អ ទាំងចាស់ ទាំងថ្មីទេ គឺថាកសាងបក្ខជនឲ្យល្អ ទាំងចាស់ ទាំងថ្មី ហើយកសាងជនចម្រើនឲ្យបានល្អ ទាំងចាស់ ទាំងថ្មី ប្រភេទបីនេះ ហៅថា ជាកម្មាភិបាលហើយ ជាកម្មាភិបាលរបស់បក្ស នៅក្នុងបក្ស ជាកម្មាភិបាលរបស់បក្សនៅក្រៅបក្ស ជនចម្រើនក៏ជាកម្មាភិបាលរបស់បក្ស ក៏ប៉ុន្តែ នៅក្រៅបក្ស ព្រោះមិនទាន់ចូលបក្ស ។ បើកសាងបក្ខជនល្អហើយ កសាងអង្គការស្នូលល្អហើយ កសាងជនចម្រើនល្អហើយ គឺយើងសម្រេចការងារបានទាំងអស់ ការពារ ក៏ល្អ កសាងសង្គមនិយមក៏ល្អ បដិវត្តន៍សង្គមនិយមក៏ល្អ កសាងកម្លាំងប្រជាជនក៏ល្អ ៣គោនកន្លះ និង ៧គោនក៏ល្អ ដីក៏ល្អ ទឹកក៏ល្អ នេះហៅថា ជាការងារស្នូល ជាគន្លឹះជាងគេ ជាសំខាន់ជាងគេ ។ បើក្តាប់បញ្ហានេះបាន បញ្ហាដទៃទៀត អត់មានអ្វីលំបាកទេ ពីព្រោះយើងមានកម្មាភិបាលហើយ ។ ប៉ុន្តែ បើគ្មានកម្មាភិបាល ឬក្តាប់កម្មាភិបាលមិនបាន នោះនឹងស្មុគស្មាញទាំងការពារ ទាំងកសាងសង្គមនិយម ទាំងធ្វើបដិវត្តន៍សង្គមនិយម ស្មុគស្មាញទាំង ៣គោនកន្លះ និង៧គោន ស្មុគស្មាញទាំងជីវភាពរបស់ប្រជាជន ។ បើកម្មាភិបាលដែលយើងមានសព្វថ្ងៃនេះ បើយើងមិនក្តាប់ឲ្យជាប់ យើងមិនកសាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង មិនសម្រិតសម្រាំង មិនពង្រឹងពង្រីកឲ្យបានហ្មត់ចត់ទេ កម្មាភិបាលដែលមាន ហើយក៏មិនខ្លាំង ប៉ុន្តែ បើយើងក្តាប់ជាប់ទាំងនយោបាយ ទាំងសតិអារម្មណ៍ ថែបំប៉នគេទាំង នយោបាយ ទាំងចាត់តាំងនោះ គេមុខជាខ្លាំងហើយ ។ កម្លាំងសព្វថ្ងៃដែលមាន១០ វាខ្លាំងហើយ បើថែមទៀតជា ១១-១២-២០ នោះរឹតតែខ្លាំងថែមទៀតបំពេញភារកិច្ចបច្ចេកទេសផ្សេងៗទៀត បានទាំងអស់ ដូច្នេះ ស្នើយកចិត្តទុកដាក់កសាងកម្មាភិបាលឲ្យខ្លាំងក្លា និងជាប់ជានិច្ច ពិសោធនេះច្បាស់ហើយ សមមិត្តពិនិត្យខ្លួនឯងក៏ច្បាស់ដែរ ។ តាមសហករណ៍មួយៗ តាមស្រុកមួយៗ ក៏ឃើញច្បាស់ដែរ ទូទាំងប្រទេសក៏ឃើញច្បាស់ដែរ ។ ភូមិភាគណាដែលមានកម្មាភិបាលល្អ ខ្លាំងច្រើន គឺអនុវត្តផែនការទូទាំងប្រទេសបានល្អ ។ ភូមិភាគណា កម្មាភិបាលនៅរយីករយាក គឺអនុវត្តផែនការនៅរយីករយាក មិនសម្រេចផែនការ ។ នេះជាពិសោធ នេះជាជាក់ស្តែង ហើយពិសោធនេះ វាទៅជាលក្ខការណ៍ហើយ វាទៅជាមាគ៌ាដឹកនាំបដិវត្តន៍ហើយជាមាគ៌ាដឹកនាំទូទាំងប្រទេសក៏អ៊ីចឹង ភូមិភាគមួយក៏អ៊ីចឹង ក្នុងកងផលិតមួយក៏អ៊ីចឹង ។ ដូច្នោះ បញ្ហាកសាងកម្មាភិបាល ជាបញ្ហាគន្លឹះសំខាន់ ។

**អំពីផែនការឆ្នាំ១៩៧៨ :** ផែនការឆ្នាំ១៩៧៨ ជាផ្នែកការងាររណបភារកិច្ចរួម ។ បើសម្រេចភារកិច្ចនយោបាយរួមតាមបញ្ហាជាគន្លឹះ ដែលបានសម្រេចអម្បាញ់មិញនេះហើយ គឺអនុវត្តផែនការនេះ បានជាមូលដ្ឋានហើយ ព្រោះផែនការជាតួលេខល្អិត ដីប៉ុន្មាន ដីធ្វើម្តងប៉ុន្មាន ធ្វើពីរដងប៉ុន្មាន ផ្លូវគ្រាន់តែរៀបចំយ៉ាងម៉េចឲ្យវាសមស្របតែប៉ុណ្ណឹងទេ ។ នេះជាតួលេខ គឺជាការងារល្អិតដើម្បីអនុវត្ត ។

និយាយរួមផែនការនេះ បានលើកគ្រប់ផ្នែកទាំងអស់ផ្នែកអ្វីក៏លើកដែរ នាំឲ្យយើងមានទស្សនៈកសាងសង្គមនិយមនៅក្នុងភូមិភាគនេះបានគ្រប់មុខ ។ នេះជាចំណុចល្អ នាំឲ្យយើងមានទស្សនៈនាំឲ្យយើងគិតគូរការងារបានគ្រប់ផ្នែក ហើយឲ្យយើងខិតខំធ្វើឲ្យបានគ្រប់ផ្នែកនេះ នាំឲ្យការកសាងសង្គមនិយមបានរីកចម្រើននៅក្នុងភូមិភាគនេះឆាប់រហ័ស ។

ម្យ៉ាងទៀត តួលេខនៃផែនការរបស់ភាគ ដែលចែងនៅក្នុងតារាងទាំងអស់នេះ គឺជាតួលេខស្ថិតនៅក្នុងសភាពងាយសម្រុកបានន័យថា តួលេខយើងដាក់ឲ្យខ្លាំងជាប់ ឲ្យខ្លាំងដើម្បីជំរុញឲ្យវាលឿនដូច្នេះ ជាទស្សនៈដឹកនាំជាគុណសម្បត្តិ ហៅថា ខំប្រយុទ្ធឲ្យបានច្រើនឲ្យបានខ្លាំង យើងសម្រុកឲ្យបាន ច្រើនជាងឆ្នាំ១៩៧៧ ។

ខ្ញុំយល់ឃើញថា លក្ខណសម្បត្តិរបស់ភូមិភាគបស្ចិមឆ្នាំ ១៩៧៧ យើងសម្រេចផែនការ ៣គោន និង ៦គោន បាន៨០ និង៩០ភាគរយ ។ ឆ្នាំ១៩៧៨ លក្ខណសម្បត្តិល្អជាងឆ្នាំ១៩៧៧ ច្រើន ល្អនេះក្នុងន័យកម្មាភិបាល ។ កម្មាភិបាលល្អ ខាងនយោបាយ ខាងសតិអារម្មណ៍ ខាងចាត់តាំង ហើយមានពិសោធក្នុងបញ្ហាដឹកនាំក្នុងបញ្ហាបច្ចេកទេសអនុវត្តផែនការកសាងសង្គមនិយមនៅក្នុងសហករណ៍ នៅក្នុងស្រុក នៅក្នុងតំបន់មួយជាពីរ ជាបី ខ្លាំងជាងឆ្នាំ១៩៧៧ ។ បើរៀបចំផែនការនេះ ឲ្យសមស្របតាមកម្លាំងរបស់ខ្លួនច្បាស់ជាសម្រេចបាន អ្វីអាចបន្ថយ អ្វីអាចបន្ថែម ឲ្យសមស្របតាមកម្លាំង គឺទៅរួចហើយ ពិសេស កម្មាភិបាលជាស្នូលសម្រាប់ដឹកនាំ ។

**ឆាង សារៈមុនិន្ទ**

# ពេញមួយរបបក្នុងភេទចល័ត

ក្នុងវ័យ ៥៥ឆ្នាំ សូរ សុភ័ក្ត្រ បានធ្វើដំណើរពីខេត្តតាកែវ មកកាន់តុលាការខ្មែរក្រហម ដើម្បីចូលរួមស្តាប់សវនាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ នេះគឺជាលើកទីមួយហើយសម្រាប់ សុភ័ក្ត្រ ដែលបានចូលរួមសវនាការ និងឃើញជនជាប់ចោទដោយផ្ទាល់ ។ សុភ័ក្ត្រ បានបង្ហាញពីការជឿជាក់ចំពោះតុលាការនេះថានឹងអាចជួយរកយុត្តិធម៌ជូនដល់ជនរងគ្រោះទាំងអស់ ក៏ដូចជារូបគាត់ ។

ក្រឡេកមើលអ្នកចូលនៅជុំវិញខ្លួនដែលកំពុងបរិភោគអាហារថ្ងៃត្រង់ ក្រោយពេលតុលាការឈប់សម្រាក បានធ្វើឲ្យ សុភ័ក្ត្រ នឹកឃើញឡើងវិញពីអតីតកាលរបស់គាត់មុនពេលរបបខ្មែរក្រហមចូលមកគ្រប់គ្រង ។ គាត់នឹកឃើញការហូបចុក ការជួបជុំគ្រួសារ និងគ្រួសារបងប្រុសរបស់គាត់ ដែលមានសមាជិកទាំងអស់ប្រាំនាក់ ដែលក្រោយមកបានស្លាប់ដោយសារអត់អាហារ ។

សុភ័ក្ត្រ បានរៀបរាប់ គាត់ជាកូនពៅក្នុងចំណោមបងប្អូនប្រុសស្រី ប្រាំពីរនាក់ ដែលមានគ្រួសារជាកសិករមួយ នៅខេត្តតាកែវ ។ គាត់រៀនបានត្រឹមថ្នាក់ទី៧ប៉ុណ្ណោះ នៅពេលរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ឆ្នាំ១៩៧០ ។ រីឯភូមិស្រុកដែលគាត់រស់នៅក៏ត្រូវខ្មែរក្រហមដណ្តើមកាន់កាប់បានតាំងពីពេលនោះដែរ ។ ខ្មែរក្រហមបានឃោសនាប្រជាជននៅក្នុងភូមិឲ្យចូលចលនាតស៊ូ និងច្បាំងជាមួយទាហាន លន់ នល់ ដើម្បីយកសម្តេចមកគ្រប់គ្រងប្រទេសវិញ ។ អ្នកភូមិជាច្រើនបានស្ម័គ្រចិត្តចូលរួមចលនានោះ ប៉ុន្តែសម្រាប់បងប្អូន សុភ័ក្ត្រ មិនមាននរណាម្នាក់ចូលរួមទេ ហើយខ្មែរក្រហមក៏មិនបានបង្ខំដែរ ។ សុភ័ក្ត្រ បន្តថា នៅពេលនោះមានអ្នកចូលរួមចលនាតស៊ូប្រឆាំង លន់ នល់ ភាគច្រើនបាន ស្លាប់ ។

ដំបូង ការរស់នៅក្រោមការគ្រប់គ្រងរបស់ ខ្មែរក្រហមមិនមានអ្វីលំបាកខ្លាំងទេ ព្រោះអ្នកភូមិអាចធ្វើស្រែ ដាំដំណាំ និងអាចហូបចុកឯកជន និងតាមគ្រួសារបាន ។ តែក្រោយថ្ងៃជ័យជម្នះ ១៧ មេសា



ទាវ សារៈមុនិន្ទ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា (រូបខាងឆ្វេង) និង សូ សុភ័ក្រ្ត ថតពេលសម្ភាសនៅសាលាក្តីខ្មែរក្រហម

ឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមបង្កើតសហករណ៍ ហើយដីស្រែ គោ ក្របី ត្រូវដាក់ជាទ្រព្យសម្បត្តិរបស់អង្គការ ឬសមូហភាព ។ ខ្មែរក្រហមចាប់ផ្តើមរិតត្បិតចំពោះប្រជាជនក្នុងភូមិដោយបាន ចាត់ចែងការងារឲ្យធ្វើ ចំណែកការហូបចុកអង្គការចាប់រឹតបណ្តឹង ដោយលែងឲ្យហូបជាឯកជន និងតាមគ្រួសារ ។ ចាស់ៗក្នុងភូមិ ដែលខ្សោយកម្លាំង ដូចជា ឪពុកម្តាយ សុភ័ក្ត្រ អង្គការចាត់តាំងឲ្យ ដាំបន្លែ ធ្វើបង្គី ឬមើលថែទាំក្មេងតូចៗ នៅក្នុងភូមិ ។ ចំណែកយុវជន ពេញកម្លាំងដូចគាត់ អង្គការចាត់តាំងទៅធ្វើការ នៅក្នុងកងចល័ត ។

ជាក់ស្តែង សុភ័ក្ត្រ បានបែកពីគ្រួសារចេញទៅធ្វើការតាម កងចល័តនៅគ្រប់តំបន់ ក្នុងខេត្តតាកែវ ។ គាត់ធ្វើការនៅកងចល័ត រហូតដល់កងទ័ពវៀតណាមចូលមករំដោះភ្នំពេញ នៅឆ្នាំ១៩៧៩ គឺពេញក្នុងមួយរបបខ្មែរក្រហមដែលគាត់មិនដែលបានត្រឡប់មកជួប ជុំឪពុកម្តាយ និងបងប្អូននៅក្នុងភូមិ ។ ការងារនៅកងចល័ត មិនថាជា អ្នកមូលដ្ឋាន ឬប្រជាជនថ្មីទេ គឺមានការលំបាកដូចគ្នា ជាពិសេស អាហារប្រចាំថ្ងៃ ។ អង្គការបានចែករបបអាហារឲ្យពីរពេលក្នុងមួយ ថ្ងៃ ហើយក្នុងមួយកងរយ អង្គការចែកអង្ករឲ្យតែបួនកំប៉ុងប៉ុណ្ណោះ ។ ដូច្នេះនៅពេលបើករបបម្តងៗ សុភ័ក្ត្រ ទទួលបានតែបបររាវពីរទៅ បីវែកប៉ុណ្ណោះក្នុងមួយពេល ។

ក្រៅពីការងារនៅក្នុងកងចល័ត សុភ័ក្ត្រ ត្រូវធ្វើការងារ ផ្សេងៗទៅតាមការស្នើ និងការចាត់តាំងរបស់អង្គការ ។ ប្រសិន បើការងារបន្ទាន់ ឬតម្រូវសម្រុកឲ្យគ្រប់ផែនការ កងចល័តទាំងអស់ ត្រូវងើបធ្វើការចាប់តាំងពីម៉ោងបី ឬម៉ោងបួនទៀបភ្លឺ រហូតដល់ ម៉ោង១១ ឬ១២ថ្ងៃត្រង់ ទើបបានសម្រាកហូបបបរ ។ រយៈមួយ ម៉ោងក្រោយ កងចល័តទាំងអស់ត្រូវចុះធ្វើបន្តរហូតដល់ម៉ោង៦ ល្ងាច ហើយពេលខ្លះដល់ម៉ោង១០ ឬ១១យប់ ទៀតផង ។ មនុស្ស ក្នុងកងចល័តជាច្រើនបានស្លាប់ ដោយសារតែជំងឺ ធ្វើការហួសកម្លាំង និងការចាប់យកទៅសម្លាប់ ។ ចំណែកអ្នកដែលឈឺច្រើន ហើយមិន បានទៅធ្វើការ ត្រូវអង្គការចោទប្រកាន់ថា កេងប្រវ័ញ្ចលើកម្លាំង ពលកម្មអ្នកដទៃ ហើយចុងក្រោយក៏ត្រូវយកទៅសម្លាប់ដែរ ។

សុភ័ក្ត្រ បានបន្តថា នៅពេលយប់ តែងតែមានកងឈ្លបមក ហៅមនុស្សយកទៅ ដោយប្រាប់ថា អង្គការហៅទៅរៀនសូត្រ ឬផ្លាស់ឲ្យទៅនៅកងថ្មី ប៉ុន្តែគាត់មិនដែលឃើញអ្នកទាំងនោះត្រឡប់ មកវិញនោះទេ ។ សុភ័ក្ត្រ បន្ថែមថា ពេលនោះគាត់មានសំណាង ព្រោះគាត់មិនត្រូវបានខ្មែរក្រហមធ្វើបាប ឬបង្ខំឲ្យធ្វើការហួសកម្លាំង និងបង្អត់អាហារ ។

ប៉ុន្តែមានរឿងមួយដែលនឹកស្មានមិនដល់ គឺនៅអំឡុងដើម ឆ្នាំ១៩៧៩ ពេល សុភ័ក្ត្រ កំពុងធ្វើការនៅកងចល័ត គាត់ឃើញ យោធាខ្មែរក្រហមរត់មកភូមិវិញទាំងយប់ជាមួយសភាពភ័យស្ងន់ ស្ញោ ។ គាត់បានសួរទៅកាន់យោធាខ្មែរក្រហមម្នាក់ថាមានរឿងអ្វី កើតឡើង? យោធានោះប្រាប់គាត់ថា កងទ័ពវៀតណាមបានឈ្លាន ពានចូលមកប្រទេសយើងហើយ ។

ភ្លឺឡើង សុភ័ក្ត្រ ទៅបានជួបប្រធានចុងភៅដែលមានកូនវិទ្យុ តូចមួយដែលបានបើកស្តាប់ឮថា ភ្នំពេញត្រូវបានរំដោះហើយ ។ ចំណែកសភាពការណ៍នៅកងចល័តក៏មានការប្រែប្រួលដែរ ដោយ ខ្មែរក្រហមប្រកាសរំសាយកងចល័ត រួចហើយកៀរអ្នកនៅកង ចល័តទាំងអស់ និងប្រជាជនឲ្យឡើងចូល ព្រៃនៅលើភ្នំដំរីរមៀល ដើម្បីត្រៀមតស៊ូច្បាំងជាមួយទ័ពវៀតណាម ។

ស្របពេលនោះ ខ្មែរក្រហមបានឃោសនាថា បើបងប្អូនហ៊ាន នៅភូមិទៀត ពេលកងទ័ពវៀតណាមមកដល់នឹងចាប់អារកសម្លាប់ ជាមិនខាន ។ ទោះបីយ៉ាងណា អ្នកដែលបដិសេធមិនព្រមទៅតាម ការឃោសនានេះ ត្រូវយោធាខ្មែរក្រហមសម្លាប់ចោលនៅពេល នោះតែម្តង ។ សុភ័ក្ត្រ មានការបារម្ភពេលធ្វើដំណើរជាមួយហ្វូង មនុស្សយ៉ាងច្រើននោះបែបនេះ ដូច្នេះគាត់បានលួចរត់គេចខ្លួនជា មួយប្រជាជនត្រឡប់ក្រោយមកផ្ទះវិញ ។ ប៉ុន្តែ មានប្រជាជនមួយ ត្រូវយោធាខ្មែរក្រហមចាប់បាន ហើយយកទៅសម្លាប់ចោល ។

សុភ័ក្ត្រ បានត្រឡប់មកដល់ភូមិ និងបានជួបជុំគ្រួសារលើក លែងតែគ្រួសារបងប្រុសដែលស្លាប់ដោយសារអត់អាហារ ។ ក្រុម គ្រួសារ សុភ័ក្ត្រ បន្តរស់នៅស្រុកកំណើតដោយប្រកបរបរធ្វើស្រែ ។ សុភ័ក្ត្រ បានរៀបការនៅឆ្នាំ១៩៨១ ។

របបខ្មែរក្រហមនៅតែធ្វើឲ្យ សុភ័ក្ត្រ មិនអាចបំភ្លេចបាននូវ ការលំបាកវេទនា និងបែកបាក់គ្រួសារ ។ សុភ័ក្ត្រ តែងតែនិយាយ ពីរបបខ្មែរក្រហមប្រាប់ដល់កូនចៅគាត់ ព្រោះគាត់គិតថា ការយល់ ដឹងពីខ្មែរក្រហមមានសារសំខាន់ណាស់ និងធ្វើយ៉ាងណាកុំឲ្យមានរបប នេះកើតឡើងម្តងទៀតនៅក្នុងប្រទេសកម្ពុជា ។ **ឆាង សារះមុនិន្ទ**

# គ្រូមន្តអាគមចាម និងសម័យខ្មែរក្រហម

ក្លាម ៗ បន្ទាប់ពីការសិក្សាស្រាវជ្រាវរបស់ខ្ញុំស្តីពីជនជាតិចាមម៉ូស្លីមកាលពីឆ្នាំមុន ខ្ញុំមានការភ្ញាក់ផ្អើលបន្តិចបន្តួចនៅពេលដែលខ្ញុំបានដឹងថា ជនជាតិចាមម៉ូស្លីមត្រូវបានជឿថាជាគ្រូមន្តអាគមដ៏ពូកែ ។ខ្ញុំបានសិក្សាអំពីអ៊ីស្លាមនៅមជ្ឈិមបូព៌ាមុនពេលដែលមកកាន់ប្រទេសកម្ពុជា ហើយទិដ្ឋភាពស្តីពីជនម៉ូស្លីមនៅទីនេះគឺជាទិដ្ឋភាពថ្មីសម្រាប់ខ្ញុំ ។ កាលនោះ ខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវស្តីពីឯកសារសម្ងាត់សរសេរជាភាសាអារ៉ាប់ ដែលត្រូវបានកប់ដោយជនជាតិចាម ដើម្បីការពារឯកសារទាំងនោះពីការបំផ្លិចបំផ្លាញរបស់ខ្មែរក្រហម ។ ខ្ញុំគិតថា ការសិក្សាស្រាវជ្រាវនេះអាចលាតត្រដាងដល់អ្នកអាននូវទិដ្ឋភាពនៃជីវិតរបស់បញ្ញវន្តជនជាតិចាមកាលគ្រានោះ ។

ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីបានបញ្ចប់ការសិក្សាស្រាវជ្រាវនេះ ខ្ញុំយល់ឃើញថា ខ្ញុំចង់ដឹងអំពីទិដ្ឋភាពនៃវប្បធម៌ជនជាតិចាមម៉ូស្លីមកាន់ខ្លាំងជាងមុន ។ បន្ទាប់មក ខ្ញុំយល់ឃើញថា ការប្រើប្រាស់មន្តអាគមក្នុងចំណោមជនជាតិចាមម៉ូស្លីម អាចជាគន្លឹះដើម្បីយល់ដឹងអំពីវប្បធម៌ ដោយមានហេតុផលបីយ៉ាង ទី១) វេទមន្តគឺផ្នែកមួយក្នុងចំណោមខ្លឹមសារនៃការសិក្សាដ៏សំខាន់បំផុតក្នុងការយល់ដឹងអំពីតម្លៃឬទស្សនជាសកលពាក់ព័ន្ធទៅនឹងជនជាតិ



ទួន និង ហាកឹម ជនជាតិចាម

ចាមសាមញ្ញ ទី២) មន្តអាគមមានអត្ថន័យថា ជានិមិត្តរូប អំពីការកកើតរបស់ជនជាតិចាមក្នុងសង្គមកម្ពុជា ដែលថាតើវាជាពិតឬយ៉ាងណា ទី៣) មន្តអាគមគឺជាទិដ្ឋភាពដ៏ចម្រូងចម្រាស់នៅក្នុងសង្គមម៉ូស្លីម ។ មានបញ្ញវ័ន្តជាច្រើននៅក្នុងមជ្ឈមណ្ឌលបូព៌ាទទួចថា ការប្រើប្រាស់មន្តអាគមត្រូវបានហាមឃាត់ ដោយសារវាប្រឆាំងទៅនឹងជំនឿរបស់សាសនាអ៊ីស្លាម ។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រើមន្តអាគមនៅតែមាន ។

ខ្ញុំបានធ្វើការសិក្សាតាមរយៈការសម្ភាសគ្រូ ឬគ្រូមន្តអាគមនៅតាមតំបន់មួយចំនួនក្នុងទីក្រុងភ្នំពេញ ដូចជា ប្រាំងចំរេះ ជ្រោយចង្វារ ព្រែកប្រា និងព្រែកលៀប នៅពាក់កណ្តាលឆ្នាំ២០១៣ ។ ពាក្យ "គ្រូ" មានន័យថា "មេ" ដែលកើតចេញពីពាក្យសំស្ក្រឹត គុរុ ហើយត្រូវបានប្រើប្រាស់ដើម្បីនិយាយសំដៅទៅរក "គ្រូវេទមន្ត" "គ្រូធ្មប់" ឬ "គ្រូព្យាបាលជំងឺអំពើធ្មប់" នៅក្នុងជំនឿជនជាតិចាម និងពុទ្ធសាសនិកខ្មែរ ។ ខ្ញុំបានសម្ភាសជាមួយគ្រូចំនួន៣០នាក់ ។ មួយភាគបីក្នុងចំណោមគ្រូទាំងនោះគឺជាស្ត្រី ។ ២៨ភាគរយនៃគ្រូទាំងនោះ មានអាយុចន្លោះ៣០ឆ្នាំទៅដល់៤០ឆ្នាំ ហើយ៤៤ភាគរយស្ថិតក្នុងអាយុ៥០ឆ្នាំ ដល់៦០ឆ្នាំ ហើយ២៨ភាគរយក្នុងចំណោមគ្រូទាំងនោះ ស្ថិតក្នុងអាយុ៧០ឆ្នាំ ដល់៨០ឆ្នាំ ។ ខ្ញុំបានសរសេរឈ្មោះរបស់គ្រូមន្តអាគមទាំងនោះជាតួអក្សរកាត់ ដើម្បីការពារឯកជនភាព ហើយខ្ញុំចង់បង្ហាញនូវការដឹងគុណយ៉ាងជ្រាលជ្រៅរបស់ខ្ញុំចំពោះអ្នកទាំងនោះ ។ ខ្ញុំចង់អរគុណចំពោះការគាំទ្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សា ហ្វាទីលី និងជំនួយការស្រាវជ្រាវរបស់ខ្ញុំ ។

តាមរយៈការសិក្សាស្រាវជ្រាវនេះ ការងារជាច្រើនត្រូវបានលាតត្រដាង ។ ផ្នែកមួយក្នុងចំណោម ការសិក្សាស្រាវជ្រាវនោះ គឺថាភាគច្រើននៃអ្នកមកពឹងពាក់គ្រូមន្តអាគមចាម គឺជាជនជាតិខ្មែរមិនមែនជាជនជាតិចាទេ ។ មុនពេលដែលខ្ញុំចាប់ផ្តើមការសិក្សាស្រាវជ្រាវ ខ្ញុំបានសន្មតថា សហគមន៍ជនជាតិចាមមានភាពជិតស្និទ្ធនឹងគ្នា ។ ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីការចាប់ផ្តើមការសិក្សាស្រាវជ្រាវ ខ្ញុំយល់ឃើញថា ជនជាតិខ្មែរភាគច្រើនត្រូវការវេទមន្តរបស់ជនជាតិចាម ដើម្បីដោះស្រាយបញ្ហារបស់ខ្លួនទាក់ទងទៅនឹងបញ្ហាប្តីប្រពន្ធ ជំនួញ និងសុខភាព ទោះបីជាសង្គមខ្មែរមាននិន្នាការភ័យខ្លាចចំពោះវេទមន្តរបស់ជនជាតិចាមក៏ដោយ ។

ខ្ញុំចង់បន្ថែមថា ខ្ញុំមិនអាចយល់ស្របជាមួយនឹងពាក្យចចាមអារាមដែលថា ជនជាតិចាម គឺជាគ្រូមន្តអាគមដ៏ពូកែដែលខ្ញុំបាននិយាយកាលពីខាងដើមនៃអត្ថបទនេះ ។ គ្រូមន្តអាគមជាច្រើនដែលខ្ញុំបានសម្ភាសបាននិយាយថា "កាលពីអតីតកាល ជនជាតិចាមជាច្រើនអាចប្រើប្រាស់មន្តអាគមដើម្បីព្យាបាលជំងឺ ឬការពារខ្លួនពីសត្រូវ" ។ ពាក្យនេះបង្កប់នូវអត្ថន័យយ៉ាងច្បាស់ថា នៅពេលបច្ចុប្បន្ននេះ ជនជាតិចាម ធម្មតាមិនបានប្រើប្រាស់មន្តអាគមនោះឡើយ ។ ជាងនេះទៅទៀត មេដឹកនាំសាសនា ជនជាតិចាមដូចជា ហាកឹម (មេដឹកនាំសហគមន៍ និងវិហារអ៊ីស្លាម) ហើយអ្នកដែលមានការយល់ដឹងអំពីអ៊ីស្លាម នៅក្រៅប្រទេសកម្ពុជា មិនព្រមទទួលយកចំពោះការប្រើប្រាស់មន្តអាគមនោះឡើយ ។ ភាគច្រើននៃអ្នកទាំងនោះទទូចថា "មិនមានគ្រូមន្តអាគមនៅក្នុងសាសនាអ៊ីស្លាមនោះទេ" ឬ "មិនមានការអនុញ្ញាតឲ្យប្រើមន្តអាគមក្នុងចំណោមជនជាតិម៉ូស្លីមនោះទេ" ។ ឧទាហរណ៍ អាម៉ាត យ៉ាសយ៉ា ប្រធានអង្គការអភិវឌ្ឍសហគមន៍អ៊ីស្លាមកម្ពុជា ដែលជាអង្គការមួយក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលរបស់ជនជាតិចាម ដ៏មានឥទ្ធិពល និងសកម្មបំផុត បាននិយាយថា "ខ្ញុំមិនជឿមនុស្សទាំងនោះទេ.... ទី១) គឺថា ការក្លាយជាគ្រូមន្តអាគមគឺផ្ទុយទៅនឹងការបង្រៀនរបស់អ៊ីស្លាម ។ ទី២) គឺថា អ្នកទាំងនោះកុហកមនុស្ស"

ចំណុចដ៏សំខាន់នៃការសិក្សាស្រាវជ្រាវរបស់ខ្ញុំកាលនោះ គឺថា គ្រូមន្តអាគមចាមប្រើប្រាស់មន្តអាគម ដោយយោងទៅលើវិធីសាស្ត្រ ឬ ទ្រឹស្តី ដែលកើតចេញពីវប្បធម៌ចំនួនបីៈ វប្បធម៌មកពីអាណាចក្រចម្ប៉ាដែលមានដើមកំណើតនៅប្រទេសវៀតណាម ។ វប្បធម៌របស់អ៊ីស្លាមតាមរយៈប្រទេសម៉ាឡេស៊ី និងវប្បធម៌ខ្មែរ ។ ផ្នែកដំបូងហាក់បីដូចជាកាន់តែទន់ខ្សោយ ប៉ុន្តែផ្នែកដទៃទាំងពីរហាក់បីដូចជា ពង្រឹងឥទ្ធិពលរបស់ខ្លួន ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រធានបទនេះនឹងត្រូវបានពិភាក្សាក្នុងអត្ថបទផ្សេង ដែលមិនទាន់បោះពុម្ពផ្សាយនៅឡើយ ។ ផ្ទុយទៅវិញ ខ្ញុំចង់ពិភាក្សាអំពីអ្វីដែលត្រូវបានលាតត្រដាងអំឡុងពេលនៃការស្រាវជ្រាវរបស់ខ្ញុំ ដែលថា "តើសម័យខ្មែរក្រហមបានជះឥទ្ធិពលដល់គ្រូមន្តអាគមជនជាតិចាមនាពេលបច្ចុប្បន្នដោយរបៀបណា?" ។ ខ្ញុំមានការ

រីករាយ ប្រសិនបើអត្ថបទនេះអាចផ្តល់ពត៌មានមួយចំនួនអំពីស្ថានភាពនៅក្នុងសម័យខ្មែរក្រហម ទោះបីជាតិចតួចក៏ដោយ ។

## ១) ស្ថានភាពរបស់គ្រូវេទមន្តក្នុងអំឡុងសម័យខ្មែរក្រហម

នៅក្នុងរបបខ្មែរក្រហម ទាំងសាសនាអ៊ីស្លាម និងព្រះពុទ្ធសាសនាត្រូវបានបំផ្លិចបំផ្លាញ ។ ការកម្ទេចជនជាតិចាមមូស្លីមរបស់ខ្មែរក្រហម គឺកាន់តែធ្ងន់ធ្ងរជាងការកម្ទេចជនជាតិខ្មែរកាន់ព្រះពុទ្ធសាសនា ចំពោះអ្វីដែលត្រូវបានហៅថាជា "ការបោសសម្អាតពូជសាសន៍" ។ របបខ្មែរក្រហមបានបំផ្លាញវិហារអ៊ីស្លាម គម្ពីរសាសនាជាច្រើន រួមមាន គម្ពីរគូរ៉ាន ព្រមទាំងការសម្លាប់មេដឹកនាំសាសនារបស់សហគមន៍ជនជាតិចាម ដោយសារខ្មែរក្រហមជំទាស់ទៅនឹងការកកើតឡើងនៃសាសនាណាក៏ដោយ ។ ដូច្នេះហើយ វាមិនគួរឲ្យភ្ញាក់ផ្អើលដែលដឹងថា គ្រូវេទមន្តចាមជាច្រើនមិនបានលាតត្រដាងនូវចំណេះវិជ្ជារបស់ខ្លួន ហើយធ្វើពុតជាមិនចេះអ្វីនោះ ។ គ្រូមន្តអាគមជាច្រើន បាននិយាយថា "ខ្ញុំមិនបាននិយាយថា ខ្ញុំគឺជាគ្រូដើម្បីការពារខ្លួនឯង" ហើយ "ប្រសិនបើខ្ញុំបាននិយាយដូច្នេះ ខ្ញុំនឹងត្រូវគេសម្លាប់" ។ គ្រូមន្តអាគមមួយចំនួនបាននិយាយដែរថា ខ្លួនគាត់ធ្វើការងារជាអ្នកឃ្វាលគោ និងធ្វើជាជាង ក្នុងអំឡុងសម័យ ប៉ុល ពត ។

ទោះបីជាយ៉ាងណាក៏ដោយ មានគ្រូមន្តអាគមដទៃផ្សេងទៀតមួយចំនួន ដែលប្រើប្រាស់ចំណេះវិជ្ជារបស់ខ្លួនដើម្បីការពារខ្លួនពីរបបខ្មែរក្រហមដើម្បីរស់រានមានជីវិត ។ គ្រូ "ម" មានអាយុជាង៦០ឆ្នាំ បានប្រាប់ខ្ញុំថា គាត់បានលាក់កំបាំងការពិតដែលថាគាត់គឺជាគ្រូមន្តអាគមដែលប្រើប្រាស់ចំណេះវិជ្ជារបស់ខ្លួនដើម្បីការពារខ្លួនគាត់ពីគ្រាប់កាំភ្លើងរបស់ទាហានខ្មែរក្រហម ហើយបានលាក់កំបាំងខ្លួនតាមរយៈការទន្ទេញគម្ពីរគូរ៉ាន ប៉ុន្តែគាត់មិនអាចជួយអ្នកដទៃ ដោយសារគាត់ចាំបាច់ត្រូវការធ្វើការងារនេះដោយសម្ងាត់ ។ គ្រូមន្តអាគម "ក" មានអាយុជាង៧០ឆ្នាំ បាននិយាយថាចំណេះវិជ្ជាមន្តអាគមបានធ្វើឲ្យគាត់រស់រានមានជីវិតអំឡុងពេលដែលជីវិតរបស់គាត់ជួបគ្រោះថ្នាក់ ។ អំណាចមន្តអាគមរបស់គាត់បានធ្វើឲ្យគាត់អាចកត់សម្គាល់ខ្មែរក្រហមដែលនឹងមក ហើយគាត់អាចលាក់ខ្លួនបាន ។ គាត់អាចបំបាំងខ្លួនតាមរយៈការប្រើប្រាស់ស្លឹកឈើ ទោះបីជាគាត់អង្គុយក្រោមដើមឈើក៏ដោយ ។ បទពិសោធនេះបានពង្រឹងជំនឿរបស់គាត់លើអំណាចមន្តអាគម ។ មន្តអាគមបំបាំងខ្លួនមនុស្ស ហាក់បីដូចជាអាគមមួយក្នុងចំណោមមន្តអាគមរបស់ជនជាតិចាម នៅពេលដែលខ្ញុំបានសម្ភាសគ្រូមន្តអាគម ដែលបាននិយាយថា បច្ចុប្បន្នគាត់កំពុងប្រើ មន្តអាគមនោះ ប៉ុន្តែមិនទាន់បានទទួលជោគជ័យនៅឡើយ ។

មានគ្រូមន្តអាគមដែលមានវិជ្ជាព្យាបាលអ្នកជំងឺទាំងលក្ខណៈឯកជននិងបើកចំហ ។ គ្រូមន្តអាគមជាស្ត្រីមួយចំនួនបានប្រាប់ខ្ញុំថា គាត់បានព្យាបាលក្មេងៗ និងមនុស្សជំទង់ដែលឈឺ ដូចជាជំងឺសើស្បែក ឬការឈឺចាប់រៀងកាយ ។ ទោះបីជាយ៉ាងណាក៏ដោយ គ្រូមន្តអាគមទាំងនោះបានប្រើមន្តអាគមដោយសម្ងាត់ ។ គាត់បានបន្តការព្យាបាលផ្នែកវេជ្ជសាស្ត្រ រហូតដល់ពេលបច្ចុប្បន្នដោយប្រើប្រាស់រុក្ខជាតិជាថ្នាំព្យាបាល ។ គ្រូមន្តអាគមដទៃបានប្រើប្រាស់ចំណេះវិជ្ជានេះដោយបើកចំហ ដោយសារគ្រូទាំងនោះត្រូវខ្មែរក្រហមស្នើសុំឲ្យប្រើមន្តអាគមទាំងនោះ ។ គ្រូមន្តអាគមប្រុសម្នាក់មានអាយុ៨០ឆ្នាំ បាននិយាយថា នៅពេលដែលគាត់នៅបាត់ដំបង ខ្មែរក្រហមម្នាក់បានប្រាប់គាត់ថា ប្រពន្ធរបស់ខ្លួនមិនអាចមានកូននោះឡើយ ។ បន្ទាប់ពីគាត់បានប្រើមន្តអាគមដោយប្រើអង្ករ ប្រពន្ធរបស់ខ្មែរក្រហមរូបនោះក៏មានផ្ទៃពោះ ។ ខ្ញុំបានសួរថា តើខ្មែរក្រហមយល់ឃើញយ៉ាងដូចម្តេចចំពោះរូបគាត់នៅពេលដែលការប្រើមន្តអាគម មិនត្រូវបានអនុញ្ញាតក្នុងសម័យខ្មែរក្រហម ។ គាត់បានឆ្លើយថា គាត់មិនបានប្រាប់អំពីចំណេះវិជ្ជារបស់គាត់ក្នុងនាមជាគ្រូនោះទេ ប៉ុន្តែខ្មែរក្រហមមិនអាចយល់ដឹងអំពីរបៀបណាដើម្បីធ្វើឲ្យគ្រួសាររបស់គាត់មានកូនបាននោះ ហើយក៏មិនអាចស្វែងរកនរណាម្នាក់ ដែលអាចជួយព្យាបាលបាន ។ ខ្មែរក្រហមបានអនុញ្ញាតឲ្យគាត់ប្រើមន្តអាគមនោះ ទោះបីជាខ្មែរក្រហមបានហាមឃាត់ការប្រើមន្តអាគមជាផ្លូវការក៏ដោយ ។

គ្រូមន្តអាគម "ស" មានអាយុជាង៧០ឆ្នាំ បានប្រើប្រាស់ជំនាញពេទ្យរបស់ខ្លួនក្នុងសម័យខ្មែរក្រហម ។ គាត់ត្រូវបានខ្មែរក្រហមស្នើឲ្យគាត់ធ្វើជាគ្រូពេទ្យដែលប្រើប្រាស់ "ថ្នាំខ្មែរ" ប៉ុន្តែគាត់បានបិទបាំងអំពីការដែលថា គាត់ជាជនជាតិចាម ប្រសិនបើគាត់និយាយ គាត់នឹងត្រូវសម្លាប់ ។ គាត់មិនបានប្រើប្រាស់មន្ត

អាគម ដូចជាការទន្ទេញគម្ពីរគួរ៉ាននោះទេ ផ្ទុយទៅវិញ បានប្រើប្រាស់ជំនាញពេទ្យរបស់គាត់ ។ ពេលដែលខ្មែរក្រហមត្រូវការព្យាបាលជំងឺ គាត់អាចប្រើវិជ្ជាពេទ្យរបស់គាត់បាន ។ ដូច្នេះហើយ គ្រូមន្តអាគមជនជាតិចាមបានលាក់កំបាំងអត្តសញ្ញាណ ក្នុងនាមជាជនជាតិចាម ប៉ុន្តែតាមការតម្រូវ គាត់ប្រើមន្តអាគមដើម្បីព្យាបាលជំងឺ ទាំងប្រជាជនសាមញ្ញ និងខ្មែរក្រហម ។ រហូតមកដល់ពេលបច្ចុប្បន្ន គ្រូមន្តអាគមចាម ដូចជា គ្រូមន្តអាគមខ្មែរមានចំណេះវិជ្ជាព្យាបាលអ្នកជំងឺ ដែលតាមប្រពៃណីក្នុងតំបន់នោះ ត្រូវបានហៅថា ជាឱសថជំនួស ។

## ២) សម័យខ្មែរក្រហមជាដើមចមក្នុងការធ្វើជាគ្រូមន្តអាគម

មានការសិក្សាស្រាវជ្រាវ បានបញ្ជាក់ថា មានហេតុផលពីរយ៉ាងសម្រាប់គ្រូមន្តអាគមជ្រើសរើសការងារបែបនេះ ។ ទីមួយគឺថាអ្នកទាំងនោះកើតក្នុងគ្រួសារដែលមានគ្រូមន្តអាគម ហើយបន្តចំណេះវិជ្ជាពីគ្រូមន្តអាគមដទៃ ។ គ្រូមន្តអាគមជាច្រើនបាននិយាយ



ជនជាតិចាមសំប៉ះយ៉ាំង

ថា គាត់បានរៀនសូត្រពីឪពុកម្តាយរបស់ខ្លួន ឬពីជីដូនជីតាដែលជាគ្រូមន្តអាគម ។ ហេតុផលផ្សេងគឺថា បន្ទាប់ពីគាត់ឬក្រុមគ្រួសាររបស់គាត់ឈឺ ឬត្រូវបណ្តាសារពីអ្នកដទៃ ពួកគេចាប់ផ្តើមរៀនវេទមន្តដើម្បីដោះស្រាយបញ្ហាខ្លួនឯង ។ ខាងក្រោមនេះ គឺករណីមួយដែលសម័យខ្មែរក្រហមធ្វើឲ្យមនុស្សដែលមានហេតុផលទាំងពីរនេះក្លាយទៅជាគ្រូមន្តអាគម ។

គ្រូមន្តអាគម ម មានអាយុជាង៦០ឆ្នាំ បានរៀនមន្តអាគមដើម្បីព្យាបាលជំងឺវិកលចរិតរបស់ប្រពន្ធរបស់គាត់ ។ ដោយសារជីដូនជីតារបស់គាត់គឺជាគ្រូមន្តអាគម ហើយឪពុករបស់គាត់ចេះមន្តអាគមនោះ ។ ពួកគេបានបង្រៀនគាត់ពីមន្តអាគមមុនសម័យខ្មែរក្រហម ។ ប៉ុន្តែគាត់មិនបានចាប់អារម្មណ៍ ហើយក៏មិនបានប្រើប្រាស់កាលគ្រានោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងសម័យខ្មែរក្រហម គាត់បានប្រើប្រាស់ចំណេះវិជ្ជានោះដើម្បីគេចពីគ្រាប់កាំភ្លើងខ្មែរក្រហម ។ គាត់បាននិយាយថា ពិតប្រាកដណាស់មនុស្សជាច្រើនបានរៀនមន្តអាគម ដើម្បីការពារខ្លួនពីគ្រាប់កាំភ្លើងកាលសម័យនោះ ។ ប្រពន្ធរបស់គាត់បានវង្វេងស្មារតីដប់ដងកាលគ្រានោះ ហើយបានព្យាយាមសម្លាប់កូនរបស់ខ្លួន ។ ទង្វើរបស់គាត់នៅតែបន្តរហូតដល់ចប់សម័យខ្មែរក្រហម ។ ដូច្នេះហើយ គាត់បានសម្រេចចិត្តរៀនមន្តអាគមបន្តពីជីដូនជីតារបស់គាត់ និងឪពុក អាស្រ័យហេតុនេះ គាត់អាចធ្វើឲ្យប្រពន្ធរបស់គាត់ត្រឡប់មករកប្រកតីបាន ។

ចាប់តាំងពីសម័យខ្មែរក្រហម ករណីជាច្រើនត្រូវបានរាយការណ៍ថា មនុស្សទទួលរងការប៉ះទង្គិចសតិអារម្មណ៍ដោយសារការរស់នៅយ៉ាងលំបាករបស់ខ្លួន ។ ឧទាហរណ៍ ស្ត្រីជប៉ុនម្នាក់ឈ្មោះ យ៉ាស៊ូកុ ណៃតុ ដែលបានរៀបការជាមួយប្រតិភូទូតកម្ពុជា និងបានរស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមពុសំឡេងកូនប្រុសទីពីររបស់គាត់បន្ទាប់ពីកូនប្រុសទីមួយ និងកូនចិញ្ចឹមស្រីរបស់គាត់បានស្លាប់ភ្លាមៗបន្ទាប់ពីសម័យខ្មែរក្រហមបានឡើងគ្រប់គ្រងអំណាច ។ ដូចគ្នាទៅនឹងជនជាតិជប៉ុនដទៃ ទោះបីជាគាត់មិនបានជឿទាល់តែសោះអំពីជំនឿលើមន្តអាគមមុនសម័យខ្មែរក្រហម ។ បទពិសោធរបស់គាត់បានធ្វើឲ្យគាត់ជឿលើជំនឿ បន្ទាប់ពីគាត់ត្រឡប់ទៅប្រទេសជប៉ុន ក្រោយ

ពីការបញ្ចប់សម័យខ្មែរក្រហម ។

ប្រពន្ធរបស់គ្រូមន្តអាគម ម ទទួលរងការប៉ះទង្គិចសតិអារម្មណ៍ ដែលបណ្តាលឲ្យគ្រូមន្តអាគម ម ចង់រៀនវេទមន្ត ហើយក្លាយជាគ្រូមន្តអាគម ។ គ្រូមន្តអាគម ម បច្ចុប្បន្នធ្វើការងារជាគ្រូជួយមនុស្សដោះស្រាយបញ្ហា ដោយផ្អែកលើជំនឿលើសាសនាអ៊ីស្លាម ។ ទោះបីជាយ៉ាងណាក៏ដោយ គាត់បាននិយាយថា ពិតប្រាកដណាស់ គាត់មិនចង់ក្លាយជាគ្រូ ដោយសារគាត់កត់សម្គាល់ឃើញថា វាមិនសក្តិសមទៅនឹងជំនឿសាសនាអ៊ីស្លាមភាគច្រើន ហើយគាត់មិនចង់ឲ្យកូនប្រុសរបស់គាត់ធ្វើតាមគាត់ ដោយសារបច្ចុប្បន្នវាមានវិទ្យាសាស្ត្រ ។

### ៣) សម័យខ្មែរក្រហមគឺជាហេតុផលមួយនៃការបាត់បង់សៀវភៅមន្តអាគមរបស់អាណាចក្រចម្ប៉ា

តាមរយៈការងារស្រាវជ្រាវនេះ បានបង្ហាញថា គ្រូមន្តអាគមជនជាតិចាម ធ្លាប់មានសៀវភៅមន្តអាគម ដែលត្រូវបានប្រើប្រាស់ដើម្បីយល់ដឹងអំពីអ្វីៗទាំងអស់នាពេលអនាគត ។ សៀវភៅនោះត្រូវគេហៅថា គីតាប អ៊ីល ហ្វលាក ឬ គីតាប (តឹម-ប៉ុក) ប៉ុន្តែបច្ចុប្បន្នវាបានបាត់បង់អស់ហើយ ។ "គីតាប" មានន័យថា "សៀវភៅ" ហើយ "អ៊ីល ហ្វលាក" កើតចេញពីពាក្យ "អ៊ីម អាល ហ្វលាក" ដែលមានន័យថា "ការយល់ដឹងអំពីរាងកាយ" ហើយជាធម្មតាត្រូវបានប្រើប្រាស់ដើម្បីនិយាយអំពីការសិក្សាអំពីហោរាសាស្ត្រ ។ សម្រាប់អត្ថន័យនៃពាក្យ "តឹមប៉ុក" ខ្ញុំបានសួរគ្រូមន្តអាគមយ៉ាងច្រើន ប៉ុន្តែមិនអាចទទួលបានចម្លើយច្បាស់លាស់ណាមួយទេ ។ អ្វីដែលខ្ញុំអាចគូសបញ្ជាក់នាពេលបច្ចុប្បន្ន គឺថា "អ៊ីល ហ្វលាក" និង "តឹមប៉ុក" មានសំឡេងស្រដៀងគ្នា ជាពិសេសផ្នែកខាងក្រោយនៃពាក្យទាំងពីរនេះ ដែលបង្កប់អត្ថន័យថា មានសៀវភៅតែមួយប៉ុណ្ណោះដែលមានឈ្មោះពីរផ្សេងគ្នា ។ ប៉ុន្តែតាំងពីយូរមក ខ្ញុំមិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីវិនិច្ឆ័យនោះទេ ។

ជាអកុសល មានព័ត៌មានតិចតួចស្តីពីសៀវភៅ ទោះបីជាមានព័ត៌មានផ្សេងៗក៏ដោយ ។ គ្រូមន្តអាគមខ្លះបាននិយាយថា គីតាប អ៊ីល ហ្វលាក និង គីតាប តឹមប៉ុក គឺជាសៀវភៅពីរផ្សេងគ្នា ទន្ទឹមពេលដែលអ្នកដទៃបាននិយាយថា សៀវភៅទាំងពីរនេះ គឺជាសៀវភៅមួយដែលមានឈ្មោះពីរផ្សេងគ្នា ។ មនុស្សជាច្រើនបាននិយាយថា ធ្លាប់បានឮឈ្មោះ ប៉ុន្តែមិនបានឃើញសៀវភៅនោះដោយផ្ទាល់ភ្នែកនោះទេ ប៉ុន្តែអ្នកទាំងនោះបានឃើញគ្រូមន្តអាគមផ្សេងអានសៀវភៅនោះតាំងពីអតីតកាល ប៉ុន្តែមិនដែលបានអានសៀវភៅដោយខ្លួនឯងនោះទេ ។ ខ្ញុំបានជួបជាមួយគ្រូមន្តអាគមមួយចំនួន ដែលបានលើកឡើងថា គាត់បានអានសៀវភៅនោះ ប៉ុន្តែបានក្រវេងចោល ។ ដោយផ្សារភ្ជាប់សាច់រឿងទាំងនេះ សៀវភៅមន្តអាគមមានដើមកំណើតមកពីប្រទេសចម្ប៉ា ដែលនិយាយរៀបរាប់អំពីអាណាចក្រដែលបានបាត់បង់ ហើយត្រូវបានសរសេរជាភាសាចាម (កាក កក) ។ ទោះបីជាយ៉ាងណាក៏ដោយ គ្រូមន្តអាគមមួយចំនួនបាននិយាយថា សៀវភៅនោះត្រូវបានបំផ្លាញចោលក្នុងរបបខ្មែរក្រហម ហើយអ្នកដទៃបាននិយាយថា សៀវភៅនោះត្រូវជនជាតិចាមក្រវែងចោល ដោយសារសៀវភៅនោះរៀបរាប់អំពីការទស្សទាយជាតារាសី ដែលមិនត្រូវបានអនុញ្ញាតក្នុងចំណោម ជនម៉ូស្លីមដែលជឿលើព្រះអាឡា ។ ព្រះអាចដឹងអ្វីៗទាំងអស់រួមទាំងអនាគត ។

នេះគឺជាករណីមួយរបស់គ្រូមន្តអាគមដែលជឿថា សៀវភៅនោះត្រូវបានបាត់បង់ដោយសារតែរបបខ្មែរក្រហម ។ គ្រូ ដ មានអាយុជាង៥០ឆ្នាំ បានប្រាប់ខ្ញុំដូចខាងក្រោមថា

> គាត់ខ្លួនឯងមិនបានឃើញសៀវភៅនោះទេ ប៉ុន្តែគាត់បានគិតថា ជីតារបស់គាត់ធ្លាប់មានសៀវភៅនោះ ។ គាត់មិនដឹងថាតើមានសៀវភៅមួយឬពីរក្បាលនោះទេ ។ ជីតារបស់គាត់គឺជាគ្រូមន្តអាគមដ៏ល្បីល្បាញ ដែលមិនចេះនិយាយភាសាខ្មែរ ប៉ុន្តែអាចយល់ដឹងសៀវភៅ កាក កក និងភាសាអារ៉ាប់ ។ គាត់គឺជាមនុស្សម្នាក់ដែលបានបង្រៀនគ្រូមន្តអាគម ដ អំពីមន្តអាគម ។ សៀវភៅនោះត្រូវបានសរសេរនៅក្នុងសៀវភៅ កាក កក ។ ទោះបីជាយ៉ាងណាក៏ដោយសៀវភៅនោះបានបាត់បង់ ពីព្រោះសៀវភៅនោះត្រូវបានកប់ក្នុងសម័យខ្មែរក្រហម ហើយមិនអាចរកឃើញបន្ទាប់ពីពេលនោះទេ ។ ជីតារបស់គាត់ គឺជាគ្រូមន្តអាគមម្នាក់ដ៏ពូកែ ដែលគាត់

*អាចមើលឃើញពីអនាគត ហើយអាចព្យាករណ៍អំពីអ្វីដែលនឹងកើតឡើង បន្ទាប់ពីរបបខ្មែរក្រហមបានកាន់កាប់ ។ ដូច្នេះហើយ ជីតារបស់គាត់បានព្យាករណ៍ថា សៀវភៅនោះនឹងត្រូវបាត់បង់ក្នុងសម័យខ្មែរក្រហម ហើយត្រូវថតចម្លងផ្នែកខ្លះនៃសៀវភៅដាក់លើក្រណាត់ដើម្បីរក្សាខ្លឹមសារ ។*

គ្រូ ដ បានបង្ហាញខ្ញុំនូវក្រណាត់ ដែលនៅលើនោះមាននិមិត្តរូបជាច្រើនជាតួអក្សរ ភាសាអារ៉ាប់ និងរូបថតនាវា ។ គាត់បាននិយាយថា និមិត្តរូបនិមួយៗមានអំណាចវេទមន្ត ដែលមានមុខងារផ្សេងៗ ហើយបន្ទាប់ពីជ្រើសរើសនិមិត្តរូបមួយ និមិត្តរូបនោះត្រូវបានចម្លងដាក់លើក្រដាសមួយ ដែលស្គាល់ថាជាស្នេហ៍ ។ គាត់បានពន្យល់ថា នាវា ដែលគូរលើក្រណាត់នោះ គឺនាវាមួយដែលជនជាតិចាមបានជិះដើម្បីគេចពីប្រទេសវៀតណាមមកកម្ពុជា ។ ឈើនាវានោះយកមកពីរាជវាំងនៃអាណាចក្រចម្ប៉ា ។ ដូច្នេះហើយ សាច់រឿងរបស់គ្រូមន្តអាគម "ដ" បានឆ្លុះបញ្ចាំងអំពីប្រវត្តិសាស្ត្រដ៏សោកសៅរបស់ចាមនៅក្នុងប្រទេសកម្ពុជា ដែលបានបាត់បង់ប្រទេសរបស់ខ្លួន ដោយសារការឈ្លានពានរបស់វៀតណាម ហើយត្រូវបានសម្លាប់អំឡុងសម័យខ្មែរក្រហម ។

ទោះបីជាយ៉ាងណាក៏ដោយ វាមិនងាយស្រួលសម្រាប់យើងដើម្បីទទួលបានការពិតអំពីសៀវភៅនោះ ។ គ្រូមន្តអាគម ដទៃ ដែលបានអះអាងថា គាត់ធ្លាប់មានសៀវភៅ ប៉ុន្តែបានបោះចោល ដោយសារគាត់ចាត់ទុកសៀវភៅនោះថាជាការប្រឆាំងទៅនឹងជំនឿលើសាសនាអ៊ីស្លាម ហើយបាននិយាយថា សៀវភៅនោះមិនបានដាក់បញ្ចូលរូបភាពណាមួយនោះទេ ប៉ុន្តែមានតែពាក្យប៉ុណ្ណោះ ។ អ្វីទាំងអស់ដែលយើងអាចសន្និដ្ឋានៅទីនេះ គឺថា សៀវភៅថតចម្លងនោះត្រូវបានបំផ្លាញចោល ហើយបានបាត់បង់ក្នុងសម័យខ្មែរក្រហម ហើយបន្ទាប់ពីពេលនោះមកសៀវភៅថតចម្លងផ្សេងៗត្រូវបានបំផ្លាញចោលដោយចេតនា ។ ដោយសារ



ទូន និង ហាកីម ជនជាតិចាមនៅកោះគ ក្នុងខេត្តកំពង់ចាម

តែការបាត់បង់សៀវភៅ វាហាក់បីដូចជាមិនអាចមានព័ត៌មានត្រឹមត្រូវអំពីរឿងនេះទេ ។ អ្វីដែលយើងដឹងនាពេលបច្ចុប្បន្ន គឺថាគ្រូចាមធ្លាប់មានសៀវភៅពិសេសស្តីពីមន្តអាគមនៅនគរចម្ប៉ា ប៉ុន្តែវាបានបាត់បង់ទៅវិញ ។

ដូចដែលបានឃើញពីផ្នែកខាងលើសម័យខ្មែរក្រហមគឺជាពេលវេលាមួយដែលគ្រូមន្តអាគមជនជាតិចាម ទទួលរងទុក្ខទោសនិងមានការព្រួយបារម្ភ ដូចគ្នាទៅនឹងប្រជាជនទាំងអស់នៅក្នុងប្រទេសកម្ពុជា ។ ឯកសារនេះ ផ្តោតលើជនជាតិចាម ប៉ុន្តែយើងអាចមើលឃើញយ៉ាងងាយស្រួលចំពោះការពិតដែលថាសហគមន៍ខ្មែរមានបទពិសោធន៍ស្រដៀងគ្នាទៅនឹងសាច់រឿងដែលពិពណ៌នាខាងលើ ។ យោងទៅតាមលោក ឌីឌីយេ៉រ ប័រត្រេន ដែលស្រាវជ្រាវអំពីបារមី ទោះបីជាការបញ្ចូលរូបអក្សរត្រូវបានហាមឃាត់ក្នុងសម័យខ្មែរក្រហម អ្នកកាន់បារមីត្រូវបានការពារដោយព្រលឹងខ្មោចដោយសារព្រលឹងខ្មោចបាននាំយកអាហារមកឲ្យអ្នកទាំងនោះ ។


ដាវរបស់ជនជាតិចាមប្រើក្នុងពេលបះបោរប្រឆាំងនឹងខ្មែរក្រហម

សៀវភៅរបស់ ហ្សង់ អូវីសេន និង អៀង ព្រីត ត្រេនគេលមានចំណាងជើងថា ជនជាតិកម្ពុជា និងវេជ្ជបណ្ឌិតរបស់ខ្លួន ៖ នរវិទ្យាវេជ្ជសាស្ត្ររបស់ប្រទេសកម្ពុជាសម័យអាណានិគម និងក្រោយអាណានិគម បានបរិយាយលម្អិតអំពីស្ថានភាពរបស់គ្រូមន្តអាគមខ្មែរ ជាគ្រូព្យាបាលជំងឺក្នុងតំបន់ ក្នុងសម័យខ្មែរក្រហម ។ មានគ្រូមន្តអាគមខ្មែរដែលបានរស់រានមានជីវិតពីសម័យខ្មែរក្រហម ដោយសារព្រមគោរពបញ្ជារបស់ខ្មែរក្រហម ក្នុងការផ្សំថ្នាំពីស្លឹកឈើ និងមិនប្រព្រឹត្តិអំពើសែនព្រេន អាថ៌កំបាំងនោះ ។ សៀវភៅរបស់ អូវីសេន និង ត្រេនគល បានលាតត្រដាងថាខ្មែរក្រហមបានទប់ស្កាត់ការផ្ទេរចំណេះដឹងព្យាបាលជំងឺតាមផ្លូវផងដែរនិងតាមលក្ខណៈវេជ្ជសាស្ត្រ ហើយបានលើកឡើងថា ស្លឹករឹតដែលមានការពន្យល់អំពីចំណេះវិជ្ជានេះត្រូវបានបំផ្លិចបំផ្លាញចោល ។ កាលពិត សៀវភៅរបស់ អ៊ាន ហារីស មានចំណងជើងថា ព្រះពុទ្ធសាសនាក្រោមរបប ប៉ុល ពត បានពិពណ៌នាអំពីការបំផ្លិចបំផ្លាញអក្សរសាស្ត្ររបស់ព្រះពុទ្ធសាសនាដូចជាស្លឹករឹត ។

អាស្រ័យហេតុនេះ គ្រូមន្តអាគមចាម និងខ្មែរមានបទពិសោធស្រដៀងគ្នានៅក្នុងសម័យខ្មែរក្រហម ប៉ុន្តែអ្នកទាំងនោះមានលក្ខណៈខុសគ្នា គ្រូមន្តអាគមចាមត្រូវតែលាក់កំបាំងអត្តសញ្ញាណរបស់ខ្លួនក្នុងនាមជាជនជាតិចាម ។ ភាពខុសប្លែកគ្នានេះបណ្តាលមកពីគោលនយោបាយ ខ្មែរក្រហមកម្ទេចជនជាតិចាមដែលមានដើមកំណើតមកពីនគរចម្ប៉ា ។ ខ្មែរក្រហមបានកែប្រែជនជាតិចាមនៅក្នុងប្រទេសកម្ពុជា ដើម្បីបំបាត់លក្ខណៈវប្បធម៌ចម្ប៉ាតាមរយៈការបំផ្លាញសៀវភៅមន្តអាគមរបស់អ្នកទាំងនោះ ។

ទោះបីជាយ៉ាងណាក៏ដោយ និន្នាការក្នុងការកាត់បន្ថយឥទ្ធិពលវប្បធម៌ចម្ប៉ា ក្នុងចំណោមជនជាតិចាម ហាក់បីដូចជាកំពុងបន្តទៅមុខនាពេលបច្ចុប្បន្ន ។

ម្យ៉ាងវិញទៀត លក្ខណៈវប្បធម៌អ៊ីស្លាម និងខ្មែរបានជះឥទ្ធិពលបន្ថែមទៀត ទោះបីជាការស្រាវជ្រាវនេះគឺជាប្រធានបទសម្រាប់ការពិភាក្សាផ្នែកក្រោយ ដូចដែលបានលើកឡើងនៅខាងលើក៏ដោយ ។

**រីកុ គូរ៉ូមីយ៉ា អូកាថា**

# មុំបី ៖ មូលដ្ឋានតស៊ូរំដោះខ្មែរក្រហម

## *សេចក្ដីផ្ដើម*

*ការកើនឡើង និងការធ្លាក់ចុះនូវប្រជាប្រិយភាពរបស់ខ្មែរក្រហម បានបន្សល់ទុកនៅពេលវេលាចងចាំ ដែលមិនអាចបំភ្លេចបានដល់ប្រជាជនទូទាំងប្រទេសកម្ពុជា ។ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ សកម្មភាពឧក្រិដ្ឋកម្មសាហាវយង់ឃ្នងបានផុសឡើង និងបន្តរហូតដល់ផុតរលត់ ។ ពេលថ្មីៗនេះ ដំណើរលំនាំស្រដៀងគ្នាទៅនឹងសកម្មភាពឧក្រិដ្ឋកម្មមួយនេះ ហាក់ដូចជារំកិលខ្លួនកៀកមកវិញបន្តិចម្ដងៗទៀតហើយ ។ អាស្រ័យហេតុដូច្នេះហើយ បានជាជំរុញឲ្យមានការរៀបចំវេទិកាសាធារណៈតាមភូមិ គាំទ្រដោយគម្រោងឃ្លាំមើលយុត្តិធម៌របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៤ នៅឃុំកំពង់ស្រឡៅ១ នៃខេត្តព្រះវិហារ ដែលមានការចូលរួមពីខាងអ្នកភូមិប្រមាណជា២២នាក់ ក្នុងនោះមានស្ត្រី ៨នាក់ និងការចូលរួមពីសំណាក់សិស្សានុសិស្សចំនួន៥៨នាក់ ក្មេងស្រីមាន៣០នាក់ ។ គួរបញ្ជាក់ថា អ្នកដែលមកចូលរួមត្រូវចំណាយពេលប្រហែលជាពីរម៉ោងពីផ្ទះ ឬពីកន្លែងការងាររបស់ខ្លួន ដើម្បីមកកាន់សាលាស្រុកឆែប ដែលស្ថិតនៅក្បែរអនុវិទ្យាល័យកំពង់ស្រឡៅ ។ នៅពេលជុំគ្នាហើយ គាត់បែកក្រុម និងពិភាក្សាទៅលើប្រធានបទមួយចំនួន ជាពិសេសប្រធានបទទាក់ទងនឹងតំបន់មុំបី ដែលជាតំបន់ផ្ដាច់ខ្លួនរបស់ទាហានខ្មែរក្រហម និងជាកន្លែងកសាងមូលដ្ឋានទ័ពចលនាតស៊ូរំដោះឡើងវិញ ។ លើសពីនេះទៅទៀត អ្នកចូលរួមបានទទួលសៀវភៅស្ដីពីរបបកម្ពុជាប្រជាធិបតេយ្យ*



*ផ្លូវទៅកាន់ស្រុកឆែប ខេត្តព្រះវិហារ*

ដែលបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដោយផ្ទាល់ ដើម្បីទុកអានពង្រីកចំណេះដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរការកាត់ទោសរបស់សាលាក្តីខ្មែរក្រហម ។ បង្វែរមកវិញ អត្ថបទនេះផ្តោតសំខាន់លើការរៀបរាប់របស់អ្នកភូមិ និងប្រតិកម្មរវាងអ្នកភូមិ និងក្មេងៗជំនាន់ក្រោយក្នុងសហគមន៍ រួមទាំងប្រតិកម្មរបស់អ្នកចូលរួមចំពោះវេទិកានេះ ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងប្រវត្តិសាស្ត្រខ្មែរក្រហមទាំងមូល ។

### ចំណុចសំខាន់ៗនៃវេទិកាក្នុងឃុំស្រឡៅ១

មុំបី គឺជាប្រធានបទសំខាន់មួយ ក្នុងចំណោមប្រធានបទផ្សេងៗដែលត្រូវយកមកពិភាក្សានៅក្នុងវេទិកាសាធារណៈតាមភូមិ ។ ការពិភាក្សាត្រូវបានបែកចែកជាបីក្រុម នៅក្នុងអំឡុងពេលពិភាក្សា អ្នកភូមិភ្ញាក់ផ្អើលថា សិស្សភាគច្រើនបានសិក្សាពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហម តែបែជាមើលរំលងនូវរឿងរ៉ាវដែលបានកើតឡើងក្នុងសហគមន៍របស់ខ្លួនក្នុងរបបខ្មែរក្រហម ។ ទោះបីជាយ៉ាងណាក្តី អ្នកភូមិព្យាយាមលើកយកនូវរឿងរ៉ាវនិងបទពិសោធផ្ទាល់ខ្លួនក្នុងរបបខ្មែរក្រហមមកបកស្រាយ និងចែករំលែកដល់ក្មេងៗ ដើម្បីបង្កើនការយល់ដឹងពីប្រវត្តិសហគមន៍ខ្លួនផ្ទាល់ មុនឈានដល់ការពិភាក្សាលើតំបន់មុំបី ។ ជាក់ស្តែង តំបន់មុំបី មានព្រំប្រទល់ខាងកើតជាប់នឹងឡាវ ខាងលិចជាប់នឹងថៃ ។

ដូចដែលបានរៀបរាប់ខាងលើ ហាំ រុម អាយុ៥៨ឆ្នាំ រស់ក្នុងឃុំកំពង់ស្រឡៅ១ នៃខេត្តព្រះវិហារ បានប្រាប់ទៅកាន់អ្នកចូលរួមទាំងអស់ក្នុងក្រុម អំពីជោគវាសនាប្តីរបស់គាត់ និងមូលដ្ឋានផ្តាច់ខ្លួនចុងក្រោយរបស់ខ្មែរក្រហម ។ រុម ប្រាប់ថា ប្តីរបស់គាត់ឈ្មោះថា ជុង ធី គឺជាអតីតមេបញ្ជាការកងពលធំក្នុងតំបន់ភូមិភាគឧត្តរ ចំណែកឯខ្លួនគាត់វិញ គឺជាមេកងរងរបស់កងចល័តនារីកម្រិតថ្នាក់ស្រុក ។ ក្រោយមក ដោយសារតែខាងបងប្អូនសាច់ថ្លៃរបស់គាត់ត្រូវបានចោទប្រកាន់ពីបទក្បត់ជាតិ ប្រឆាំងទៅនឹងបដិវត្តន៍ ប្តីរបស់គាត់ត្រូវអង្គការទម្លាក់តួនាទីពីមេបញ្ជាការកងពលធំទៅមេបញ្ជាការកងវរសេនាតូច ។ រុម ផ្ទាល់ ត្រូវបានអង្គការចាប់ចង និងបញ្ជូនទៅកាន់មន្ទីរស-២៨ ដែលជារោងចក្រផលិតក្រណាត់ អស់រយៈពេលមួយឆ្នាំ ។ រុម ចាំថា ឆ្នាំ១៩៧៨ ប្តីរបស់គាត់ត្រូវបានអង្គការហៅឲ្យទៅកសាង ។ មុនពេលដែលប្តីគាត់ចាកចេញ បានផ្តាំគាត់ថា ប្រសិនបើមិនឃើញគាត់ត្រឡប់មកវិញទេ ឲ្យគាត់រត់គេចខ្លួនទៅកាន់ប្រទេសឡាវ ។ នៅត្រង់ចំណុចនេះ រុម បញ្ជាក់ម្តងហើយម្តងទៀតថា ប្តីរបស់គាត់ហាក់ដូចជាដឹងខ្លួនមុនថា ខ្លួនគាត់បម្រុងនឹងត្រូវបានខ្មែរក្រហមសម្លាប់ហើយ ព្រោះជាក់ស្តែង ស៊ីម ដែលជាមេបញ្ជាការរងត្រូវបានខ្មែរក្រហមសម្លាប់រួចបាត់ទៅហើយ ។

អ្នកភូមិផ្សេងៗទៀត បន្តរៀបរាប់រឿងរ៉ាវកើតឡើងចំពោះខ្លួនគេផ្ទាល់ ទាក់ទងទៅនឹងបញ្ហាផ្សេងៗ ដូចជា កង្វះម្ហូបអាហារ និងការរៀបចំផែនការរត់គេចខ្លួន ។ ស្ត្រីវ័យក្មេងម្នាក់បានលើកឡើងពីការផលិតស្រូវទាំងឡើងឆ្ងល់ថា គាត់ឃើញថានៅពេលរដូវប្រមូលផលគាត់ម្តងៗ ទិន្នផលស្រូវដែលទទួលបានច្រើនក្រាស់ក្រៃល តែជាក់ស្តែង គាត់ឆ្ងល់ថាតើអង្គការយកទិន្នផលស្រូវទាំងនោះបញ្ជូនទៅណា ។ បន្ថែមពីនេះ ទេព ភ័ក្ត្រ អាយុ៨៧ឆ្នាំ រស់នៅក្នុងឃុំកំពង់ស្រឡៅ១ ក៏បានលើកឡើងពីករណីស្រដៀងគ្នានេះ ដែលរួមមានចំណីអាហារមិនគ្រប់គ្រាន់ការកសាងទំនប់ និងប្រឡាយទឹក និងការព្រាត់ប្រាស់សមាជិកគ្រួសារ ។ បន្ទាប់ទៀត ដោយមានចម្ងល់ពីក្មេងៗ គាត់ក៏លើកពីការរៀបការដោយចាប់បង្ខំ គាត់ប្រាប់ថា ក្នុងពិធីរៀបការម្តងៗដែលធ្វើឡើងដោយអង្គការ គឺអង្គការរៀបការច្រើនគូ ។ ជាក់ស្តែង ការរៀបការដោយបង្ខំនេះកំពុងត្រូវបានស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។

ចំណែក ថោង វិញ បានប្រាប់ពីការរត់ភៀសខ្លួនរបស់គាត់ទៅកាន់ប្រទេសឡាវ បន្ទាប់មក គាត់ក៏ត្រូវបានគេបង្ខំឲ្យត្រឡប់មកវិញ ដោយរស់នៅសម្ងំខ្លួនក្នុងព្រៃ ។ នៅពេលដែលក្មេងៗសួរថាហេតុអ្វីបានជាគាត់ត្រឡប់មកវិញក្នុងរបបខ្មែរក្រហម (ឆ្នាំ១៩៧៥-៧៩) ថោង ប្រាប់ថា គាត់ជឿជាក់ទៅលើបដិវត្តន៍ តែនៅពេលគាត់ត្រឡប់មកវិញ អ្វីៗគឺមិនដូចជាការដែលគាត់បានរំពឹងទុកនោះទេ ។

ក្រោយមក សិស្សានុសិស្សដែលបានចូលរួម ហាក់ដូចជាមានភាពស្ទាក់ស្ទើរ និងខ្មាស់អៀន មិនហ៊ានលើកសំណួរបន្ត ។

ឈឹម សុចិន្តា អាយុ២៧ឆ្នាំ ជាគ្រូមកពីអនុវិទ្យាល័យកំពង់ស្រឡៅ១ ជំរុញឲ្យសិស្សទាំងអស់ត្រូវចោទជាសំណួរ យ៉ាងតិចម្នាក់ៗឲ្យបានមួយ ។ រូបគាត់ផ្ទាល់សួរទៅកាន់ ចាន់ អ៊ិត អាយុ៧០ឆ្នាំថា គាត់មានធ្លាប់ឃើញការសម្លាប់ដោយផ្ទាល់ភ្នែកទេក្នុងរបបខ្មែរក្រហមទេ? អ៊ិត ឆ្លើយតបថា គាត់ធ្លាប់ឃើញពិតប្រាកដណាស់ ។ អ៊ិត បន្តថា គាត់ឃើញបុរសម្នាក់ ត្រូវបានចោទថាជាខ្មាំង ដោយសារគេទាក់ទងជំនួញជាមួយជនជាតិឡាវ បន្ទាប់មកត្រូវអង្គការសម្លាប់ និងកប់នៅក្នុងរណ្តៅដែលបានជីកស្រាប់ ។ បន្ទាប់មក សិស្សានុសិស្សបានលើកសំណួរឡើងបន្តបន្ទាប់គ្នាទាក់ទងនឹងការអប់រំ តម្រូវការប្រចាំថ្ងៃ ឋានៈ និង តួនាទីរបស់ជនភៀសខ្លួនទៅកាន់ឡាវ និងសហរដ្ឋអាមេរិក ទីផ្សារ និងរូបិយប័ណ្ណនានា ។

នៅក្នុងការពិភាក្សា អ្នកភូមិក៏បានផ្តោតយកចិត្តទុកដាក់លើការដួលរលំនៃរបបខ្មែរក្រហម នៅខែមករា ឆ្នាំ១៩៧៩ និងអ្វីៗដែលគាត់បានធ្វើដើម្បីរស់ ហើយរត់គេពីការបាញ់ប្រហាររបស់យោធាខ្មែរក្រហម ។ ថោង ស្ថិតក្នុងវ័យ៧០ឆ្នាំ រស់នៅក្នុងភូមិកំពង់ស្រឡៅ១ ដដែលនេះ រៀបរាប់ថា នៅពេលដែលកងទ័ពវៀតណាមចូល គាត់សម្រេចចិត្តរត់គេចទៅប្រទេសឡាវ ប៉ុន្តែក្រោយមក គាត់ភៀសខ្លួនទៅកាន់ភ្នំដងរែក ។ គួរបញ្ជាក់ថា ភ្នំដងរែកនេះគឺជាកន្លែងដែលយោធាខ្មែរក្រហមបានជ្រើសរើសកម្លាំងដើម្បីវាយប្រយុទ្ធជាមួយវៀតណាម ។ តែផ្ទុយទៅវិញ ការវាយពិតប្រាកដនោះ គឺវាងខ្មែរ និងខ្មែរ ។ នៅពេលនោះ ថៃក៏បានអនុញ្ញាតឲ្យប្រជាជនខ្មែរចូលទឹកដីរបស់ខ្លួនដែរ ព្រោះថៃធ្លាប់បានសម្លាប់ប្រជាជនខ្មែរយ៉ាងច្រើន តាមរយៈដឹកអ្នកទាំងនោះទាំងឡានៗទៅដាក់គរចោលនៅភ្នំដងរែក ។ ភាគច្រើននៃប្រជាជនខ្មែរបានបាត់បង់ជីវិត ។

រុម រិញ បង្ហាញថា កំហឹងរបស់គាត់បានបន្ធូរបន្ថយនៅពេលដែលកងទ័ពវៀតណាមចូលមក ហើយដេញទាហានខ្មែរក្រហមទាំងអស់ចេញពីទីក្រុងភ្នំពេញ ។ រុម ប្រាប់ថា ទាហានខ្មែរក្រហមភាគច្រើន ដែលមកពីតំបន់ភាគឦសាន ចូលតាមស្រុកឆែប ហើយបណ្តេញប្រជាជនទាំងអស់ទៅកាន់តំបន់ភ្នំ ។ រុម ប្រកែកមិនព្រមទៅតាមគេ ដោយសារតែប្តីរបស់គាត់ត្រូវបានគេសម្លាប់ ។

អ្នកចូលរួមពីរនាក់ ឈ្មោះប្រកែកគ្នាអំពីរឿងខ្មែរក្រហមជ្រើសរើសយកតំបន់មុំបី ដោយសារតែទីតាំងនេះមានអំណោយផលដល់ការឈរជើងរបស់ទាហានខ្មែរក្រហម ។ មុត ស័យ អាយុ៥៨ឆ្នាំ ជាមេភូមិកំពង់ស្រឡៅ១ ក្នុងខេត្តព្រះវិហារ មានប្រសាសន៍ទៅកាន់អ្នកចូលរួមថា កម្លាំងខ្មែរក្រហមទាំងអស់ត្រូវបានដកចេញពីព្រំប្រទល់ប្រទេសកម្ពុជា ថៃ និងឡាវ ។ ហេតុផលដែលខ្មែរក្រហមជ្រើសរើសតំបន់នេះកាន់កាប់ ព្រោះថាតំបន់នេះ អាចយកទឹកដីថៃ និងឡាវជាខ្នងបង្អែក ដើម្បីទប់ទល់នឹងការវាយប្រហាររបស់ទាហានវៀតណាម សូមបញ្ជាក់ថា នេះគឺជាយុទ្ធសាស្ត្រយោធា ។ ស័យ លើកយកតំបន់អន្លង់វែង ដែលមានចម្ងាយ១៥គីឡូម៉ែត្រពីព្រំប្រទល់ខ្មែរ-ថៃ មកប្រៀបធៀបនឹងតំបន់មុំបីនេះថា មានស្ថានភាពអំណោយផលតិចជាង បន្ទាប់មក ខ្មែរក្រហមចាប់ផ្តើមរៀបចំ កម្លាំងសាជាថ្មី និងពង្រាយកម្លាំងតាមព្រំប្រទល់ថៃ-ឡាវ ។ មុំបីមានទីតាំងស្ថិតនៅក្នុងស្រុកនេះតែម្តង ហើយក្លាយជាទីប្រជុំកម្លាំងខ្មែរក្រហមដែលដកមកពីទីក្រុងភ្នំពេញ ។ អ្នកទាំងនោះឆ្លងកាត់តាមស្រុកឆែប ខេត្តព្រះវិហារ ហើយចុងក្រោយដល់គោលដៅក្នុងតំបន់មុំបី ។ ឆ្នាំ១៩៨៥ មុំបី ស្ថិតក្រោមការវាយប្រហារយ៉ាងខ្លាំង និងត្រូវបានបំផ្លិចបំផ្លាញទាំងស្រុងនៅពាក់កណ្តាលឆ្នាំ១៩៨០ ។

ស្រដៀងគ្នានេះដែរ ថ្លាំង ប្រាសាទ អាយុ៦៥ឆ្នាំ ជាទីប្រឹក្សាឃុំកំពង់ស្រឡៅ១ បានប្រាប់ថា ក្រោយពេលដកទ័ពខ្មែរក្រហមផ្លាស់ទៅកាន់តំបន់មុំបី ហើយប្រឹងបង្កើតយុទ្ធសាស្ត្រយោធាថ្មីមួយ ដើម្បីបណ្តេញទាហានវៀតណាមទាំងអស់ចេញពីប្រទេសកម្ពុជា ។ គួរបញ្ជាក់ថា កម្លាំងនេះ ទទួលបានជំនួយពីប្រទេសថៃ ។ លើសពីនេះ មានជំរំជនភៀសខ្លួនខ្មែរក្រហមមួយនៅកៀកនឹងចលនាឡាវស ។ ចលនាឡាវស គឺជាចលនាប្រឆាំងនឹងកម្លាំងកុម្មុយនីស្តឡាវ ។

ខណៈពេលដែលខ្មែរក្រហមចាត់ទុកថា តំបន់មុំបីគឺជាកន្លែងដែលមានសុវត្ថិភាព អ្នកអត្ថាធិប្បាយជាច្រើនចង្អុលបង្ហាញថា វាគឺជាកន្លែងដែលងាយរងការវាយលុក ។ ពាក់កណ្តាលឆ្នាំ១៩៨០ កងទ័ពវៀតណាមសហការជាមួយនឹងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា នាំឲ្យមានការវាយប្រហារលក្ខណៈទ្រង់ទ្រាយធំមួយ



ចាស់ៗ រៀបរាប់រឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមប្រាប់ដល់ក្មេងជំនាន់ក្រោយ ក្នុងវេទិកាសាធារណៈ នៅខេត្តព្រះវិហារ

ដណ្តើមយកតំបន់ជុំវិញទាំងអស់ ។ កម្លាំងខ្មែរក្រហមជ្រៀតចូលប្រទេសថៃ និងត្រឡប់មកទឹកដីប្រទេសកម្ពុជាវិញជាប្រញាប់ ។

***សេចក្តីសរុប***

ការចំណាយពេលប្រហែលជាជិតពីរម៉ោងក្នុងការពិភាក្សាលើប្រធានបទប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ឃើញថាប្រកបដោយចំណេះដឹង និងព័ត៌មាន ។ អ្នកភូមិដែលបានចូលរួម និងអ្នកដឹកនាំក្នុងក្រុមដែលបានបែងចែកជាបីក្រុមផ្សេងៗគ្នានោះ បានបង្ហាញពីចំណាប់អារម្មណ៍ក្នុងពេលពិភាក្សា និងរីករាយស្វាគមន៍រាល់ចម្ងល់ ឬសំណួរផ្សេងៗពីប្អូនៗសិស្សានុសិស្ស ។

ទន្ទឹមគ្នានេះដែរ តំបន់មុំបីដែលមានទីតាំងស្ថិតនៅក្នុងសហគមន៍របស់ខ្លួនផ្ទាល់ ក៏ត្រូវបានលើកយកមកពិភាក្សានៅក្នុងវេទិកានាថ្ងៃនោះដែរ ដើម្បីបញ្ជាក់ថា អ្នកចូលរួមបានដឹង និងចងចាំនូវប្រវត្តិរបស់តំបន់ដែលខ្លួនបានរស់នៅ ។ មុំបី គឺជាកន្លែងប្រមូលផ្តុំកម្លាំង ផ្លាស់ទី និងបន្សាំខ្លួន នៅចុងឆ្នាំ១៩៧៩ ក្នុងការបង្កើតចលនាតស៊ូវាយប្រហារនឹងវត្តមានរបស់កងទ័ពវៀតណាមលើទឹកដីកម្ពុជា ។ ទាក់ទងនឹងដំណើរការកាត់ក្តីខ្មែរក្រហម មានបណ្តឹងរដ្ឋប្បវេណីជាហូរហែ ទាមទារ និងរង់ចាំយុត្តិធម៌ត្រឡប់មកវិញ ។ សិស្សានុសិស្សដែលបានចូលរួម ចង់ឃើញដំណើរការកាត់ក្តីនេះ ប្រកបទៅដោយរលូន និងឆាប់រហ័ស ជាការតបស្នងដល់សមាជិកក្នុងគ្រួសារខ្លួនដែលបានស្លាប់ក្នុងរបបនោះ ។ ខណៈពេលដែលឃើញថាវេទិកាតាមភូមិនេះ ឆ្លុះបញ្ចាំងពីទិដ្ឋភាពពិត និងបើកចំហរដល់ប្រជាជនក្នុងការពិភាក្សា និងចែករំលែកបទពិសោធ អ្នកភូមិដែលបានមកចូលរួមស្នើសុំ ឲ្យមានការរៀបចំវេទិកាបែបនេះទៀតក្នុងសហគម៍របស់ពួកគេ ។ ជាងនេះទៅទៀត សៀវភៅដែលត្រូវបានចែកជូន មានដូចជា សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) សៀវភៅទស្សនាវដ្តីស្វែងរកការពិត សៀវភៅចងក្រងករណីសំណុំរឿង០០២ និងព្រឹត្តិបត្រសង្កេតការណ៍ដំណើរការកាត់ទោស គឺជាឯកសារពិគ្រោះដ៏ល្អប្រសើរ ដើម្បីយល់ដឹងបន្ថែមក្នុងករណីអវត្តមាន ឬមិនបានចូលរួមក្នុងវេទិកាពិភាក្សាតាមភូមិនេះ ។

**លី សុខឃាង**

# ការរៀបចំសំណង ការប្រឈមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២

***(តពីលេខមុន)***

ក្នុងសំណុំរឿង០០២ វិធានផ្ទៃក្នុងដែលបានធ្វើវិសោធនកម្ម បានធ្វើឲ្យទម្រង់ជាក់លាក់ ក្លាយជាតម្រូវការសម្រាប់ទាមទារសំណង ប៉ុន្តែបានជួយបន្ថែមដល់ជនរងគ្រោះក្នុងការកំណត់ពីភាពជាក់លាក់ ។ ដោយអនុលោមតាមវិធាន២៣ស្ទួន(២) ក្រុមដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួបរួមគ្នា ត្រូវដាក់សំណើមួយដើម្បីស្វែងរកសំណងសមូហភាព និងសំណងផ្លូវចិត្ត ។ សំណើនោះត្រូវតែដាក់បញ្ចូលការបកស្រាយសំណងដែលត្រូវស្វែងរក ដែលជាការលើកឡើងសមហេតុផលចំពោះ ថាតើសំណងបានដោះស្រាយនូវគ្រោះថ្នាក់ដែលទទួលរង និងរបៀបជាក់លាក់នៃការអនុវត្តសំណង ។ ឧទាហរណ៍ ថាតើជនជាប់ចោទអាចទ្រាំទ្រចំពោះសំណងបានឬទេ? ឬសំណងត្រូវបានបង្កើតឡើង និងត្រូវបានគាំទ្រថវិកាដោយមានការសហការជាមួយនឹងអង្គភាពគាំពារជនរងគ្រោះ ។ អង្គភាពគាំពារជនរងគ្រោះ មិនត្រូវបានផ្តល់សិទ្ធិអំណាចដើម្បីជួយជនរងគ្រោះបង្កើតសំណងជាក់លាក់ គ្រប់គ្រាន់ ហើយបានធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាល, រដ្ឋាភិបាល, សហមេធាវីនាំមុខ និងម្ចាស់ជំនួយដើម្បីបង្កើត គម្រោងអនុវត្តសំណងដែលត្រូវបានបង្ហាញដល់តុលាការ ។

ទន្ទឹមពេលដែលមានការកែប្រែនៅក្នុងវិធានផ្ទៃក្នុងបានជួយជនរងគ្រោះដើម្បីបង្កើតគម្រោងនោះ ហេតុផលដែលតុលាការប្រើប្រាស់ដើម្បីទាញហេតុផលអំពីការស្នើសុំជាក់លាក់ នៅតែជាបញ្ហាប្រឈមចំពោះជនរងគ្រោះដែលស្វែងរកសំណង ដែលត្រូវ



នីកូឡាស គុំចាន់ សហព្រះរាជអាជ្ញាអន្តរជាតិនៃសាលាក្តីខ្មែរក្រហម រង់ចាំឆ្លើយសំណួររបស់អ្នកភូមិក្នុងវេទិកាសាធារណៈ នៅខេត្តតាកែវ

ការត្រួតពិនិត្យ និងគ្រប់គ្រងដោយត្រឹមត្រូវបន្ទាប់ពីសំណុំរឿង ០០២បានបញ្ចប់ ។ នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូល បានទាញហេតុផលអំពីតម្រូវការនៃភាពជាក់លាក់របស់ខ្លួនតាមរយៈការបែរឆ្ពោះទៅរកសំណួរនៃការបង្គាប់ ។ តុលាការបានកត់សម្គាល់ថា តុលាការអន្តរអាមេរិកាំងទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស អាចដាក់បទដ្ឋានទាប អំពីភាពជាក់លាក់ ពីព្រោះវាអាចដាក់បន្ទុកមួយចំនួនដល់រដ្ឋក្នុងការចេញសេចក្តីបង្គាប់សំណង ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមានយុត្តាធិការលើប្រទេសកម្ពុជា ហើយខ្លួនក៏ខ្វះអំណាចក្នុងការត្រួតពិនិត្យដែរ ។ ការបង្គាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែអនុវត្តក្នុងវង្វង់ប្រព័ន្ធតុលាការ ឧទាហរណ៍ ដូចជាអ្នកការពារជនជាប់ចោទនៅក្នុងបន្ទប់សវនាការ ។ តុលាការបានបកស្រាយអំពីសំណង ដែលបង្គាប់នោះថាជាសំណងដែលមានភាពជាក់លាក់ ដែលត្រូវអនុវត្តដោយមិនចាំបាច់ត្រួតពិនិត្យតាមផ្លូវច្បាប់បន្ថែមពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយថាសំណងនោះមានលក្ខណៈស្មុគស្មាញដែលពន្យារពេលដល់ការចេញសេចក្តីសម្រេចអំពីការជំនុំជម្រះ ។ យុត្តាធិការរបស់តុលាការផ្អែកលើការស្រមើស្រមៃ ដែលគម្រោងសំណងផ្តល់ថវិកា និងភាពជាក់លាក់អាចត្រូវបានអនុវត្តដោយរលូន ដោយមិនចាំបាច់ធ្វើការត្រួតពិនិត្យ ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយមិនពិចារណាថាតើសំណងមានលក្ខណៈជាក់លាក់បែបណានោះ នៅពេលដែលសំណងត្រូវបានបង្ហាញនៅក្នុងតុលាការការត្រួតពិនិត្យមួយចំនួនចាំបាច់ត្រូវតែធ្វើឡើង ដែលបញ្ហាផ្លូវច្បាប់មិនបានបញ្ឈប់ការបង្កើតគម្រោងនោះឡើយ ហើយការត្រួតពិនិត្យនេះនឹងទំនងជាបន្តត្រូវការតាមរយៈការអនុវត្តសំណង ។

ឧទាហរហ៍ សំណងដែលបង្គាប់ដោយតុលាការ មាន “តម្រូវការទំនាក់ទំនង” ។ ក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានលើកឡើងថា សំណងត្រូវតែមានបំណងលុបបំបាត់ចោលការប៉ះពាល់ដែលជនរងគ្រោះទទួលរង ។ តម្រូវការដែលមានទំនាក់ទំនងនេះ ឬទំនាក់ទំនងហេតុរវាងឧក្រិដ្ឋកម្ម និងទម្រង់នៃសំណង ត្រូវបានបង្កើតឡើងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការអ៊ីរ៉ុបទទួលបន្ទុកសិទ្ធិមនុស្ស និងតុលាការអន្តរអាមេរិក ទទួលបន្ទុកសិទ្ធិមនុស្ស ។ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការអនុញ្ញាតចំពោះដើមបណ្តឹងរដ្ឋប្បវេណី ផ្អែកលើតម្រូវការទំនាក់ទំនងដំបូង ។ ឧទាហរណ៍ ការទទួលរងគ្រោះថ្នាក់ គឺជាលទ្ធផលផ្ទាល់នៃឧក្រិដ្ឋកម្ម ។ នៅពេលដែលត្រូវបានអនុញ្ញាតអោយចូលខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិស្វែងរកសំណង ។ ក៏ប៉ុន្តែ ទម្រង់នៃសំណងត្រូវតែឆ្លើយតបតម្រូវការទំនាក់ទំនងទី២



អ្នកភូមិ និងសិស្សានុសិស្សស្តាប់ការបកស្រាយរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងដំណើរក

ដូចជាសំណង ត្រូវតែមានទំនាក់ទំនងទៅនឹងការគ្រោះថ្នាក់ ដោយសំដៅលុបបំបាត់ចោលលទ្ធផលនៃអំពើខុសឆ្គងរបស់ឧក្រិដ្ឋជន ព្រមទាំងស្តាលក្ខខណ្ឌច្បាប់ដែលមានអាទិភាព ។ ឧទាហរណ៍ អង្គជំនុំជម្រះតុលាការកំពូល បានទទួលស្គាល់ការព្យាបាលផ្លូវចិត្ត និងរាងកាយដល់ជនរងគ្រោះ បានបំពេញតម្រូវការទំនាក់ទំនងទី២ ដោយសារការទទួលរងគ្រោះថ្នាក់ គឺជាការបង្កគ្រោះថ្នាក់ដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ ។ យោងតាមតុលាការព្រហ្មទណ្ឌអន្តរជាតិ សំណងដែលបង្គាប់ដោយតុលាការ

ទាមទារឲ្យមានទំនាក់ទំនងរវាងបទឧក្រិដ្ឋ និងគ្រោះថ្នាក់ ។ ម្យ៉ាងវិញទៀត ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយ ឡុ បានហ្កា មានហេតុផលស្រដៀងគ្នាទាក់ទងនឹងការបង្កការខូចខាតដែលត្រូវការសំណង ។ តម្រូវការទំនាក់ទំនងត្រូវបានកែប្រែ ហើយត្រូវបានរក្សានៅក្នុងការកែតម្រូវថ្មីនៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។


ការកាត់ទោសមេដឹកនាំខ្មែរក្រហម ក្នុងវេទិកាសាធារណៈ នៅខេត្តតាកែវ

វានឹងអាចជាការលំបាកសម្រាប់អង្គភាពដើម្បីអនុវត្តបទដ្ឋានផ្លូវច្បាប់ នៅពេលដែលខ្លួនអនុវត្តគម្រោងសំណង ដូចជាការកំណត់អត្តសញ្ញាណអ្នកដែលទទួលបានអត្ថប្រយោជន៍, ការបង្កើតទម្រង់លម្អិតស្តីពីជំនួយ និងការធានាថាការកែប្រែមួយចំនួនចំពោះគម្រោង មិនបានគំរាមកំហែងដល់ទំនាក់ទំនងផ្លូវច្បាប់រវាងការរងគ្រោះថ្នាក់ និងជំនួយ ។ ចំណោទសួរទាំងនេះត្រូវបានដោះស្រាយនៅដំណាក់ កាលបង្កើតគម្រោងនោះ ។ កិច្ចសន្យាជាលាយល័ក្ខណ៍អក្សរអាចចែងអំពីវិសាលភាពនៃគម្រោង, លក្ខខណ្ឌជាក់លាក់អំពីការអនុវត្តគម្រោង ហើយបានបង្កើតនូវការចង្អុលបង្ហាញលម្អិតចំពោះការកំណត់អ្នកដែលទទួលបានអត្ថប្រយោជន៍ ហើយកំណត់អំពីសិទ្ធិទទួលបានសំណង ។ សូម្បីតែមានកិច្ចសន្យាលម្អិតក៏ដោយ អង្គភាពនៅតែត្រូវប្រឈមដោះស្រាយ នៅពេលដែលវាយតម្លៃថាតើការងារបន្តដែលត្រូវបានកែសម្រួល ដោយសារតែលក្ខខណ្ឌទំនាក់ទំនងរវាងការរងគ្រោះថ្នាក់ និងការទទួលសេវាជំនួយឬថាតើអ្នកទទួលបានអត្ថប្រយោជន៍ថ្មីដែលមានសិទ្ធិទទួលបានគម្រោងនោះ មានលក្ខណៈស្របទៅនឹងបទដ្ឋានផ្លូវច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬទេ ។ ទោះបីជាយ៉ាងណា ក៏ដោយការប្រឈមដ៏លំបាកបំផុតនឹងធានាថា កិច្ចសន្យាដែលកំណត់នូវសំណងគ្រប់គ្រាន់ត្រូវបានអនុវត្តជាលាយល័ក្ខណ៍អក្សរ ។ សរុបសេចក្តីមក ការជំរុញរបស់តុលាការមួយចំនួននឹងនៅតែជាការប្រឈមដ៏សំខាន់ ។ដូច្នេះហើយ ការត្រួតពិនិត្យមើលរបស់តុលាការមានសារសំខាន់ដើម្បីធានាថា សំណងនៅតែជាបុព្វសិទ្ធិផ្លូវច្បាប់ដែលត្រូវប្រតិបត្តិ ។ ជាជាងការអនុវត្តយុទ្ធសាស្ត្រឈ្នះ (Defeatist approach) និងការកត់សម្គាល់ថា ខ្លួនមិនអាចផ្តល់នូវសំណងដ៏ប្រសើរ ពីព្រោះខ្លួនមិនអាចត្រួតពិនិត្យ មើលសំណងឲ្យបានគ្រប់គ្រាន់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គួរតែសម្លឹងមើលតុលាការព្រហ្មទណ្ឌអន្តរជាតិ និងអង្គភាពដទៃដែលមានបទពិសោធក្នុងការផ្តល់សំណងសម្រាប់ជាគំរូដល់តុលាការចំពោះការដែលអាចចែកកាតព្វកិច្ចចម្បងមួយចំនួនដល់អង្គភាពគ្រប់គ្រង ដើម្បីគ្រប់គ្រងសំណង ដូចជា អង្គភាពគាំពារជនរងគ្រោះ និងអង្គភាពដែលបង្កើតឡើងដាច់ដោយឡែក ហើយខ្លួនប្រហែលជានៅតែមានការចូលរួមក្នុងដំណើរការត្រួតពិនិត្យតាមរយៈអង្គជំនុំជម្រះ ឬអង្គភាពដែលបង្កើតឡើងដោយឡែកតែជាអង្គភាពស្របច្បាប់ ។ លទ្ធភាពសម្រាប់យន្តការត្រួតពិនិត្យ និងគ្រប់គ្រងត្រូវបានពិភាក្សានៅខាងក្រោម ៖

១) ដំណើរការសំណងនាពេលបច្ចុប្បន្ន រួមមានការកំណត់, ការបង្កើត, ការរៃអង្គាសថវិកា និងគម្រោងអនុវត្ត ដែលចូលរួមដោយផ្នែកពាក់ព័ន្ធជាច្រើន ដូចជា អង្គភាពគាំពារជនរងគ្រោះ និងសហមេធាវីនាំមុខ ដែលមានទស្សនៈវិស័យផ្សេងគ្នាលើការត្រួតពិនិត្យសំណងដោយរបៀបណា បន្ទាប់ពី

ចេញសេចក្តីសម្រេចលើសំណុំរឿង០០២ ។

ក្របខ័ណ្ឌផ្លូវច្បាប់សម្រាប់ដំណើរការសំណងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាមទារឲ្យអង្គភាពគាំពារជនរងគ្រោះ និងសហមេធាវីនាំមុខធ្វើការងាររួមគ្នា ។ វិធានផ្ទៃក្នុង២៣ ស្ទួន(៣) (ក)(ខ) គ្រប់គ្រងវិធីសាស្ត្រ២សម្រាប់សំណងដែលបង្គាប់ដោយតុលាការ ។ ទី១) គឺការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងទៅនឹងជនជាប់ចោទដែលត្រូវបានបង្គាប់ដោយតុលាការកម្ពុជា ធម្មតាមិនមែនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះទេ ។ នេះគឺជាវិធីសាស្ត្រតែមួយនៃការផ្តល់សំណងដែលមាននៅក្នុងសំណុំរឿង០០១ ។ វិធីសាស្ត្រទី២) សម្រាប់សំណង គឺដំណើរការ រៀបចំសំណង ។ ដោយអនុលោមតាមវិធាន ២៣ ស្ទួន តុលាការអាចទទួលស្គាល់គម្រោងជាក់លាក់ថាជាសំណង ប្រសិនបើសំណងត្រូវបានបង្កើតឡើង ឬត្រូវបានកំណត់ដោយមានការសហការជាមួយនឹងអង្គភាពគាំពារជន រងគ្រោះ ហើយសំណងនោះបានធានាឲ្យមានថវិកាផ្នែកខាងក្រៅគ្រប់គ្រាន់ ។ ដូចគ្នាទៅនឹងមូលនិធិសំណងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយអនុលោមតាមវិធានដែលធ្វើវិសោធនកម្ម អង្គភាពគាំពារជនរងគ្រោះ ត្រូវបានបង្គាប់ឲ្យកំណត់ និងបង្កើតសំណងដែលបង្គាប់ដោយតុលាការជាមួយនឹងសហមេធាវីនាំមុខ, អង្គការក្រៅរដ្ឋាភិបាល និងអង្គភាពដទៃ ។ សហមេធាវីនាំមុខ អាចស្នើឲ្យអង្គជំនុំជម្រះទទួលស្គាល់ថា មធ្យោបាយសំណងជាក់លាក់មានលក្ខណៈសមស្របសម្រាប់ការអនុវត្តគម្រោងថវិកាផ្នែកខាងក្រៅ ។

វិធានផ្ទៃក្នុង អាចត្រូវបានបកស្រាយដើម្បីទាមទារឲ្យមានការចូលរួមរបស់អង្គភាពគាំពារជនរងគ្រោះនៅក្នុងការកំណត់អត្តសញ្ញាណ និងបង្កើតដំណាក់កាលនៃគម្រោងសំណង ទោះបីជាយ៉ាងណាក៏ដោយសហមេធាវីនាំមុខ និងដៃគូរបស់ខ្លួនមានសេរីភាពផ្តាច់ចេញពីអង្គភាពគាំពារជនរងគ្រោះ អំឡុងពេលដំណាក់កាលអនុវត្តគ្រប់គ្រង និងត្រួតពិនិត្យសំណង ។ ម្យ៉ាងវិញទៀត វិធានផ្ទៃក្នុងបង្កើតអំណាចនិងកាតព្វកិច្ចសម្រាប់អង្គភាពគាំពារជនរងគ្រោះ និងសហមេធាវីនាំមុខ ។ អង្គភាពគាំពារជនរងគ្រោះមានអំណាចកំណត់, បង្កើត និងអនុវត្តគម្រោងសំណង ប៉ុន្តែមានកាតព្វកិច្ចកំណត់, បង្កើត និងអនុវត្តគម្រោងដោយមានការសម្របសម្រួលជាមួយនឹងសហមេធាវីនាំមុខ ។ សហមេធាវីនាំមុខ មានកាតព្វកិច្ចសហការជាមួយនឹងអង្គភាពគាំពារជនរងគ្រោះក្នុងដំណាក់កាលកំណត់ និងបង្កើតសំណង ។ វិធានផ្ទៃក្នុងនៅតែមិនមានឥទ្ធិពលលើការអនុវត្តគម្រោង ពីព្រោះការអនុវត្តគម្រោងនោះមិនមានការចូលរួមរបស់សហមេធាវីនាំមុខ ។ ជាការពិតណាស់ សហមេធាវីនាំមុខ គឺជាមេធាវីដែលមិនមានកាតព្វកិច្ចអនុវត្តគម្រោង ហើយក៏មិនមានថវិកាសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តគម្រោងនោះឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសំណុំរឿង០០២ សហមេធាវីនាំមុខបានស្វែងរក ភាគីទី៣ ក្នុងការអនុវត្តគម្រោងតាមរយៈការប្រើប្រាស់វិធីសាស្ត្រនៅក្នុងវិធានផ្ទៃក្នុងដើម្បីពង្រីកតួនាទីរបស់ខ្លួននៅក្នុងដំណើរការផ្តល់សំណង ។

ដូចគ្នាទៅនឹងវិធានផ្ទៃក្នុងស្តីពីសំណងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា៧៥ នៃលក្ខន្តិកៈទីក្រុងរ៉ូមផ្សាភ្ជាប់សំណងទៅនឹងការចោទប្រកាន់របស់ចុងចោទ ។ ការ



អ្នកភូមិស្តាប់ការបកស្រាយរបស់ព្រះរាជអាជ្ញា

ពន្យារពេលក្នុងការចេញសេចក្តីសម្រេចលើសំណងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ការពន្យារទាំងនេះ បង្កឲ្យមានផលវិបាកដល់ការរៃអង្គាសថវិកា ទន្ទឹមពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងបន្ត ហើយនៅក្នុងសំណុំរឿងរបស់ប្រទេសកម្ពុជា ជនរងគ្រោះមានវ័យចំណាស់ និងអ្នកប្រព្រឹត្តនៅមានជីវិតនៅឡើយ ។ ដោយអនុលោមតាមវិធានផ្ទៃក្នុងថ្មី អង្គភាពគាំពារជនរងគ្រោះត្រូវបានផ្តល់សិទ្ធិអំណាចដើម្បីបង្កើត និងអនុវត្តកម្មវិធី និងចំណាត់ការដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ដើម្បីដោះស្រាយបញ្ហាផលប្រយោជន៍របស់ជនរងគ្រោះ ។ ចំណាត់ការក្រៅប្រព័ន្ធតុលាការត្រូវបានបង្កើត និងអនុវត្ត ដោយមានអង្គភាពរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។ ចំណាត់ការដំណោះស្រាយក្រៅប្រព័ន្ធតុលាការមានបំណងធ្វើឡើងនៅក្រៅកិច្ចដំណើរនីតិវិធីរបស់តុលាការ ហើយត្រូវបានអនុវត្តមុនពេលដែលសេចក្តីសម្រេចត្រូវបានធ្វើឡើង ។ ចំណាត់ការដំណោះស្រាយក្រៅប្រព័ន្ធតុលាការបានដាក់បញ្ចូលសេវាមួយចំនួន ក្រៅពីសំណងដែលបង្គាប់ដោយតុលាការ ព្រមទាំងផ្តល់ការគាំទ្រដល់ជនរងគ្រោះច្រើនជាងអ្នកដែលត្រូវបានអនុញ្ញាតឲ្យធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ។ ចំណាត់ការដំណោះស្រាយក្រៅប្រព័ន្ធតុលាការ មិនបាននាំមកជាមួយនូវការកម្រិតបែបនីតិវិធីតឹងរ៉ឹង និងភ័ស្តុតាងដែលជារបាំង ដែលដើមបណ្តឹងប្រឈមនៅពេលធ្វើការទាមទារសំណងនៅចំពោះមុខតុលាការនោះទេ ។ អង្គភាពគាំពារជនរងគ្រោះមានអំណាចតែមួយក្នុងការបង្កើត និងអនុវត្តនូវចំណាត់ការក្រៅប្រព័ន្ធតុលាការ ។ អង្គភាពគាំពារជនរងគ្រោះ មិនមានកាតព្វកិច្ចសម្របសម្រួលសហមេធាវីនាំមុខ សម្រាប់ចំណាត់ការដំណោះស្រាយក្រៅប្រព័ន្ធតុលាការនោះទេ ។ សហមេធាវីនាំមុខអាចជួយអង្គភាពគាំពារជនរងគ្រោះកំណត់ និងបង្កើតគម្រោងចំណាត់ការដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ។ ប៉ុន្តែប្រការនេះនឹងស្ថិតនៅក្រៅក្របខណ្ឌនៃវិធានផ្ទៃក្នុង ដោយសារវិធានផ្ទៃក្នុងមិនបានផ្តល់ព័ត៌មានស្តីពីលទ្ធភាពនៃតួនាទីរបស់សហមេធាវីនាំមុខ នៅក្នុងមធ្យោបាយដំណោះស្រាយក្រៅប្រព័ន្ធតុលាការនោះ ។ អង្គភាពគាំពារជនរងគ្រោះបានប្រមើលមើលថា គម្រោងនោះមិនត្រូវបានដាក់ឲ្យប្រតិបត្តិឡើយ ដោយសារសំណងអាចបង្វែរទៅជាចំណាត់ការដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ដូច្នេះហើយវានៅតែជាគម្រោងដែលទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

មាននីតិវិធីផ្សេងៗទាក់ទងទៅនឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធគ្រប់គ្រងសំណង បន្ទាប់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ចប់ ។ វិធីសាស្ត្រមួយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺត្រូវដើរតួនាទីបង្កើត ទន្ទឹមពេលដែលអង្គការក្រៅរដ្ឋាភិបាលនាំមុខក្នុងការអនុវត្ត បន្ទាប់ពីសំណងត្រូវបានធ្វើឡើង ។ ក្នុងន័យនេះ ម្ចាស់ជំនួយអាចដើរតួនាទីត្រួតពិនិត្យ ដូចដែលខ្លួនធ្វើគ្រប់គម្រោងទាំងអស់ ហើយមិនមានតម្រូវការបង្កើតយន្តការសប្បទិមិត្ត ជាពិសេសតាមរយៈអង្គភាពគាំពារជនរងគ្រោះ ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យមើលគម្រោងសំណងនោះឡើយ ។ ទោះបីជា យ៉ាងណាក៏ដោយ សហមេធាវីនាំមុខជឿថា ការត្រួតពិនិត្យមើលតាមផ្លូវច្បាប់មួយចំនួន ត្រូវបានទាមទារក្នុងអំឡុងពេលដំណើរការផ្តល់សំណង ហើយសហមេធាវីនាំមុខចង់ឲ្យមានការបង្កើតអង្គភាពផ្លូវច្បាប់ ដើម្បីត្រួតពិនិត្យ និងដោះស្រាយបញ្ហាផ្លូវច្បាប់ ដែលកើតឡើងក្នុងអំឡុងពេលអនុវត្តសំណង ។ អង្គភាពគាំពារជនរងគ្រោះ ហាក់បីដូចជាគាំទ្រស្ថាប័នពាក់កណ្តាលរដ្ឋ ដើម្បីជួយដល់មូលនិធិសំណង, ផ្តល់កិច្ចការងារគម្រោងទៅអង្គការក្រៅរដ្ឋាភិបាល និងធានាថាទំនាក់ទំនងរវាងគម្រោងផ្សេងៗត្រូវបានគ្រប់គ្រងដោយអង្គភាពតែមួយ ឧទាហរណ៍ ដូចជាមូលនិធិសំណងជនរងគ្រោះ ។ ក្នុងន័យនេះ ទោះបីជាអង្គភាពគាំពារជនរងគ្រោះ និងសហមេធាវីនាំមុខ អាចមានទស្សនៈស្រដៀងគ្នាដោយឡែក ពីព្រោះនៅពេលដែលអង្គភាពគាំពារជនរងគ្រោះហាក់បីដូចជាមានការព្រួយបារម្ភក្នុងការធានាឲ្យមានថវិកាគ្រប់គ្រាន់ និងផ្តល់សំណងដល់អ្នកទទួលប្រយោជន៍ សហមេធាវីនាំមុខទំនងជានឹងផ្តោតលើការធានាឲ្យមានការត្រួតពិនិត្យតាមផ្លូវច្បាប់ និងការឆ្លើយតបទៅនឹងសំណើរបស់តុលាការ ។

ទោះបីជាយ៉ាងណាក៏ដោយ ផ្នែកជាប់ពាក់ព័ន្ធទាំងអស់មានការព្រួយបារម្ភចំពោះថវិកា ។ មានមធ្យោបាយមួយចំនួនដើម្បីស្វែងរកថវិកា ។ ទី១) នៅពេលដែលមូលនិធិសំណងត្រូវបានគាំទ្រដោយ អង្គភាពគាំពារជនរងគ្រោះ មូលនិធិសំណងនោះ

នឹងត្រូវបានបង្កើតឡើង ។ ទោះបីជាយ៉ាងណាក៏ដោយ មូលនិធិសំណង *(Trust Fund)* ដូចគ្នាទៅនឹងមូលនិធិសំណងជនរងគ្រោះ *(Trust Fund for Victim)* ទំនងជាខ្វះថវិកា ។ ជាទូទៅ កម្មវិធីសំណងជាក់លាក់ទំនងជាទទួលបានថវិកា ។ ប្រសិនបើមូលនិធិសំណងត្រូវបានបង្កើតឡើងក្រោមការឧបត្ថម្ភរបស់អង្គភាពគាំពារជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អាចបកស្រាយឡើងវិញនៅអាណត្តិរបស់ខ្លួន ដើម្បីដាក់បញ្ចូលការត្រួតពិនិត្យដំណើរការផ្តល់សំណង ដូចដែលតុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើនៅក្នុងសំណុំរឿងឡូបានហ្គា ។ ទី២) តុលាការអាចស្នើថា ប្រទេសកម្ពុជាគួរតែដើរតាមប្រទេសដទៃដែលងើបចេញពីជម្លោះ ហើយបង្កើតគណៈកម្មាធិការចេញពីសង្គមស៊ីវិល ឬរដ្ឋាភិបាលដែលធ្វើការសម្រេចចិត្ត ក្នុងការត្រួតពិនិត្យមើលសំណង ព្រមទាំងគ្រប់គ្រងការរួមចំណែកដល់កម្មវិធីសំណង ។ តួនាទីទាំង២នេះ អាចត្រូវបានបំបែកចេញពីគ្នា រួមមានការរៃអង្គាសថវិកា និងការត្រួតពិនិត្យដើម្បីធានាភាពស្របច្បាប់ ។ ប្រសិនបើមានឬគ្មានមូល និធិសំណងជម្រើសទាំងពីរ រួមមាន មូលនិធិសំណងក្រោមជំនួយរបស់តុលាការ និងគណៈកម្មការ ដែលធ្វើការសម្រេចចិត្ត ទំនងជាមានផលវិបាកក្នុងការរៃអង្គាសថវិកា ។ កម្មវិធីសំណងដ៏ជោគជ័យ ភាគច្រើនមានថវិការបស់រដ្ឋ ដោយសារថវិកាអន្តរជាតិ ទំនងជាមានតិចតួច ។

ឃ) ជម្រើសទី១) តុលាការអាចបង្ហាញអង្គភាពគាំពារជនរងគ្រោះ បន្ទាប់ពីមូលនិធិសំណងជនរងគ្រោះត្រូវបានបង្កើតឡើងដោយមូលនិធិសំណង និងការបង្កើនការត្រួតពិនិត្យលើរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើអង្គភាពគាំពារជនរងគ្រោះ ។

ការបង្កើតមូលនិធិសំណងសម្រាប់ជនរងគ្រោះដែលស្រដៀងគ្នាទៅនឹងមូលនិធិសំណងសម្រាប់ ជនរងគ្រោះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានលើកឡើងចំណុចជាច្រើននៅក្នុងកិច្ចដំណើរ នីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មូលនិធិសំណង ត្រូវបានស្នើឡើងនៅក្នុងសំណុំរឿង ០០១តាំងពីដំបូង ។ ឧទាហរណ៍នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូល បានធ្វើការទទួលស្គាល់អំពីលទ្ធភាព ដែលមូលនិធិសំណងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចជួយដោះស្រាយកង្វល់របស់តុលាការអំពីភាពជាក់លាក់ និងការបង្គាប់ ។ ទាក់ទងទៅនឹងសំណើសុំសំណងសម្រាប់ជំនួយផ្នែកវេជ្ជសាស្ត្រដល់ជនរងគ្រោះ តុលាការបានកត់សម្គាល់ថា ដំណោះស្រាយដែលអាចធ្វើទៅរួច អាចជាការបង្កើតមូលនិធិសំណងដែលមានការជួយទំនុកបម្រុងពីខាងក្រៅ ដែលជាកិច្ចការងាររដ្ឋបាលចំពោះការអនុវត្តចំណាត់ការ ។ ការបង្កើតមូលនិធិសំណង ហួសពីដែនសមត្ថកិច្ចផ្តល់សំណងរបស់តុលាការនៅក្នុងសំណុំរឿង០០១ (ដោយសារការបង្កើតមូលនិធិសំណង មិនត្រូវបានគាំទ្រដោយជនជាប់ចោទ) ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារការកែប្រែដែលបានធ្វើឡើងនៅក្នុងវិធានផ្ទៃក្នុង នៅចំពោះមុខសំណុំរឿង ០០២ បច្ចុប្បន្នសំណងអាចត្រូវបានផ្តល់ថវិកា ពីប្រភពខាងក្រៅ ។ ដូច្នេះហើយ អង្គជំនុំជម្រះតុលាការកំពូលបានជំរុញឲ្យដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០២ ស្វែងរកការបង្កើតមូលនិធិសំណងថាជាសំណងតាមរយៈប្រព័ន្ធ ដែលត្រូវបានធ្វើវិសោធនកម្ម ។ ទន្ទឹមពេលដែលសហមេធាវីនាំមុខបានដាក់បញ្ចូលសំណើសំណងសម្រាប់មូលនិធិសំណងនៅក្នុងសំណុំរឿង ០០២ សហមេធាវីនាំមុខនោះបានទម្លាក់ចោលសំណើដោយទទួលការបញ្ជាក់ពីតុលាការថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងមិនបង្កើតមូលនិធិសំណងនោះឡើយ ។ អង្គភាពគាំពារជនរងគ្រោះបានចាប់ផ្តើមបោះជំហានទៅមុខបង្កើតមូលនិធិសម្រាប់ជនរងគ្រោះ ថាជាចំណាត់ការដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ប៉ុន្តែវាមិនទំនងជាថា មូលនិធិនឹងមិនកើតឡើងមុនពេលសេចក្តីសម្រេចនៅក្នុងសំណុំរឿង០០២ធ្វើឡើង ។ ទន្ទឹមពេលដែលសំណើសុំវិភាគទានត្រូវបានដាក់ចេញ អង្គភាពគាំពារជនរងគ្រោះបានទទួលថវិកាគម្រោងតិចជាង២ភាគរយ ដែលចាំបាច់ត្រូវផ្តល់ដល់មូលនិធិ ។ ទោះបីជាយ៉ាងណាក៏ដោយ ទាំងមូលនិធិសំណងដែលបង្គាប់ដោយតុលាការ ឬមូលនិធិជនរងគ្រោះនៃចំណាត់ការដំណោះស្រាយក្រៅប្រព័ន្ធតុលាការនឹងផ្តល់ឲ្យតុលាការនូវលទ្ធភាពបន្ថែមដើម្បីចេញសេចក្តីសម្រេចលើសំណងដ៏សមហេតុផល នៅក្នុងសំណុំរឿង០០២ ។ មូលនិធិសំណងជនរងគ្រោះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាវិធីសាស្ត្រដែលសមស្រប

បំផុត ដើម្បីធ្វើការអនុវត្ត និងការបង្កើតមូលនិធិសំណងដែលផ្សារភ្ជាប់ទៅនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

មូលនិធិសំណងសម្រាប់ជនរងគ្រោះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាអង្គភាពដាច់ដោយឡែក ។ ដោយអនុលោមតាមមាត្រា៧៩ នៃលក្ខន្តិកទីក្រុងរ៉ូម “មូលនិធិសំណងត្រូវតែបង្កើតឡើងដើម្បីផ្តល់អត្ថប្រយោជន៍ដល់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មនៅក្នុងវង្វង់យុត្តាធិការរបស់តុលាការ និងផ្តល់អត្ថប្រយោជន៍ដល់គ្រួសាររបស់ជនរងគ្រោះ ។ អង្គភាពគាំពារជនរងគ្រោះមានលក្ខណៈស្រដៀងគ្នាទៅនឹងមូលនិធិសំណងជនរងគ្រោះ ប៉ុន្តែមិនមែនជាស្ថាប័នដែលមានលក្ខណៈស្របគ្នានោះឡើយ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចង់ឲ្យអង្គភាពគាំពារជនរងគ្រោះដើរតាមគំរូរបស់មូលនិធិសំណងជនរងគ្រោះនោះ ការកែប្រែដ៏សំខាន់មួយចំនួននឹងត្រូវធ្វើឡើង ។ ជាពិសេស អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងត្រូវបង្កើតមូលនិធិសំណងក្រោមការជួយឧបត្ថមរបស់អង្គភាពគាំពារជនរងគ្រោះ ហើយត្រូវបង្កើតយន្តការត្រួតពិនិត្យរបស់តុលាការដើម្បីធានាថា ផ្នែកនោះមានអាណត្តិរបស់ខ្លួន ។ ដើម្បីយល់ដឹងកាន់ច្បាស់អំពីភាពស្រដៀងគ្នារវាងអង្គភាព គាំពារជនរងគ្រោះ និងមូលនិធិសំណងជនរងគ្រោះ ផ្នែកខាងក្រោមនឹងផ្តល់សេចក្តីសង្ខេបនៃអាណត្តិរបស់មូលនិធិសំណងជនរងគ្រោះ រចនាសម្ព័ន្ធការងារ និងគ្រប់គ្រង ។

មូលនិធិសំណងជនរងគ្រោះមានអាណត្តិ២ ។ ទី១) មូលនិធិសំណងជនរងគ្រោះ មានអាណត្តិ សំណងទៅតាមអ្វីដែលខ្លួនអនុវត្តសំណងដែលបង្គាប់ដោយតុលាការ ។ សំណងអាចត្រូវបានផ្តល់ជាថវិកាដែលចុងចោទផ្តល់ លើការខូចខាត ឬតាមរយៈវិភាគទានដោយស្ម័គ្រចិត្តរបស់ម្ចាស់ជំនួយ ។ ប្រភពថវិកាផ្នែកខាងក្រៅសម្រាប់មូលនិធិសំណងជនរងគ្រោះ មានភាពស្រដៀងគ្នាទៅនឹងប្រភពថវិកាផ្នែកខាងក្រៅរបស់អង្គភាពគាំពារជនរងគ្រោះ ។ ទោះបីជាយ៉ាងណាក៏ដោយ មិនដូចគ្នាទៅនឹងអង្គភាពគាំពារជនរងគ្រោះ មូលនិធិសំណងជនរងគ្រោះមានការកម្រិតដ៏សំខាន់ដល់សមត្ថភាពរបស់ម្ចាស់ជំនួយក្នុងការសម្រេចលើថវិកាសម្រាប់គម្រោងជាក់លាក់ ។ រដ្ឋាភិបាលមិនអាចធ្វើសេចក្តីសម្រេចលើវិភាគទាននោះឡើយ ហើយម្ចាស់ជំនួយដទៃអាចធ្វើសេចក្តីសម្រេចលើថវិកាបដិភាគ រហូតដល់មួយភាគបី នៅពេលដែលលក្ខខណ្ឌផ្សេងៗអាចត្រូវបានឆ្លើយតប ។ ការដាក់កម្រិតលើការសម្រេចចិត្ត ធានាថា មូលនិធិសំណងជនរងគ្រោះ ជាដាងម្ចាស់ជំនួយបានរក្សាសិទ្ធិយ៉ាងសំខាន់សម្រាប់ការបង្កើតកម្មវិធីសំណង ។ ទី២) មូលនិធិសំណងជនរងគ្រោះ មានអាណត្តិជំនួយទូទៅតាមរយៈអ្វីដែលមូលនិធិ សំណងជនរងគ្រោះផ្តល់ការស្តារសម្បទាផ្នែករាងកាយ និងប្រាជ្ញា ហើយជួយគាំទ្រផ្នែកសម្ភារដល់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មនៅក្នុងវង្វង់យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនោះទេ ។ ដោយមានភាពស្រដៀងគ្នាទៅនឹងមធ្យោបាយក្រៅប្រព័ន្ធតុលាការរបស់អង្គភាពគាំពារជនរងគ្រោះ គម្រោងជំនួយទូទៅអាចត្រូវបានផ្តល់ដោយវិភាគទានស្ម័គ្រចិត្ត ។ ក្រៅពីនេះ ហើយស្រដៀងគ្នា ទៅនឹងចំណាត់ការដំណោះស្រាយក្រៅប្រព័ន្ធតុលាការ គម្រោងជំនួយទូទៅ អាចត្រូវបានអនុវត្តមុនពេលការបញ្ចប់សវនាការ ហើយមិនមានការកម្រិតដល់ការចូលរួមរបស់ជនរងគ្រោះនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ គម្រោងជំនួយទូទៅជួយបង្កើតក្របខ័ណ្ឌប្រតិបត្តិសម្រាប់សំណងដែលបង្គាប់ដោយតុលាការ ព្រមទាំងជួយប្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិអំពីតម្រូវការរបស់ជនរងគ្រោះ ។ បច្ចុប្បន្ន ក្នុងចំណោមគម្រោងដែលត្រូវបានយល់ស្របទាំង៣៨របស់មូលនិធិសំណងជនរងគ្រោះ ស្ថិតនៅក្រោមបន្ទុកជំនួយទូទៅ ។

មូលនិធិសំណងជនរងគ្រោះ ធ្វើការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល, សហគមន៍, អ្នកជំនាញ, រដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ។ មូលនិធិសំណងជនរងគ្រោះ ប្រើប្រាស់ប្រព័ន្ធពាក់កណ្តាល កិច្ចសន្យា ក្នុងការអនុវត្តគម្រោងសំណង ។ ម៉្យាងវិញទៀត មូលនិធិសំណងជនរងគ្រោះបានផ្តល់ជំនួយដល់អង្គការក្រៅរដ្ឋាភិបាល ដែលបានប្រតិបត្តិការរួចហើយនោះ ឬមានបទពិសោធដោះស្រាយគ្រោះថ្នាក់ជាក់លាក់ ដែលមូលនិធិសំណងជនរងគ្រោះសង្ឃឹមថានឹងដោះស្រាយ ។ មុនពេលផ្តល់ជំនួយមូលនិធិសំណងជនរងគ្រោះបានធ្វើការវាយតម្លៃដើម្បីធានាថាគម្រោងនោះដោះស្រាយ ដោយផ្ទាល់នូវការខូចខាតដែលបណ្តាលមកពីជម្លោះ ប្រសិនបើតុលាការមានយុត្តាធិការសំដៅទៅរកជនរងគ្រោះ ។ មូលនិធិសំណងជនរងគ្រោះ ទទួលយកសំណើពីអង្គការ

ដែលមានជំនាញក្នុងផ្នែកនោះ និងធ្វើការពិចារណាលើសំណើទាំងនោះនៅពេលដែលផ្តល់ជំនួយ ។ ជនរងគ្រោះត្រូវបាន ផ្តល់តួនាទីបង្កើត, អនុវត្ត, គ្រប់គ្រងសំណង និងជំនួយ ។ ប្រសិនបើតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រេចចិត្តបង្គាប់សំណងសមូហភាព តុលាការអាចបង្គាប់ថា សំណងត្រូវតែធ្វើឡើងតាមរយៈមូលនិធិសំណង ហើយបន្ទាប់មកសំណងអាចប្រគល់ឲ្យអង្គការអន្តររដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការជាតិ ។

ទន្ទឹមពេលដែលអង្គភាពគាំពារជនរងគ្រោះ គឺជាអង្គភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មូលនិធិសំណងជនរងគ្រោះអាចត្រូវបានចាត់ចែងដោយឡែកពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ភាគីជាប់ពាក់ព័ន្ធអាចមានអំណាចទាំងស្រុងលើមូលនិធិសំណងជនរងគ្រោះ ។ មូលនិធិសំណងជនរងគ្រោះ មាននាយកគ្រប់គ្រងដែលមានសមាជិកប្រាំរូប ដែលជ្រើសតាំងដោយភាគី ជាប់ពាក់ព័ន្ធសម្រាប់រយៈពេលបីឆ្នាំ តាមរយៈអគ្គលេខា ។ ក្នុងឆ្នាំ២ ០ ០ ៥ ភាគីជាប់ពាក់ព័ន្ធបានបង្កើតបទបញ្ញាសម្រាប់មូលនិធិសំណងជនរងគ្រោះ ។ ច្បាប់ទាំងនេះកំណត់ការគ្រប់គ្រង និងការត្រួតពិនិត្យមើលមូលនិធិសំណងជនរងគ្រោះ សកម្មភាព និងគម្រោងរបស់មូលនិធិសំណងជនរងគ្រោះ និងតម្រូវការអំពីរបាយការណ៍របស់មូលនិធិសំណងជនរងគ្រោះ ។ ក្រៅពីនេះ បទបញ្ញានោះផ្តល់នូវ ក្របខ័ណ្ឌច្បាប់លម្អិតទាក់ទងទៅនឹងអាណត្តិសំណង និងអាណត្តិជំនួយទូទៅ ។ បទបញ្ញាអាចបម្រើជាគំរូក្នុងការធ្វើកំណែទម្រង់អង្គភាពគាំពារជនរងគ្រោះដើម្បីធ្វើឲ្យកាន់តែស្របទៅនឹងនីតិវិធីនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយដើម្បីធ្វើឲ្យកាន់តែមានប្រសិទ្ធភាពដល់ការបំពេញអាណត្តិរបស់សំណងរបស់ខ្លួន ។

ក្នុងសំណុំរឿងឡូបានហ្គា តុលាការព្រហ្មទណ្ឌអន្តរជាតិបានប្រមើលមើលការបង្កើតគម្រោងសំណង បន្ទាប់ពីការធ្វើជំនុំជម្រះដោយមូលនិធិសំណងជនរងគ្រោះ ។ នៅក្នុងវង្វង់គោលការណ៍នៅក្នុងសំណុំរឿងឡូបានហ្គា តុលាការព្រហ្មទណ្ឌអន្តរជាតិបានផ្តល់អនុសាសន៍ថា ក្រុមអ្នកជំនាញផ្សេងៗរួមមានអ្នកតំណាងរដ្ឋាភិបាល អ្នកជំនាញផ្នែកសំណង គួរតែត្រូវបានបង្កើតឡើង ដើម្បីវាយតម្លៃអំពីការខូចខាតដែលជនរងគ្រោះទទួលរង ហើយដើម្បីកំណត់ទម្រង់ដ៏សមស្របបំផុតនៃសំណង ដោយមានការពិគ្រោះយោបល់ជាមួយនឹងជនរងគ្រោះ ។ អ្នកជំនាញទាំងនេះមានកាតព្វកិច្ចជួយរៃអង្គាសថវិកាសម្រាប់ការអនុវត្តសំណង ។ តុលាការបានផ្ទេរកាតព្វកិច្ចជ្រើសរើសអ្នកជំនាញ និងត្រួតពិនិត្យមើលការងាររបស់ខ្លួនចំពោះមូលនិធិសំណងជនរងគ្រោះ ។ តុលាការបានគាំទ្រផែនការអនុវត្តសំណងប្រាំជំហាន ដែលបង្កើតឡើងដោយមូលនិធិសំណងជនរងគ្រោះ រួមមាន ក) ការកំណត់ទីតាំងដែលជាប់ពាក់ព័ន្ធក្នុងដំណើរការសំណង ខ) ការប្រឹក្សាយោបល់ជាមួយនឹងទីតាំងដែលបានកំណត់ គ) វាយតម្លៃវិសាលភាពការខូចខាត ឃ) ការធ្វើការពិភាក្សាដេញដោលជាមួយនឹងជនរងគ្រោះ ដើម្បីពន្យល់អំពីគោលការណ៍ និងនីតិវិធីសំណង ង) ប្រមូលសំណើសំណង និងបង្ហាញសំណើទៅអង្គជំនុំជម្រះដើម្បីធ្វើសេចក្តីសម្រេច ។

ប្រសិនបើអង្គភាពគាំពារជនរងគ្រោះ ត្រូវបានយកធ្វើជាគំរូក្រោយពីមានមូលនិធិសំណងជនរងគ្រោះ គម្រោងទាំងអស់នឹងត្រូវឆ្លងកាត់ផ្នែកនោះ ។ អង្គភាពគាំពារជនរងគ្រោះ នឹងត្រួតពិនិត្យមើលប្រព័ន្ធពាក់កណ្តាលកិច្ចសន្យា ដូចគ្នាទៅនឹងប្រព័ន្ធរបស់មូលនិធិសំណងជនរងគ្រោះ ប្រសិនបើ អង្គភាពគាំពារជនរងគ្រោះទទួលខុសត្រូវគ្រប់គ្រងថវិកា ដោយទទួលយកសំណើគម្រោង និងបន្ទាប់មក ត្រួតពិនិត្យមើលការអនុវត្តតាមរយៈដៃគូ ។ អត្ថប្រយោជន៍នៃគម្រោងនេះ គឺថាមានប្រព័ន្ធដ៏ច្បាស់ លាស់សម្រាប់ត្រួតពិនិត្យមើល ហើយគម្រោងទាំងអស់ត្រូវស្ថិតក្រោមការគ្រប់គ្រងតាមយន្តការតែមួយ ដោយធានាឲ្យមានភាពប្រទាក់ក្រឡាទៅនឹងដំណើរការសំណងទាំងមូល ។ ក្រៅពីនេះ ក្នុងនាមជា ផ្នែកមួយនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គភាពគាំពារជនរងគ្រោះត្រូវរាយការណ៍ទៅតុលាការ ។ តុលាការធ្លាប់បង្គាប់ដោយផ្ទាល់ប្រឆាំងទៅនឹងអង្គភាពមួយចំនួនរបស់ខ្លួន ។ អង្គភាពគាំពារជនរងគ្រោះមានបទពិសោធជាមួយនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ប្រព័ន្ធច្បាប់ និងតម្រូវការសំណង ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានអំណាចចេញបង្គាប់អង្គជំនុំជម្រះផ្សេងៗ បំពេញកាតព្វកិច្ច ។

វាជាការគួរឲ្យចាប់អារម្មណ៍ក្នុងការគាំទ្រមូលនិធិសំណងដែលយកគំរូតាមតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយត្រូវអង្គភាព

គាំពារជនរងគ្រោះចាត់ទុកថាជាដំណោះស្រាយដ៏សមស្របបំផុត ។ ទោះបីជាយ៉ាងណាក៏ដោយ បរិបទប្រទេសកម្ពុជា ខុសពីបរិបទរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយមិនមែនដោយសារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានអាណត្តិកំណត់របស់ខ្លួននោះទេ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានផ្ទេរកាតព្វកិច្ចមួយចំនួនទៅមូលនិធិសំណងជនរងគ្រោះ ពីព្រោះតុលាការព្រហ្មទណ្ឌអន្តរជាតិជឿថា មូលនិធិសំណងជនរងគ្រោះ បានស្តែងឲ្យឃើញសមត្ថភាពរបស់ខ្លួនក្នុងការត្រួតពិនិត្យមើលដំណើរការផ្តល់សំណងតាមរយៈការបញ្ចប់អាណត្តិផ្តល់ជំនួយដោយជោគជ័យ ។ តុលាការបានផ្សារភ្ជាប់បទពិសោធនៃមូលនិធិសំណងជនរងគ្រោះ ក្នុងការអនុវត្តគម្រោងនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ហើយបានកត់សម្គាល់ថា បទពិសោធនេះបានធ្វើឲ្យមូលនិធិសំណងជនរងគ្រោះដឹកនាំដំណើរការសំណងបានយ៉ាងប្រសើរ ។ម៉្យាងវិញទៀត អង្គភាពគាំពារជនរងគ្រោះមិនបានចាប់ផ្តើមអនុវត្តចំណាត់ការដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ។ មានការព្រួយបារម្ភមួយចំនួនអំពីការ បន្តរឿងនយោបាយ និងការវិវត្តនៅអង្គភាពគាំពារជនរងគ្រោះ ។ តាមការអនុវត្តសហមេធាវីនាំមុខ បានដើរតួនាទីនាំមុខក្នុងការបង្កើតសំណងក្នុងសំណុំរឿង០០២ ។ អង្គភាពគាំពារជនរងគ្រោះបានចាប់ផ្តើមអនុវត្តចំណាត់ការដំណោះស្រាយក្រៅប្រព័ន្ធតុលាការមួយចំនួន ហើយថ្មីៗនេះទទួលបានអំណាចចាប់ផ្តើមអនុវត្តសំណងមុនការបង្គាប់របស់តុលាការ ។ ទោះបីជាយ៉ាងណាក៏ដោយ ការវិវឌ្ឍមានសភាពយឺតយ៉ាវ ។ ដោយសារការព្រួយបារម្ភអំពីសមត្ថភាពរបស់អង្គភាពគាំពារជនរងគ្រោះដើម្បីអនុវត្ត គម្រោងឲ្យមានប្រសិទ្ធភាព និងការមិនមានចេតនាធ្វើការងារក្រោមក្របខណ្ឌរបស់អង្គភាពគាំពារជនរងគ្រោះ អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានធ្វើកិច្ចព្រមព្រៀងជាមួយនឹងអង្គភាពគាំពារជនរងគ្រោះ ដើម្បីធានាថា ប្រសិនបើសំណងមិនត្រូវបានធ្វើឡើង គម្រោងនោះមិនបានបង្វែរទៅរកចំណាត់ការដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ហើយបានក្លាយជាគម្រោងឯករាជ្យស្ថិតក្រោមសមត្ថកិច្ចរបស់អង្គការក្រៅរដ្ឋាភិបាល ។ ការព្រួយបារម្ភជាបន្តបន្ទាប់មួយគឺថាវិធានផ្ទៃក្នុងទាមទារថា សហមេធាវីនាំមុខគួរតែមានអ្នកតំណាងអន្តរជាតិម្នាក់ និងអ្នកតំណាងជាតិម្នាក់ ។ សហមេធាវីនាំមុខអន្តរជាតិ និងសហមេធាវីជាតិ ត្រូវបានទាមទារឲ្យធ្វើការងាររួមគ្នា ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គភាពគាំពារជនរងគ្រោះមិនបានទាមទារឲ្យមេធាវីធ្វើការងារនៅក្នុងវង្វង់អង្គភាពនោះឡើយ ឬទាមទារឲ្យអង្គភាពមានបុគ្គលិកអន្តរជាតិ ។ ក្រៅពីនេះ អង្គភាពគាំពារជនរងគ្រោះនៅតែខ្វះថវិកា ។ សម្រាប់មនុស្សមួយចំនួន តុលាការស័ក្តិសមព្យាយាមបង្កើតអង្គភាពថ្មី ជាជាងព្យាយាមបង្កើតអង្គភាពគាំពារជនរងគ្រោះឲ្យទៅជាមូលនិធិសំណងជនរងគ្រោះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលជាអ្វីមួយដែលអ្នករិះគន់មិនគិតថា វាអាចកើតឡើង ។

ទោះបីជាយ៉ាងណាក៏ដោយ វាអាចទៅរួចដែលអង្គភាពគាំពារជនរងគ្រោះ អាចបំពេញតួនាទីស្រដៀងគ្នា ថាជាមូលនិធិសំណងជនរងគ្រោះ ប្រសិនបើការត្រួតពិនិត្យរបស់តុលាការគ្រប់គ្រាន់ត្រូវបានធ្វើឡើង ។ សូម្បីតែនៅក្នុងសំណុំរឿងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយមានមូលនិធិសំណងជនរងគ្រោះ និងដោយមានបទពិសោធអនុវត្តគម្រោងនៅក្នុងសហគមន៍ ដែលប៉ះពាល់ដោយអំពើឧក្រិដ្ឋកម្មនៅក្នុងតុលាការ តុលាការព្រហ្មទណ្ឌអន្តរជាតិយល់ឃើញការត្រួតពិនិត្យរបស់តុលាការមានសារសំខាន់ ។ ដូចគ្នាទៅនឹងលក្ខន្តិកៈអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មិនបានផ្តល់ព័ត៌មានទៅនឹងអ្វីដែលអង្គភាពមានគោលបំណងត្រួតពិនិត្យមើលដំណើរការផ្តល់សំណងនោះឡើយ ។ មូលនិធិសំណងជនរងគ្រោះមានកាតព្វកិច្ចដោះស្រាយសំណង ទន្ទឹមពេលដែលអង្គជំនុំជម្រះនឹងត្រួតពិនិត្យមើលការងាររបស់មូលនិធិសំណងជនរងគ្រោះ ព្រមទាំងដោះស្រាយបញ្ហាមួយចំនួន ដែលលើកឡើងជុំវិញការងាររបស់មូលនិធិសំណងជនរងគ្រោះ ។ អង្គជំនុំជម្រះកត់សម្គាល់ថា ខ្លួននឹងមិនចេញបង្គាប់បន្ថែមណាមួយ ឬការណែនាំដល់មូលនិធិសំណងជនរងគ្រោះស្តីពីការអនុវត្តសំណង ដែលផ្តល់ថវិកាដោយថវិកាបដិភាគស្ម័គ្រចិត្ត ។ តុលាការបានប្រមើលមើលថា ដំណើរការនេះនឹងត្រូវបានត្រួតពិនិត្យ ហើយគ្រប់គ្រងដោយក្រុមនាយកគ្រប់គ្រងរបស់មូលនិធិ សំណងជនរងគ្រោះ ។ ***(នៅមានត)***

**ត្រីស្ទីន ប័រត័រលី**

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយ នៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបញ្ចប់សវនាការដេញដោលកាលពីខែតុលា ឆ្នាំ២០១៣ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងទៅនិងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការនិងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិនិងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញនិងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី "សហកម្មខក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "Join Criminal Enterprise" ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម "ផែនការខក្រិដ្ឋរួម" ដែលភាសាអង់គ្លេសហៅថា "Common Criminal Plan" ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

**ភ៉ាន់ថាន់ ពៅដារ៉ា**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល : truthpechet@dccam.org ។

**◆ទីកន្លែង : អាគារ "ក" ជាន់លើ ◆ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthphalla.c@dccam.org ។





















# ការអនុវត្តវិធាននៃភស្តុតាងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## សេចក្តីផ្តើម

នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ទាំងនៅតុលាការអន្តរជាតិ និងតុលាការក្នុងស្រុក ភស្តុតាង ជាធាតុសំខាន់បំផុតដែលចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវពឹងផ្អែកលើដើម្បីយកមកធ្វើការពិចារណា និងធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តីរបស់ខ្លួន ។ ដើម្បីដាក់បុគ្គលណាម្នាក់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌ ចាំបាច់ត្រូវមានភស្តុតាងគ្រប់គ្រាន់ និងអាចគួរឲ្យជឿជាក់បាន ដើម្បីបង្ហាញថាបុគ្គលរូបនោះពិតជា បានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ ។ ភស្តុតាងដែលនឹងត្រូវលើកយកមកបង្ហាញនៅក្នុងតុលាការ ចាំបាច់ត្រូវតែមានភាពជាប់ពាក់ព័ន្ធរវាងបុគ្គលដែលជាអ្នកប្រព្រឹត្ត និងឧក្រិដ្ឋកម្មដែលបានកើតឡើង ជាពិសេសភស្តុតាងនោះត្រូវតែបង្ហាញឲ្យចៅក្រមមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

ដើម្បីធានាថា ភស្តុតាង ដែលនឹងត្រូវដាក់ជូនតុលាការ ដើម្បីធ្វើការពិចារណា ជាភស្តុតាងដែលមានភាពជាប់ពាក់ព័ន្ធ និងមានភាពគួរឲ្យជឿជាក់បាន ចាំបាច់ត្រូវមាន វិធាននៃភស្តុតាង ។ វិធាននៃភស្តុតាង បានកំណត់អំពីឆន្ទានុសិទ្ធិរបស់ចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះ ក្នុងការសម្រេចទទួលយក ឬបដិសេធ រាល់ភស្តុតាងទាំងឡាយដែលភាគីនៃរឿងក្តីដាក់ជូនតុលាការ ដោយផ្អែកលើភាពជាប់ពាក់ព័ន្ធ និងភាពគួរឲ្យជឿជាក់បាននៃភស្តុតាងទាំងនោះ ។ វិធាននៃភស្តុតាង អាចជះឥទ្ធិពលទៅដល់លទ្ធផលនៃ ការសម្រេចចិត្តរបស់តុលាការ ព្រោះវិធាននេះត្រូវបានយកទៅអនុវត្តសម្រាប់គ្រប់គ្រងលើភស្តុតាង ទាំងឡាយដែលប្រើប្រាស់ដោយព្រះរាជអាជ្ញា ឬមេធាវីការពារក្តីឲ្យជនជាប់ចោទ ។

វិធាននៃភស្តុតាងដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នៅត្រង់មាត្រា៣២១ ហាក់បីដូចជាពុំបានចែងលម្អិតអំពីនីតិវិធីនៃការទទួលយកភស្តុតាង ហើយអត្ថន័យនៃ វិធាននេះទៀតសោត នៅមានលក្ខណៈចង្អៀត ពុំទាន់អាចយកទៅអនុវត្តបាននៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលមានលក្ខណៈស្មុគស្មាញ និងធំធេង ដូចជាករណីឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហមដែលមានភស្តុងតាងយ៉ាងច្រើនលើសលប់ ដែលដាក់ជូនដោយភាគីរង់ចាំអង្គជំនុំជម្រះធ្វើការវាយតម្លៃអំពីភាពជាប់ពាក់ព័ន្ធនិងភាពអាចជឿជាក់បាន ។ ផ្ទុយពីក្រមនីតិវិធីព្រហ្មទណ្ឌ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅត្រង់មាត្រា៨៧ស្តីពីវិធាននៃភស្តុតាង បានចែងលម្អិតអំពីគោលការណ៍នីតិវិធី នៃការទទួលយកភស្តុតាងដាក់ចូលក្នុងសំណុំរឿង និងបុព្វសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការវាយតម្លៃអំពីតម្លៃ និងទម្ងន់នៃភស្តុតាង ។ ដោយសារតែភស្តុតាងនៃឧក្រិដ្ឋកម្មដែលកើតឡើងក្នុងរបបខ្មែរក្រហម មានចំនួនច្រើនលើសលប់ ដូច្នេះការចែងលម្អិតអំពីវិធាននៃភស្តុតាងនឹងអាចអនុញ្ញាតឲ្យអង្គជំនុំជម្រះ ងាយស្រួលក្នុងការកំណត់ថា តើភស្តុតាងណាដែលមានភាពជាប់ពាក់ព័ន្ធ និងមានភាពគួរឲ្យជឿជាក់បាន និងភស្តុតាងប្រភេទណាគួរត្រូវបានបដិសេធ ។

ចំណុចខាងក្រោម នឹងបង្ហាញអំពីការអនុវត្តវិធាននៃភស្តុតាងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងប្រភេទនៃភស្តុតាងដែលមាននៅក្នុងសំណុំរឿង ។

### ១) ការទទួលយកភស្តុតាង

វិធាន៨៧(១) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា «លើកលែងតែមានបញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវទទួលយក» ។ វិសាលភាពនៃគោលការណ៍ទូទៅនេះត្រូវបានបញ្ជាក់ដោយវិធាន៨៧(២) នៃវិធានផ្ទៃក្នុង ដែលបានចែងបន្ថែមថា «សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវតែផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល» ។ វិធាន៨៧(៣) នៃវិធានផ្ទៃក្នុងបាន

បង្ហាញថា ភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿងត្រូវបានចាត់ទុកថា បានលើកឡើង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ឬត្រូវបានអាននៅក្នុងសវនាការ ។

ទោះបីជាពាក្យពេចន៍នៃវិធាន៨៧(៣) សំដៅទៅលើភ័ស្តុតាងដែលយកមកពីក្នុងសំណុំរឿង ក៏ដោយ ក៏ខ្លឹមសារទូទៅនៃអនុវិធានក្នុងវិធាននេះបង្ហាញឲ្យឃើញច្បាស់ថា សម្ភារទាំងអស់ដែលមាននៅក្នុងសំណុំរឿង គឺមិនមែនជា "ភ័ស្តុតាង" ទេ ប្រសិនបើសម្ភារទាំងនោះមិនត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ (ដូចជា ត្រូវបានសង្ខេប ត្រូវបានអាន ឬអាចត្រូវបានកំណត់អត្តសញ្ញាណ) ។ បន្ថែមពីលើនេះ អង្គជំនុំជម្រះអាចទទួលយកភ័ស្តុតាងថ្មី ដែលមិនមាននៅក្នុងសំណុំរឿងតាមឆន្ទានុសិទ្ធិ ឬតាមសំណើរបស់ភាគី ។ ម្យ៉ាងវិញទៀត ដើម្បីអាចយកមកប្រើប្រាស់ជាភ័ស្តុតាង សម្ភារដែលមាននៅក្នុងសំណុំរឿង ត្រូវតែបំពេញលក្ខខណ្ឌច្បាស់លាស់នៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាននៃភ័ស្តុតាង ។ ភ័ស្តុតាងចម្លង និងភ័ស្តុតាងប្រយោល អាចត្រូវបានទទួលយកទៅពិចារណាដោយអង្គជំនុំជម្រះ នៅពេលដែលភ័ស្តុតាងទាំងនោះមានភាពជាប់ពាក់ព័ន្ធ និងមានតម្លៃអាចជឿជាក់បាន ប៉ុន្តែអង្គជំនុំជម្រះនឹងធ្វើការពិចារណាជាពិសេសថា តើជនជាប់ចោទអាចតទល់នឹងប្រភពភ័ស្តុតាងបែបនោះបានដែរឬយ៉ាងណា ។ ទោះបីជាយ៉ាងណាអង្គជំនុំជម្រះអាចបដិសេធមិនយកមកធ្វើជាភ័ស្តុតាងនូវសម្ភារណាមួយ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលមានចែងក្នុងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង (ដូចជា ភាពមិនជាប់ពាក់ព័ន្ធភាពមិនសមស្របសម្រាប់បញ្ជាក់ពីអង្គហេតុដែលចោទប្រកាន់ភ័ស្តុតាងដែលមិនអាចរកបានក្នុងរយៈ ពេលសមស្រប ឬដោយសារតែអត្ថិភាពនៃការរំលោភបំពានលើបទដ្ឋានច្បាប់ជាសារវ័ន្តដែលពាក់ព័ន្ធនឹងវិធាននៃភ័ស្តុតាង) ។

ដូច្នេះ ដើម្បីអាចយកមកប្រើប្រាស់ជាភ័ស្តុតាងបានសម្ភារដែលមាននៅក្នុងសំណុំរឿងត្រូវបំពេញឲ្យបាននូវបទដ្ឋានអប្បបរមានៃភាពជាប់ពាក់ព័ន្ធ និងភាពគួរឲ្យជឿជាក់បាន ដែលចាំបាច់ដើម្បីឲ្យសម្ភារទាំងនោះអាចដាក់ដេញដោលបាននៅចំពោះមុខអង្គជំនុំជម្រះ ។ បន្ទាប់ពី សម្ភារទាំងនោះត្រូវបានដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ភាពអាចជឿជាក់បាននៃភ័ស្តុតាង និងទម្ងន់នៃភ័ស្តុតាងនឹងត្រូវវាយតម្លៃដោយអង្គជំនុំជម្រះ ប្រសិនបើភ័ស្តុតាងទាំងនោះមានប្រើប្រាស់នៅក្នុងសាលក្រម ប៉ុន្តែពុំមែនវាយតម្លៃនៅក្នុងដំណាក់កាលទទួលយកឡើយ ។ នៅពេលមានការវាយតម្លៃលើភ័ស្តុតាង ប្រសិនបើអង្គជំនុំជម្រះមាន "ភាពសង្ស័យអំពីពិរុទ្ធភាព" របស់ជនជាប់ចោទ ការបកស្រាយត្រូវតែធ្វើឡើងនៅក្នុងន័យដែលផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ ។ ការតម្រូវដូច្នេះគឺដោយសារគោលការណ៍ច្បាប់ និងវិធាន៨៧(១) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានកំណត់យ៉ាងច្បាស់ថា "ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ" ។

## ២) ប្រភេទនៃភ័ស្តុតាងដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ

សំណុំរឿងក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាសំណុំរឿងដែលមានលក្ខណៈពិសេស ដោយសារតែតុលាការនេះពុំមែនបង្កើតឡើងក្នុងគោលបំណងដើម្បីកាត់ទោសជនដែលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅអំឡុងពេលនៃរបបខ្មែរក្រហមទេ ប៉ុន្តែបង្កើតឡើងដើម្បីកាត់ជនពីរប្រភេទ គឺមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូច្នេះភ័ស្តុតាងដែលត្រូវយកមកបង្ហាញនៅចំពោះមុខតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ពុំមែនភ័ស្តុតាងជាវត្ថុដែលជនដែលយកទៅប្រព្រឹត្តឧក្រិដ្ឋកម្ម (ដូចជា កាំភ្លើង កាំបិត ពូថៅ ដំបង...) ដូចរឿងក្តីព្រហ្មទណ្ឌនៅតុលាការក្នុងស្រុកទេ ។ ភ័ស្តុតាងដែលត្រូវលើកយកមកសំអាងដើម្បីកាត់ទោសជនទាំងពីរប្រភេទខាងលើភាគច្រើនជាប្រភេទឯកសារដែលនៅសេសសល់ពីរបបកម្ពុជាប្រជាធិបតេយ្យ មានដូចជា ឯកសារជាក្រដាស រូបថត ខ្សែវីដេអូ និងបទសម្ភាសន៍ដែលបង្ហាញអំពីការទទួលខុសត្រូវ និង ខ្សែសង្វាក់នៃការបញ្ជារបស់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រៅពីនេះ សក្ខីកម្មរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលផ្តល់ជូនចៅក្រមស៊ើបអង្កេតនៅក្នុងដំណាក់កាលស៊ើបអង្កេត និងនៅក្នុងដំណាក់កាលអង្គជំនុំជម្រះសាលាដំបូង ក៏ជាប្រភពភ័ស្តុតាងដ៏សំខាន់ដែលត្រូវបានប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ដោយសារអ្នកទាំងនោះ ជាអ្នកដែលបាន

ឆ្លងកាត់ បានឃើញ បានជួបប្រទះ និងយល់ដឹងយ៉ាងច្បាស់ពីព្រឹត្តិការណ៍ដែលបានកើតឡើង ។ ដូចគ្នានេះដែរ ចម្លើយតបនានារបស់ជនជាប់ចោទអាចបង្កើតបានជាភស្តុតាងដែលតម្លៃនៃភស្តុតាងនេះ ត្រូវបានយកទៅពិចារណាដោយអង្គជំនុំជម្រះ ។ ទោះបីជាយ៉ាងណា ដើម្បីឲ្យសក្ខីកម្មរបស់សាក្សី និងអ្នកជំនាញមានតម្លៃ និងទម្ងន់ជាភស្តុតាង ការផ្តល់សក្ខីកម្មនោះចាំបាច់ត្រូវតែឆ្លងកាត់ការធ្វើសម្បថមុនពេលចូលផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ។ រីឯដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ ច្បាប់ពុំបានតម្រូវឲ្យធ្វើសម្បថនៅមុនពេលចូលផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះទេ ដោយសារតែទាំងដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ សុទ្ធតែជាភាគីនៃរឿងក្តី ហើយសក្ខីកម្មដែលត្រូវបានផ្តល់នៅតែមានតម្លៃ និងទម្ងន់ជាភស្តុតាង ។

ភាគច្រើនលើសលប់នៃឯកសារភស្តុតាងទាំងអស់ គឺបន្សល់ទុកពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវបានប្រមែប្រមូលចងក្រង និងថែរក្សាទុកដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រើប្រាស់ឯកសារទាំងនោះធ្វើជាភស្តុតាងដោយចោទប្រកាន់មេដឹកនាំ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ការទទួលយកឯកសារទាំងនោះមកធ្វើ ជាភស្តុតាង ពុំមែនធ្វើឡើងតាមរយៈការសន្មតទេ អង្គជំនុំជម្រះបានពិនិត្យ និងពិចារណាយ៉ាងយកចិត្តទុកដាក់លើខ្សែសង្វាក់នៃការរក្សាទុកឯកសារ និងយថាភាពនៃឯកសារ ដោយបានកោះអញ្ជើញប្រធាន និងអនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបញ្ជាក់លម្អិតអំពីប្រភព ខ្សែសង្វាក់នៃការរក្សាទុក និងយថាភាពនៃឯកសារត្រូវបានប្រើប្រាស់ធ្វើជាភស្តុតាងទាំងអស់នោះ ។

ក្រៅពីនេះ អង្គជំនុំជម្រះក៏បានកោះហៅសាក្សីដែលជាអ្នកថតរូប និងជាអ្នកកាសែតជនជាតិអាមេរិកាំង ដែលបានថតយករូបភាព ជាច្រើនអំពីស្ថានភាព និងព្រឹត្តិការណ៍ក្នុងទីក្រុងភ្នំពេញនៅមុន និងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៩ មកផ្តល់សក្ខីកម្មដើម្បីបញ្ជាក់អំពីរូបថតមួយចំនួនដែលបានថតនៅទីតាំងផ្សេងៗបន្ទាប់ពីខ្មែរក្រហម ចូលមកដល់ទីក្រុងភ្នំពេញ ។ ទោះបីជាយ៉ាងណា សាក្សីពុំចាំបាច់ត្រូវតែជាអ្នកថតរូបនោះទេ មានសាក្សីមួយចំនួនត្រូវបានកោះហៅចូលមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីពិពណ៌នាពីព្រឹត្តិការណ៍ និងបទពិសោធផ្ទាល់ខ្លួន និងត្រូវបានស្នើឲ្យធ្វើការបញ្ជាក់ថា តើរូបថតដែលមាននៅក្នុងសំណុំរឿងពិតជាឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ដែលបានកើតឡើងដែរឬយ៉ាងណា ។

## ៣) ការដាក់ភស្តុតាងថ្មី

នៅមុនពេលបើកសវនាការបឋម អង្គជំនុំជម្រះសាលាដំបូងតែងបានបង្គាប់ឲ្យភាគីទាំងអស់ត្រូវ ដាក់ឯកសារ និងបុបញ្ជីនានាដែលរៀបរាប់អំពីភស្តុតាងជូនអង្គជំនុំជម្រះឲ្យបានតាមពេលកំណត់ ដូចមានចែងនៅក្នុងវិធាន៨០(៣) នៃវិធានផ្ទៃក្នុង ។ ភស្តុតាង និងបញ្ជីឯកសារដែលពុំត្រូវបានដាក់តាមពេលវេលាកំណត់ នឹងត្រូវបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង លើកលែងតែភស្តុតាងនោះ ជាភស្តុតាងថ្មី ។

ភស្តុតាងថ្មី គឺជាភស្តុតាងដែលពីមុនពុំមាននៅក្នុងសំណុំរឿង ឬពុំមាននៅក្នុងបញ្ជីរបស់ភាគី ដូចដែលមានចែងនៅក្នុងវិធាន៨០(៣) នៃវិធានផ្ទៃក្នុង ។ ដើម្បីអាចដាក់ភស្តុតាងថ្មីចូលក្នុងសំណុំរឿង ភាគីទាំងអស់ ចាំបាច់ត្រូវតែគោរពតាមលក្ខខណ្ឌនៃភាពអាចទទួលយកបានដ៏តឹងរ៉ឹងនៃវិធាន៨៧(៤) នៃ វិធានផ្ទៃក្នុងដែលបានចែងយ៉ាងច្បាស់ថា ភាគីត្រូវតែបង្ហាញថា ខ្លួនបានយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងការស្វែងរក និងបង្ហាញភស្តុតាងដែលមិនអាចរកបានមុនពេលបើកការជំនុំជម្រះ ។ តាមរយៈសំណើសុំ ដែលមានសំអាងហេតុ ភាគីត្រូវបង្ហាញថា ភស្តុតាងថ្មីទាំងនេះពុំអាចរកបាននៅមុនពេលបើកការ ជំនុំជម្រះ ឬមិនអាចរកឃើញ និងពុំត្រូវបានផ្តល់ឲ្យនៅមុនពេល ទោះបីជាបានខិតខំយកចិត្តទុកដាក់ក្នុងការស្វែងរកហើយក៏ដោយ ។ ភស្តុតាងថ្មី ត្រូវតែអាចនាំដល់ការលាតត្រដាងពីការពិត និងត្រូវបំពេញលក្ខខណ្ឌនៃវិធាន៨៧(៣) នៃវិធានផ្ទៃក្នុងដែរ ។

## ៤) ការវិភាគលើឯកសារភស្តុតាងដាក់លាក់ដោយអង្គជំនុំជម្រះសាលាដំបូង

បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទទួលយកកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារឹករបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ជំនួសឲ្យការផ្តល់សក្ខីកម្មផ្ទាល់មាត់ ដោយមិនចាំបាច់ផ្តល់ឱកាសឲ្យតទល់គ្នា ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា និង ខៀវ សំផន បានធ្វើការ

ជំទាស់ជាបន្តបន្ទាប់ ។ ការជំទាស់នោះ ផ្តោតជាពិសេសលើឯកសារស្តីពី កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក ដែលបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដោយមិនចាំបាច់ស្តាប់សក្ខីកម្មសាក្សីនៃកំណត់ហេតុទាំងអស់នោះនៅក្នុងសវនាការ ។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងជំទាស់ពីមេធាវីការពារក្តី អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចទាក់ទងនឹងភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅក្នុងសំណុំរឿង០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាង ដើមបណ្តឹងរដ្ឋប្បវេណី ។ នៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះបានវិភាគលើភស្តុតាងជាក់លាក់ មួយចំនួនដូចខាងក្រោម ៖

**ក) ភស្តុតាងជាកំណត់ហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារឹក ដែលបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ**

ចំពោះកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹក ដែលនឹងបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើកលែងតែ មានអញ្ញត្រកម្មតិចតួចប៉ុណ្ណោះ ត្រូវចាត់ទុកថា «មិនអាចអនុញ្ញាតឲ្យយកមកប្រើប្រាស់តាមច្បាប់ឡើយ» ប្រសិនបើក្រុមមេធាវីការពារក្តីពុំទទួលបានឱកាសសួរដេញដោលអ្នកបានផ្តល់ចម្លើយទាំងនេះនៅក្នុងតុលាការ ។ ទោះបីជាយ៉ាងណា ក្នុងករណីដែលកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងនោះមានភាពជាប់ពាក់ព័ន្ធសម្រាប់បង្ហាញបញ្ហាផ្សេងៗ ក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបាន ចោទប្រកាន់ ហើយបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង និងអាចជា ប្រយោជន៍នៃយុត្តិធម៌ ភស្តុតាងបែបនេះអាចនឹងត្រូវទទួលយក ។

កត្តានានាដែលគាំទ្រដល់ការទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ រួមមាន ការពុំមានឱកាសពិតប្រាកដសម្រាប់តទល់គ្នាចំពោះមុខ (ដោយសារមរណភាព ការមិនមានលទ្ធភាពផ្នែកសុខភាពក្នុងការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ឬពុំមានលទ្ធភាព ទោះបីជា បានខិតខំយ៉ាងយកចិត្តទុកដាក់ក្នុងការស្វែងរកអ្នកផ្តល់ចម្លើយនោះក៏ដោយ) លក្ខណៈបញ្ជាក់នៃភស្តុតាង និងករណីថា តើភស្តុតាងទាំងនោះបានបង្ហាញពីធាតុផ្សំអប្បបរមានៃឧក្រិដ្ឋកម្មអន្តរជាតិ (ដូចជា លក្ខណៈជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំរាលដាលនៃការវាយប្រហារ) មូលដ្ឋានឧក្រិដ្ឋកម្ម ផលប៉ះពាល់លើជនរងគ្រោះ សាវតារប្រវត្តិសាស្ត្រ ឬរចនាសម្ព័ន្ធរដ្ឋបាន ។

អង្គជំនុំជម្រះនឹងធ្វើការពិចារណាអំពីតម្លៃ និងទម្ងន់នៃកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកដែលត្រូវបានទទួលយកជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ នៅពេលដែលជនជាប់ចោទពុំមានឱកាសសម្រាប់តទល់ចំពោះមុខម្ចាស់សក្ខីកម្មទាំងនោះ ។

ទោះបីជាយ៉ាងណា គ្មានអ្វីអាចរារាំងការទទួលយកកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹកដែលអាចមានភស្តុតាងពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់នោះទេ នៅពេលឯកសារទាំងនោះគ្រាន់តែត្រូវបានស្នើឡើងដើម្បីយកមកធ្វើជាមូលដ្ឋានសម្រាប់គោលបំណងនានា ក្រៅពីការបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ រួមទាំងភាពអាចទុកចិត្តបាននៃភស្តុតាងផ្សេងៗទៀត ដែលមាននៅក្នុងខ្សែអាត់ថតសំឡេង និងវីដេអូ ។

**ខ) កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹករបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ**

នៅពេលសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ពេលនោះ មេធាវីការពារក្តីនឹងមានឱកាសក្នុងការសួរតទល់ជាមួយពួកគាត់ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក ។ ដូច្នេះ ចម្លើយរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលចូលមកផ្តល់សក្ខីកម្មនោះ ពុំចាំបាច់បំពេញតាមលក្ខណៈវិនិច្ឆ័យដូចមានកំណត់នៅក្នុងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយទេ ។ ចម្លើយទាំងនោះគ្រាន់តែត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពអាចទទួលយកបានជាទូទៅ ដូចមាន ចែងក្នុងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុងក៏បានដែរ ។

កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹករបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះត្រូវបានសន្មតថា មានភាពជាប់ពាក់ព័ន្ធ និងអាចជឿជាក់

បានជាបឋម ។ បន្ថែមពីលើនេះ ដើម្បីជាប្រយោជន៍យុត្តិធម៌ កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក នឹងត្រូវយកមកពិចារណាជាមួយនឹងភស្តុតាងដទៃទៀតរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ។

**ក) កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែលបានទទួលមរណភាព**

យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបបង្ហាញថា សិទ្ធិក្នុងការពិនិត្យលើសាក្សីដែលជាផ្នែកនៃសិទ្ធិក្នុងការទទួលបាននូវការកាត់ទោសដោយយុត្តិធម៌ ជាធម្មតាបានសន្មតជាមុនថា ភស្តុតាងនឹងត្រូវនាំយកមកបង្ហាញនៅក្នុងសវនាការសាធារណៈ ដោយមានវត្តមានរបស់ជនជាប់ចោទ ដែលអាចមើល ឃើញការជជែកតទល់គ្នា ។ នៅពេលមានការលើកលែងចំពោះគោលការណ៍ទូទៅនេះតាមវិធានទូទៅ ជនជាប់ចោទត្រូវបានផ្តល់នូវឱកាសគ្រប់គ្រាន់ និងសមស្របដើម្បីផ្ទុំការជំទាស់ និងអាចសួរសំណួរទៅសាក្សីដែលប្រឆាំងនឹងខ្លួន ទាំងនៅពេលផ្តល់ចម្លើយ ឬនៅដំណាក់កាលបន្ទាប់ទៀត ។

តុលាការឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗទៀតអនុញ្ញាតឲ្យមានការប្រើប្រាស់ភស្តុតាងនៅក្នុងទម្រង់ជាកំណត់ហេតុលាយលក្ខណ៍អក្សររបស់សាក្សីដែលបានទទួលមរណភាព ឬសាក្សីដែលគេមិនអាចរកឃើញដោយការព្យាយាមសមរម្យ នៅពេលដែលភស្តុតាងនៅបានបំពេញលក្ខខណ្ឌមួយចំនួន ។ កត្តាដែលត្រូវពិចារណាថាតើត្រូវទទួលយកភស្តុតាងបែបនេះ ឬមិនទទួលយកនោះ រួមមានកាលៈទេសៈ ដែលចម្លើយនោះត្រូវបានធ្វើ និងត្រូវបានកត់ត្រាថាតើចម្លើយបើកផ្លូវឲ្យមានការសួរដេញដោលភាគី ប្រឆាំងដែលកំពុងប្រើប្រាស់ភស្តុតាងនេះដើម្បីចោទប្រកាន់ឬទេ និងថាតើចម្លើយនោះទាក់ទងនឹងព្រឹត្តិការណ៍ដែលនាំឲ្យមានភស្តុតាងផ្សេងទៀតដែរឬទេ ។ នៅពេលដែលភស្តុតាងឈានទៅរកការបង្ហាញពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នោះ នេះគឺជាកត្តាដែលប្រឆាំងនឹងភាពអាចទទួលយកបាននៃភស្តុតាងបែបនេះ ឬក៏ជាផ្នែកនៃភស្តុតាងនោះ ។

នៅក្នុងបរិបទនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលមរណភាព គឺ “អាចទទួលយកបាន” ទាំងសម្រាប់គោលបំណងក្នុងការបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់ ។ ប៉ុន្តែកំណត់ហេតុស្តាប់ ចម្លើយទាំងអស់នោះចាំបាច់ត្រូវតែមានភាពជាប់ពាក់ព័ន្ធ និងអាចជឿជាក់បានជាបឋម ឬបានគោរព តាមលក្ខខណ្ឌនៃវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង ។

ទោះបីជាកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលមរណភាព អាចទទួលយកបានដើម្បីបង្ហាញអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់ក៏ដោយ ក៏កំណត់ហេតុស្តាប់ចម្លើយទាំងអស់នោះ អាចមានតម្លៃជាភស្តុតាងតិចតួច ហើយការសម្រេចឲ្យជាប់ពិរុទ្ធភាព មិនអាចផ្អែកទាំងស្រុង ឬជាសំខាន់លើកំណត់ហេតុស្តាប់ចម្លើយទាំងនោះឡើយ ។

ទោះបីស្ថិតក្នុងករណីណាក៏ដោយ ប្រសិនបើមានការជំទាស់ពីសំណាក់មេធាវីការពារក្តីទៅលើលក្ខណៈវិនិច្ឆ័យនៃការទទួលយកភស្តុតាង ការជំទាស់នោះនឹងត្រូវទទួលបានការពិចារណាពីអង្គជំនុំជម្រះ នៅពេលមានការវាយតម្លៃពីតម្លៃ និងទម្ងន់ ប្រសិនបើកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងអស់ ដែលបានដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ត្រូវបានដាក់បញ្ចូលទៅក្នុងសាលក្រម ។

**សន្និដ្ឋាន**

សំណុំរឿង០០១ បានបិទបញ្ចប់ជាស្ថាពរ រីឯសវនាការលើសំណុំរឿង០០២ ដំណាក់កាលទី១ បានបិទបញ្ចប់ និងរង់ចាំការចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលរំពឹងថានឹងចេញនៅក្នុងអំឡុងឆមាសទី១ ឆ្នាំ២០១៤ ។ ការអនុវត្តវិធាននៃភស្តុតាងនៅក្នុងបរិបទនៃសំណុំរឿងក្តីស្មុគស្មាញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងក្លាយទៅជាបទពិសោធ និងគំរូសម្រាប់ការអនុវត្តនីតិវិធីទាក់ទងនឹងវិធានភស្តុតាងនៅក្នុងតុលាការក្នុងស្រុក ។ នាពេលអនាគត ការធ្វើវិសោធនកម្មលើវិធាននៃភស្តុតាងដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជាគួរតែត្រូវបានធ្វើឡើង ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកអនុវត្តច្បាប់ អាចអនុវត្តវិធាននេះប្រកបដោយប្រសិទ្ធភាពតាមគំរូបទដ្ឋានអន្តរជាតិ ។ **លឹម ជ័យឆ័ត្រ**

# ការថែរក្សាឯកសារសិទ្ធិមនុស្សផ្លូវការ នៅក្នុងរដ្ឋអន្តរសម័យ

## *ក្របខណ្ឌផ្លូវច្បាប់ពាក់ព័ន្ធ*

ច្បាប់អន្តរជាតិគោរពចំពោះអធិបតេយ្យភាពរបស់រដ្ឋក្នុងការគ្រប់គ្រងឯកសារផ្លូវការ និងបណ្ណសារដ្ឋានដោយចាត់ទុកថាជា «សម្បត្តិវប្បធម៌» របស់រដ្ឋដែលបានបង្កើតរបស់ទាំងនោះ ។ ច្បាប់អន្តរជាតិមិនបានដាក់បញ្ចូល ករណីពិសេសសម្រាប់ឯកសារដែលបង្កើតឡើងដោយរដ្ឋាភិបាល ដូចជារបបណាហ្ស៊ីនៅប្រទេសអាល្លឺម៉ង់ របបផ្តាច់ការយោធានៅក្នុងតំបន់អាមេរិកឡាទីន ឬរបបកុម្មុយនីស្តនៅតំបន់អឺរ៉ុបខាងកើតនិងអតីតសហភាពសូវៀតនោះទេ ។ ឯកសារពាក់ព័ន្ធរបបទាំងនោះ ត្រូវបានចាត់ទុកថាជាសម្បត្តិរបស់រដ្ឋាភិបាលបន្ត ។

ដោយស្របជាមួយនឹងគោលការណ៍ នៃភាពមិនអាចផ្លាស់ប្តូរឯកសារបាននោះ ច្បាប់អន្តរជាតិមិនបានផ្តល់មូលដ្ឋានច្បាស់លាស់ស្តីពីកម្មសិទ្ធិលើឯកសារផ្លូវការសម្រាប់អង្គភាពណាមួយក្រៅពីរដ្ឋនោះឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់អន្តរជាតិនេះអនុញ្ញាតឲ្យអង្គភាពអនុវត្ត នូវការថែរក្សាឯកសារផ្លូវការក្នុងលក្ខខណ្ឌមួយចំនួនក្រៅពីរដ្ឋ ។ កងកម្លាំងប្រដាប់អាវុធដែលក្តោបក្តាប់រដ្ឋមួយ ប្រហែលជាអាចគ្រប់គ្រងឯកសារផ្លូវការ និងបណ្ណសារដ្ឋានក្នុងអំឡុងពេលនៃក្តោបក្តាប់របស់យោធា ។ មិនមានអង្គភាពក្រៅពីរដ្ឋាភិបាលណាអាចអនុវត្តសិទ្ធិថែរក្សាឯកសារដោយមិនមានការយល់ស្របពីរដ្ឋនោះទេ ។

ច្បាប់ក្នុងស្រុករួមមានច្បាប់បណ្ណសារដ្ឋាននៅតាមបណ្តារដ្ឋមួយចំនួន បានផ្តល់អំណាចដល់រដ្ឋាភិបាល ដើម្បីទាញយកឯកសារផ្លូវការ ដែលគ្រប់គ្រងដោយអង្គភាពឯកជន និងអង្គការក្រៅរដ្ឋាភិបាល ។ ច្បាប់បណ្ណសារដ្ឋានក្នុងឆ្នាំ២០០៥ របស់ប្រទេសកម្ពុជា បានបញ្ជាក់ច្បាស់ថារដ្ឋាភិបាលអាចយក «បណ្ណសារដ្ឋានសាធារណៈ» ដែលគ្រប់គ្រងដោយអង្គភាពក្រៅរដ្ឋ ។ វាមិនច្បាស់លាស់ ដែលថាឯកសារផ្លូវការរបស់របបកម្ពុជាប្រជាធិបតេយ្យដែលគ្រប់គ្រង ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា អាចមានតម្លៃចាត់ទុកថាជា «បណ្ណសារដ្ឋានសាធារណៈ» ដោយសារច្បាប់ឆ្នាំ ២០០៥ កំណត់និយមន័យមិនច្បាស់លាស់ ។ ទោះបីជាយ៉ាងណាក៏ដោយ ពិតប្រាកដណាស់ រដ្ឋាភិបាលអាចពោលអះអាងយកឯកសារទាំងនោះដើម្បីបង្កើតជា «បណ្ណសារដ្ឋានសាធារណៈ» ហើយអាចបង្គាប់បញ្ជា ឲ្យយកឯកសារទាំងនោះត្រឡប់មកវិញ ។ ការបង្គាប់បញ្ជាបែបនោះនឹងបង្កផលវិបាកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការជំទាស់ទៅនឹងប្រព័ន្ធច្បាប់ក្នុងស្រុក ។ ករណីដូចគ្នានេះទំនងជាកើតឡើងចំពោះ អង្គការក្រៅរដ្ឋាភិបាល នៅតាមបណ្តារដ្ឋអន្តរសម័យផ្សេងៗ ។

## *គោលការណ៍សីលធម៌ទូទៅនៃបណ្ណសារដ្ឋាន*

ការកាន់កាប់របស់រដ្ឋលើឯកសារផ្លូវការនិងបណ្ណសារដ្ឋានធ្វើឡើងចំពេលដែលមាន ភាពតានតឹងចំពោះបទដ្ឋានសិទ្ធិមនុស្សនៅពេលដែលរដ្ឋខ្វះឆន្ទៈឬសមត្ថភាពជាក់ស្តែង ដើម្បីថែរក្សានិងរៀបចំ កំណត់ហេតុឬក៏គ្រប់គ្រងប្រព័ន្ធទទួលឬចែកចាយឯកសារឲ្យមានប្រសិទ្ធភាព ។ នៅក្នុងសំណេរអត្ថបទ នាពេលថ្មីនេះដែលមានចំណងជើងថាអ្នកចងក្រងឯកសារជនជាតិអាមេរិក អ្នកសិក្សាស្រាវជ្រាវ ផ្នែកឯកសារ មីឆែល កាសស៊្វែល និយាយលើកហេតុផលថាការថែរក្សាឯកសារនៅក្នុងរដ្ឋអន្តរសម័យ គួរតែត្រូវបានគ្រប់គ្រងដោយគោលការណ៍ជឿទុកចិត្តបាន ជាជាងគោលការណ៍មិនអាចផ្លាស់ប្តូរបាន ។ គាត់បានប្រើប្រាស់គំរូនៃការគ្រប់គ្រងឯកសារក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីលើកហេតុផលថា ការថែរក្សាឯកសារផ្លូវការរបស់អង្គការក្រៅរដ្ឋាភិបាលនេះគួរតែត្រូវបានចាត់ទុកថាជា ការស្របច្បាប់ហើយជាពិសេសការគួរឲ្យចង់បាន នៅពេលដែលអង្គការ

ក្រោរដ្ឋាភិបាលនេះ គឺជាអង្គភាពដ៏មានទំនុកចិត្តជាងរដ្ឋ ក្នុងការគ្រប់គ្រងឯកសារសិទ្ធិមនុស្សផ្លូវការ ។

ទោះបីជាការនិយាយយោងលើកហេតុផលនេះ នឹងបង្កាប់ពីគោលការណ៍សីលធម៌ ការនិយាយយោងលើកហេតុផលនេះ មិនបានឆ្លុះបញ្ចាំងអំពីច្បាប់ឬគោលការណ៍សីលធម៌ទូទៅនៃបណ្ណសារដ្ឋាន ដែលជាទូទៅគាំទ្រគោលការណ៍ភាពមិនអាចផ្លាស់ប្តូរបាននៃឯកសារ ។ សហគមន៍ឯកសារកាណាដានិងអាមេរិក បានរិះគន់រដ្ឋាភិបាលអាមេរិក និងមូលនិធិចងចាំប្រទេសអ៊ីរ៉ាក់ យ៉ាងខ្លាំងពីបទដកយកសំណុំឯកសារ ក្នុងរបបបាអាត របស់ សាដាម ហ៊ូសេន បន្ទាប់ពីរបបនេះត្រូវបានទម្លាក់ចេញពីអំណាច នៅក្នុងឆ្នាំ២០១៣ ព្រមទាំងកិច្ចព្រមព្រៀងរបស់មូលនិធិចងចាំប្រទេសអ៊ីរ៉ាក់ ជាមួយនឹងវិទ្យាស្ថាន ហ៊ូវែរ ដើម្បីតម្កល់កំណត់ហេតុមួយចំនួននៅទីនោះ ហើយទាមទារឲ្យមានការប្រគល់ត្រឡប់មកវិញភ្លាមៗនូវកំណត់ហេតុទាំងនោះទៅកាន់បណ្ណាល័យ និងបណ្ណសារដ្ឋានជាតិអ៊ីរ៉ាក់វិញ ។ អ្នកចងក្រងឯកសារមិនបាននិយាយយោងលើកហេតុផលថា ប្រទេសអ៊ីរ៉ាក់ មានសមត្ថភាពផ្នែក បច្ចេកទេសខ្ពស់ ក្នុងការគ្រប់គ្រងសំណុំឯកសារនោះ ប៉ុន្តែខ្លួនបានឲ្យហេតុផលថាឯកសារនោះគឺជាកម្មសិទ្ធិរបស់ប្រទេសអ៊ីរ៉ាក់ ហើយនៅពេលដែលបណ្ណាល័យនិងបណ្ណសារដ្ឋានជាតិអ៊ីរ៉ាក់ បានធ្វើការអះអាងចំពោះភាពជាកម្មសិទ្ធិនោះ ច្បាប់និងគោលការណ៍សីលធម៌ដែលត្រូវអនុវត្តតម្រូវឲ្យមានការប្រគល់ ឯកសារត្រឡប់មកកន្លែងដើមវិញ ។

## ***ហេតុអ្វីជាការងាររៀបចំរក្សាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា***

ដោយប្រៀបធៀបទៅនឹងករណីរបស់ប្រទេសអ៊ីរ៉ាក់ មេធាវីអន្តរជាតិ អ្នកចងក្រងឯកសារ និងរដ្ឋាភិបាលប្រទេសកម្ពុជា និងសាធារណជន បានចាត់ទុកការរក្សាឯកសារក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ថាជាការស្របច្បាប់ ហើយមិនត្រូវជំទាស់នោះឡើយ ។ ភាពជោគជ័យនៃគំរូរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្អែកលើកត្តាគន្លឹះបីយ៉ាង ៖ ១) ការយល់ស្របពីរដ្ឋាភិបាលកម្ពុជា ២) ការគាំទ្រពីសហរដ្ឋអាមេរិក និងម្ចាស់ជំនួយដទៃ ៣) ការអភិវឌ្ឍ សមត្ថភាពបច្ចេកទេស និងភាពអាចជឿទុកចិត្តបានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ រដ្ឋាភិបាលប្រទេសកម្ពុជា មានផលប្រយោជន៍ខាងផ្លូវនយោបាយ ក្នុងការឆ្លុះបញ្ចាំងអំពីការរំលោភបំពានរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ប្រសិនបើគ្មានការយល់ស្រប និងគាំទ្រពីរដ្ឋាភិបាលកម្ពុជា ការរក្សាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងឈរលើមូលដ្ឋានគោលការណ៍សីលធម៌ និងច្បាប់ទន់ខ្សោយ ។ ការយល់ស្របពីរដ្ឋាភិបាល ដោយផ្សារភ្ជាប់ជាមួយនឹងសមត្ថភាពផ្នែកបច្ចេកទេស និងភាពដែលអាច ជឿទុកចិត្តបានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់មូលដ្ឋានរឹងមាំដល់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ការរក្សាឯកសារតាមលក្ខណៈស្របច្បាប់ ហើយបន្ទន់ការជំរុញរបស់រដ្ឋាភិបាល ក្នុងការកែប្រែផែនការនេះ ។ ការគាំទ្រពីអន្តរជាតិនិងសាធារណជន បានបង្កើនដល់សមត្ថភាពនិងភាពស្របច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយធ្វើឲ្យរដ្ឋាភិបាលជួបផលវិបាកក្នុងការស្វែងរកការគ្រប់គ្រងលើសំណុំឯកសារ ។

កត្តាទាំងបីនេះទំនងជាគន្លឹះសម្រាប់ការរក្សាឯកសារពាក់ព័ន្ធសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាពរបស់អង្គការក្រៅរដ្ឋាភិបាលនៅតាមប្រទេសដទៃ ។ ការគាំទ្រពីអន្តរជាតិ និងការដឹកនាំ និងការកសាងសមត្ថភាពរបស់អង្គការក្រៅរដ្ឋាភិបាលអាចផ្តល់នូវមូលដ្ឋានយ៉ាងច្រើនដើម្បីទទួលជោគជ័យ ប៉ុន្តែការរៀបចំរក្សាឯកសារនឹងពឹងផ្អែកយ៉ាងសំខាន់លើការបន្តបេ្តជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការអនុញ្ញាតដំណើរការចងក្រងឯកសារអង្គការក្រៅរដ្ឋាភិបាល ។ ច្បាប់ និងគោលការណ៍សីលធម៌បន្តផ្តល់សិទ្ធិឲ្យរដ្ឋ ដើម្បីគ្រប់គ្រងឯកសារផ្លូវការ និងអំណាចពេញលេញ ដើម្បីទប់ស្កាត់ផែនការរៀបចំថែរក្សាឯកសារណាមួយដែលមិនមានការយល់ស្របពីរដ្ឋាភិបាល ។ ការកសាងបណ្ណសារដ្ឋាន ដែលដឹកនាំដោយ អង្គការក្រៅរដ្ឋាភិបាលនៅក្នុងរដ្ឋអន្តរសម័យដែលខ្វះសមត្ថភាពនិងភាពជឿទុកចិត្តបាន នឹងតម្រូវឲ្យមានការចូលរួមជាទៀងទាត់ និងហ្មត់ចត់ពីរដ្ឋាភិបាល ដើម្បីចង្អុលបង្ហាញអំពីលក្ខណៈស្មុគស្មាញខាងបច្ចេកទេស និងលក្ខណៈស្របច្បាប់ជាសាធារណៈ ដែលជួនកាលផែនការរៀបចំនោះអាចមាន ។

**ចន ឆរឆីអារី**

# ការវិភាគស្តីពីច្បាប់បណ្ណសារដ្ឋានរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០០៥

ដោយអនុលោមតាមសំណើរបស់អ្នក ក្នុងនេះខ្ញុំធ្វើការបរិយាយផ្លូវការអំពីការងារ ដែលបានធ្វើក្នុងខែកញ្ញា ឆ្នាំ២០០៥ កន្លងមកនេះ ដើម្បីធ្វើការវិភាគលើច្បាប់ស្តីពីការគ្រប់គ្រងបណ្ណសារដ្ឋានរបស់ប្រទេសកម្ពុជា ។ ច្បាប់នេះ ត្រូវបានវាយតម្លៃសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយខ្លួនខ្ញុំផ្ទាល់ ចនឆរឆីអារី និង ហ៊ីលីន យ៉ូណេក ។ ខ្ញុំបង្ហាញនូវគំហើញនៅផ្នែកខាងក្រោយ ។ ខ្ញុំភ្ជាប់អនុស្សរណៈស្តីពីការព្រាងច្បាប់របស់ សុត វីរដេន ដែលកាលនោះគាត់ធ្វើការងារឲ្យការិយាល័យរបស់ក្រុមការពារក្តីសាធារណៈ ដូច្នេះហើយគាត់ផ្តោតជាសំខាន់លើការដាក់ទោសព្រហ្មទណ្ឌដែលមាននៅក្នុងច្បាប់ ។

ទន្ទឹមពេលដែលយើងមិនមានកង្វល់ ដែលច្បាប់នោះនឹងត្រូវបានប្រើប្រាស់ដើម្បីបង្ខំឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ឯកសារចម្លងរបស់ខ្លួនទៅឲ្យបណ្ណសារដ្ឋានជាតិ ឬត្រូវរឹបអូសឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ យើងមានកង្វល់យ៉ាងខ្លាំងចំពោះច្បាប់នេះ ។

ដំបូង យ៉ាងហោចណាស់ជាផ្នែកភាសាអង់គ្លេស មាននិយមន័យជាច្រើន ដែលមិនមានភាពច្បាស់លាស់ ហើយបង្កបញ្ហា ។ និយមន័យនៃពាក្យ បណ្ណសារដ្ឋានសាធារណៈ នៅក្នុងមាត្រា២៧ សំដៅទៅរក បណ្ណសារដ្ឋានរដ្ឋបាល ដែលរួមមានបណ្ណសារដ្ឋានបច្ចុប្បន្ន អន្តរបណ្ណសារដ្ឋាន និងបណ្ណសារដ្ឋានអចិន្ត្រៃយ៍ ។ តាមការសន្មតនោះ និយមន័យនេះសំដៅទៅរករដ្ឋបាលសាធារណៈ ដូចជាក្រសួង សាលាក្រុង ហើយធ្វើឲ្យនិយមន័យកាន់តែច្បាស់លាស់ជាងមុន ។ និយមន័យនៃពាក្យបណ្ណសារដ្ឋានបច្ចុប្បន្ន នៅក្នុងមាត្រា៨ មិនបានបញ្ជាក់ច្បាស់លាស់នោះទេ (ដូចជាក្នុងកំណត់សម្គាល់មួយនោះ វាត្រូវបានសំដៅទៅរកមាត្រា២ ជាមួយនឹងនិយមន័យផ្សេង) ប៉ុន្តែសំដៅទៅរក ឯកសារដែលនៅតែប្រើប្រាស់ដោយស្ថាប័នផ្សេងៗ ដូច្នេះហើយឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងនឹងសម័យខ្មែរក្រហមមិនជាប់ក្នុងនិយមន័យនេះទេ ។ និយមន័យនៃពាក្យ អន្តរបណ្ណសារដ្ឋាន នៅក្នុងមាត្រា៩ គឺមិនច្បាស់លាស់នោះទេ (ហើយត្រូវតែប្តូរទៅមាត្រា២វិញ) ប៉ុន្តែសំដៅទៅរកឯកសារ ដែលមិនបានប្រើប្រាស់តទៅទៀត ប៉ុន្តែនៅតែរក្សានៅទីតាំង ដែលឯកសារនោះ ត្រូវបានប្រើប្រាស់លើកមុន ដូច្នេះជាថ្មីម្តងទៀត ឯកសារទាំងនេះ មិនមែនជាឯកសារភាគច្រើនរបស់មជ្ឈមណ្ឌលឯកសារ កម្ពុជានោះទេ ។

ការកាន់តែមានកង្វល់ចំពោះនិយមន័យនោះ គឺជានិយមន័យនៃពាក្យបណ្ណសារដ្ឋានអចិន្ត្រៃយ៍ ក្នុងមាត្រា១០ ។ ជាថ្មីម្តងទៀត និយមន័យនេះ មិនមានភាពច្បាស់លាស់នោះទេ ប៉ុន្តែវាសំដៅទៅរក ឯកសារដែលត្រូវបានចាត់ទុកថាជាឯកសារប្រវត្តិសាស្ត្រសម្រាប់ជាផលប្រយោជន៍សាធារណៈ ហើយបន្ទាប់មកត្រូវតែរក្សានៅបណ្ណសារដ្ឋានជាតិប្រទេសកម្ពុជា បន្ទាប់ពីការវាយតម្លៃ ។ ក្នុងបរិបទនេះ វាហាក់បីដូចជាថា ឯកសារដែលត្រូវវាយតម្លៃ គឺត្រូវបានរក្សាទុកក្នុងអន្តរបណ្ណសារដ្ឋាន ដោយរដ្ឋបាលផ្សេងៗ ។ វាមិនទំនងជាថា ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្ថិតក្នុងផ្នែកនេះ ប៉ុន្តែនៅតែមានហានិភ័យដែលមាត្រា១០អាចត្រូវបានបកស្រាយពេញលេញ ដើម្បីដាក់បញ្ចូលឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងផ្នែកនៃឯកសារដែលត្រូវវាយតម្លៃ ។ ច្បាប់នោះខកខាន បរិយាយអំពីការវាយតម្លៃឯកសារប្រវត្តិសាស្ត្រនឹងដំណើរការដោយរបៀបណា ។ វានឹងក្លាយជាការគួរឲ្យចង់បាន ប្រសិនបើច្បាប់កាន់តែត្រូវបានប្រើពាក្យពេចន៍ខ្លីៗ ហើយច្បាស់លាស់ ។

មាត្រា១៣ និង១៤ ចែងអំពីការអាចស្វែងរកឯកសារនៅក្នុងបណ្ណសារដ្ឋាន ដោយសាធារណជន ហើយរួមបញ្ចូលលក្ខខណ្ឌ

តម្រូវពេលវេលាដ៏តឹងរ៉ឹង (៤០ឆ្នាំបន្ទាប់ពីការបង្កើតច្បាប់នោះ) សម្រាប់សាធារណជនដើម្បីទទួលបានឯកសារដែលធ្វើឲ្យប៉ះពាល់ដល់ការការពារជាតិ សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សង្គម ។

មាត្រា១៦និង១៧ ផ្តោតលើបណ្ណសារដ្ឋានឯកជន ដែលមានតម្លៃជាប្រវត្តិសាស្ត្រ ឬបេតិកភណ្ឌជាតិ ។ មាត្រា ២,៤ បរិយាយទូលំទូលាយអំពីបណ្ណសារដ្ឋានឯកជន រួមមានឯកសារ (ឯកសាររដ្ឋបាល) បង្កើតឡើងដោយបុគ្គលឯកជន ឬនីតិបុគ្គល ដែលត្រូវបានទទួល (ឬសូម្បីតែប្រមូល) ដោយបុគ្គលឯកជន ឬនីតិបុគ្គល ។ ជាថ្មីម្តងទៀត និយមន័យនេះនឹង បង្កឲ្យមានបញ្ហាដល់ភាពមិន ច្បាស់លាស់នៃនិយមន័យ និងខកខានពន្យល់ដំណើរការដើម្បីកំណត់ថាតើឯកសារនោះ មានតម្លៃប្រវត្តិសាស្ត្រ ឬបេតិកភណ្ឌជាតិ ។ វាទំនងដែលឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្ថិតក្នុងផ្នែកនេះ ។ មាត្រា១៦ ចែងថា ឯកសារនោះប្រហែលជាត្រូវបានផ្តល់ ឬលក់ដោយបុគ្គលឯកជន ឬនីតិបុគ្គលទៅឲ្យបណ្ណសារដ្ឋានជាតិប្រទេសកម្ពុជា ។ ដោយសារតែមានកង្វល់កាន់តែធំនោះ មាត្រា១៧ចែងថា ប្រសិនបើឯកសារថតចម្លងមិនផ្តល់ឲ្យ ឬលក់នោះទេ ឯកសារថតចម្លងដែលមានតម្លៃប្រវត្តិសាស្ត្រ ឬបេតិកភណ្ឌជាតិ ត្រូវតែផ្តល់ឲ្យទៅបណ្ណសារដ្ឋានជាតិ ។

មាត្រា១៨ ចែងថា “ក្រុមប្រឹក្សាបណ្ណសារដ្ឋាន នឹងបង្កើតបទដ្ឋានសម្រាប់កំណត់នូវតម្លៃប្រវត្តិសាស្ត្រ ។ ក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ។ យើងបានផ្តល់ជាដំបូន្មានថា មជ្ឈមណ្ឌលឯកសារកម្ពុជាគួរតែសម្លឹងមើលក្រុមប្រឹក្សាបណ្ណសារដ្ឋានមួយនេះ ដោយសារច្បាប់ មិនមានភាពច្បាស់លាស់នេះ អាចត្រូវបានបកស្រាយដើម្បីតម្រូវឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ឯកសារថតចម្លងទាំងអស់របស់ខ្លួន ។

មាត្រា១៩ដល់២២ ចែងអំពីការដាក់ទោស ។ ការដាក់ទោសហាក់បីដូចជាផ្តោតលើការបន្លំ ឯកសារនិងការបញ្ជូនឯកសារទៅបរទេស ។ ដូច្នេះហើយការដាក់ទោសនោះមិនគួរត្រូវបានអនុវត្ត ចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ ទោះបីជាពាក្យពេចន៍ទូលំទូលាយយ៉ាងណានោះ ។

សរុបសេចក្តីមក ទោះបីជាច្បាប់ដែលមានពាក្យពេចន៍មិនច្បាស់លាស់នេះ អាចត្រូវបានបកស្រាយដើម្បីទាមទារឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រគល់ឯកសាររបស់ខ្លួនទៅឲ្យបណ្ណសារដ្ឋានជាតិ យើងមិនគិតថាទង្វើបែបនោះនឹងត្រូវបានធ្វើឡើងតាមផ្លូវនយោបាយនោះទេ ។ យើងគិតថា ច្បាប់អាចត្រូវបានប្រើប្រាស់ដើម្បីតម្រូវឲ្យ មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្សព្វផ្សាយឯកសារជាសាធារណៈ និងផ្តល់ឯកសារថតចម្លងនៃរបបកម្ពុជាប្រជាធិបតេយ្យទៅឲ្យសាធារណជនក្នុងលក្ខខណ្ឌ ហ្វុសអូអាយ អេ ។

ខ្ញុំបានទាក់ទង ហេឡែន ដាប៊ីស័រ ដែលជាអ្នកជំនាញច្បាប់សេរីភាពសារព័ត៌មាននៅវិទ្យាស្ថានសង្គមបើកចំហ ។ គាត់បានរកឃើញថា ច្បាប់នោះ គឺជាច្បាប់បណ្ណសារដ្ឋាន ជាជាងច្បាប់ ហ្វុសអូអាយអេ ហើយបានឲ្យយើងទាក់ទងបណ្ណសារដ្ឋានសន្តិសុខជាតិជាបន្ត ។ ដោយសារតែមានការវិភាគផ្នែកច្បាប់ របស់យើងនោះ ខ្ញុំមិនបានធ្វើតាមទង្វើបែបនេះឡើយ ។

**ចាយ៉ា រាមជី ណូហ្គារេលស**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ: (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខ: (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខ: (៨៥៥) (២៣) ២១០ ៣៥៨

Email: truthsocheat@dccam.org

Home page: www.dccam.org

# ការចងចាំអំពីខ្មែរក្រហមស្ថិតនៅជាដរាប

មនុស្សម្នាក់ៗតែងតែមានការចងចាំរៀងៗខ្លួន មិនថាការចងចាំនោះមានភាពផ្អែមល្ហែម ឬភាពជូរចត់នោះទេ។ អ្នកដែលធ្វើឲ្យយើងចងចាំជាងគេ គឺជាអ្នកដែលធ្វើឲ្យយើងភ័យខ្លាចជាងគេ។ នៅក្នុងជម្រៅចិត្តរបស់ប្រជាជនកម្ពុជា អ្នកដែលធ្លាប់រងការឈឺចាប់ពីវិនាសកម្មប្រវត្តិសាស្ត្រ និងឆ្លងកាត់ផ្ទាល់ពីរបបបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃនេះ គឺមានការចងចាំដ៏គួរឲ្យភ័យខ្លាចដែលតាមលងបន្លាចប្រជាជនកម្ពុជារាល់ថ្ងៃៗ ជារៀងរាល់ថ្ងៃ នៅក្រោមរបបដ៏សាហាវយង់ឃ្នង ប្រជាជនកម្ពុជាតែងតែបន់ស្រន់សូមឲ្យថ្ងៃនេះកន្លងផុតទៅឲ្យឆាប់រហ័ស ហើយសង្ឃឹមនឹងឃើញព្រះអាទិត្យរះនៅថ្ងៃស្អែកបន្តទៀត។ ពេលខ្លះ ការចងចាំទាំងអស់នេះបានធ្វើឲ្យជនរងគ្រោះស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន ហើយថែមទាំងធ្វើឲ្យមានជំងឺភ័យខ្លាច និងជំងឺផ្លូវចិត្តទៀតផង។ មនុស្សមួយចំនួនព្យាយាមស្វែងរកវិធីដែលអាចជួយឲ្យខ្លួនបំភ្លេចអតីតកាលក្រោយរបបខ្មែរក្រហម ប៉ុន្តែខ្ញុំនៅតែមិនជឿថា ការបំភ្លេចអតីតកាលអាចជួយឲ្យប្រជាជនកម្ពុជាគេចផុតពីការពិតទាំងនេះបានឡើយ។ តាមគំនិតខ្ញុំ ប្រជាជនកម្ពុជាមិនទំនងជាអាចបំភ្លេចនូវការចងចាំពីរបបខ្មែរក្រហមបាននោះទេ។



សា ហ៊ុទីលី

ខ្ញុំបានធ្វើការលើកគម្រោងជាច្រើននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដែលភាគច្រើនទាក់ទងទៅវីដេអូបទសម្ភាសនិងភាពយន្តឯកសារខ្មែរក្រហម។ ការចាប់យករូបភាពវីដេអូសវនាការថតរូបភាគីក្នុងតុលាការ និងផលិតជាខ្សែភាពយន្តខ្លីៗស្តីពីប្រតិកម្មរបស់ប្រជាជនចំពោះការកាត់ក្តីនេះគឺជាផ្នែកមួយនៃការងាររបស់ខ្ញុំចាប់ពីឆ្នាំ២០០៧មក។ យោងតាមប្រតិកម្មរបស់ប្រជាជនកម្ពុជាដែលខ្ញុំបានជួបសម្ភាស ខ្ញុំសឹងតែអាចប្រាប់បានថា អ្នកទាំងនោះមិនអាចបំភ្លេចរឿងរ៉ាវអតីតកាលបាននោះទេ។ ការបាត់បង់មនុស្សជាទីស្រលាញ់ និងអនុស្សាវរីយ៍ទាំងប៉ុន្មានដែលបានធ្លាប់ជួបប្រទះ វានៅតែដក់ជាប់ជានិច្ចនៅក្នុងក្រអៅបេះដូងរបស់គាត់។ ឪពុករបស់ខ្ញុំ សា ម៉ាត់ បានប្រាប់ខ្ញុំថាគាត់មិនអាចបំភ្លេចនូវអ្វីដែលឪពុកម្តាយគាត់ត្រូវបានសម្លាប់យ៉ាងព្រៃផ្សៃនៅក្នុងរបបខ្មែរក្រហមនោះឡើយ។ ជារៀងរាល់ពេលដែលឪពុកខ្ញុំឃើញត្រសក់ត្រាំ គាត់តែងតែនឹកដល់ម្តាយរបស់គាត់ដែលតែងតែវេចខ្ចប់បាយជាមួយនឹងត្រសក់ត្រាំឲ្យគាត់ទៅសាលារៀន។ របបខ្មែរក្រហមបានបំបែកនិងជម្លៀសឪពុកខ្ញុំចេញពីអ្នកមានគុណរបស់គាត់។ នៅចុងឆ្នាំ១៩៧៥ របបនេះបានឆក់យកជីវិតមនុស្សជាទីស្រឡាញ់និងសាច់ញាតិរបស់យើងដោយចោទថាបានចូលរួមក្នុងចលនាបះបោរជាមួយជនជាតិចាមនៅកោះផល ហើយប្រជាជនប្រមាណជិត១០០គ្រួសារ ត្រូវបាននាំយកទៅសម្លាប់ទាំងអស់។ ខ្មែរក្រហមបានសម្លាប់ជីតារបស់ខ្ញុំ និងប្អូនរបស់គាត់ដោយចងទម្ងន់ទៅក្នុងទឹកដើម្បីឲ្យលង់ទឹកស្លាប់។ យាយរបស់ខ្ញុំស្លាប់ដោយសារតែមិនមានថ្នាំព្យាបាលជំងឺ ហើយឪពុករបស់ខ្ញុំនៅរស់ដោយសារគាត់ប្រើងប្រែងធ្វើការ និងលាក់ប្រវត្តិរូបរបស់គាត់ដែលជាអតីតទាហាន លន់ នល់។ មាន

ថ្ងៃមួយ ឪពុករបស់ខ្ញុំត្រូវបានចោទ ប្រកាន់ថាជាទាហានលន់នល់ ហើយគាត់បានព្យាយាមនិយាយបញ្ចុះបញ្ចូលកម្មាភិបាលទាំងអស់នោះថា គាត់គ្រាន់តែជាកសិករម្នាក់ ដែលមិនចេះសូម្បីតែអានឬសរសេរអក្សរ ។ យប់ឡើងមានកម្មាភិបាលចំនួនប្រាំនាក់បានមកផ្ទះរបស់ឪពុកខ្ញុំ ហើយបានហៅគាត់ទៅក្រៅជាមួយនឹងអ្នកភូមិផ្សេងទៀត ។ ទាំងអស់គ្នាបានឡើងជិះទូក ហើយធ្វើដំណើរតាមទន្លេទៅកាន់កោះ ។ ពេលនោះឪពុករបស់ខ្ញុំគិតថា កម្មាភិបាលទាំងអស់នោះពិត ជាបានដឹងពីប្រវត្តិពិតរបស់គាត់ ហើយគាត់កំពុងត្រូវបាននាំយកទៅសម្លាប់ចោល ។ ខណៈពេលកំពុងដើរបណ្ដើរគិតបណ្ដើរ ស្រាប់តែកម្មាភិបាលខ្មែរក្រហមវាយក្បាលអ្នកភូមិម្នាក់នឹងព្រនង់ ហើយអ្នកភូមិនោះក៏បានដួលលើផ្លូវស្លាប់នៅហ្នឹងកន្លែង ។ នៅពេលឪពុករបស់ខ្ញុំឃើញ ដូច្នេះគាត់ក៏ទន់ជើងលត់ជង្គង់ទៅនឹងដីដោយភាពតក់ស្លុតហើយនៅនឹងថ្កល់ ។ កម្មាភិបាលខ្មែរក្រហមស្រែកគំហកឪពុកខ្ញុំឲ្យក្រោកឡើងហើយដើរទៅមុខ ។ ឪពុករបស់ខ្ញុំពិតជាភ័យខ្លាចសឹងតែព្រលឹងហោះចេញពីរូបរាងកាយរបស់គាត់បាត់ទៅហើយ ។ កម្មាភិបាលខ្មែរក្រហមគំរាមឪពុកខ្ញុំថានឹងសម្លាប់គាត់ចោល ប្រសិនបើគាត់ប្រាប់រឿងនេះដល់អ្នកផ្សេង ។ ដូច្នេះគាត់ក៏លាក់នៅក្នុងចិត្តតែម្នាក់ឯង ។

ខ្ញុំបានចាប់កំណើតឡើងប្រាំបីឆ្នាំក្រោយការដួលរលំរបបខ្មែរក្រហម ។ ខ្ញុំធំឡើងដោយ មិនដឹងអ្វីទាំងអស់ទាក់ទងទៅនឹងប្រវត្តិក្រុមគ្រួសាររបស់ខ្ញុំនិងប្រទេសជាតិរបស់ខ្ញុំ ។ តាមរយៈការងារខ្ញុំចាប់ផ្ដើមសិក្សាអំពីរបបកាចសាហាវនេះដែលបានកើតមានក្នុងប្រទេសរបស់ខ្ញុំ ។ ពីរឆ្នាំក្រោយ បន្ទាប់ពីធ្វើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំត្រូវបានជ្រើសរើសឲ្យចុះធ្វើកម្មសិក្សាក្នុងវិទ្យាស្ថាន *Shoah Foundation* នៃសាកលវិទ្យាល័យ *Southern California* នៅសហរដ្ឋអាមេរិក ។ ខ្ញុំបានជួបជាមួយនឹងអ្នកដែលរស់រានពីការសម្លាប់របស់ពួកណាស៊ី ដែលមកចែករំលែកនូវបទពិសោធរបស់គាត់ ។ លើសនេះទៀត ខ្ញុំបានជួបសម្ភាសជាមួយខ្មែរសញ្ជាតិអាមេរិកកាំងជាច្រើនដែលនៅរស់រានមានជីវិត តែមិនត្រឡប់មកប្រទេសកំណើតខ្លួនវិញ បង្ហាញពីអារម្មណ៍ភ័យខ្លាចនៅពេលអ្នកទាំងនោះប្រឈមនឹងការចងចាំនូវការបាត់បង់សាច់ញាតិបងប្អូន និងមិត្តភក្តិនៅពេលនោះ ។ បន្ទាប់ពីការវិលត្រឡប់មកវិញ ខ្ញុំបានតាំងចិត្តនឹងសម្ភាសឪពុករបស់ខ្ញុំអំពីរឿងរ៉ាវរបស់គាត់ចាប់ផ្ដើមពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ។ រហូតមកដល់ឥឡូវនេះគឺរយៈពេលបួនឆ្នាំហើយ តែខ្ញុំនៅតែមិនទាន់បានរឿងរ៉ាវរបស់គាត់ទាំងស្រុងនោះទេ ។ គាត់មិនអាចទប់ទឹកភ្នែកបាននៅពេលគាត់ និយាយពីរឿងក្រុមគ្រួសាររបស់គាត់ក្នុងរបបខ្មៅងងឹតនេះ ។ ឥឡូវគាត់កំពុងឈឺ ហើយសម្រាកព្យាបាលខ្លួននៅក្នុងមន្ទីរពេទ្យ ។ ខ្ញុំតែងតែរំលឹកប្រាប់គាត់ជារឿយៗអំពីដំណើរការកាត់ក្ដីខ្មែរក្រហម ព្រោះតែគាត់មានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើបញ្ហានេះ ។ ឪពុករបស់ខ្ញុំបានប្រាប់ថា អ្នករស់រានក្រោយរបបខ្មែរក្រហម និងជនជាប់ចោទមួយចំនួនមានវ័យជរា ហើយកំពុងតែស្លាប់បណ្ដើរៗ គាត់គ្រាន់តែសង្ឃឹមថា ការប្រកាសសាលក្រមនឹងត្រូវបញ្ចប់មុនពេលអ្នកទាំងអស់នេះលាចាកពីលោកនេះទៅ ។ មួយថ្ងៃនៅក្នុងគុកក៏ដោយ សម្រាប់មេដឹកនាំនៅសម័យនោះមុនពេលគាត់ស្លាប់ក៏ជាការបង្ហាញពីការតបស្នងគ្រប់គ្រាន់សម្រាប់គាត់ និងមនុស្សជាទីស្រលាញ់របស់គាត់ ។

ដោយសារតែ យើងមិនអាចបំភ្លេចអតីតកាលបាន ការរំឭកនូវការចងចាំគឺជាកម្លាំងមួយដែលជំរុញឲ្យយើងហ៊ានដើរទៅមុខ ។ ខ្ញុំជឿជាក់ថា របបកាចសាហាវដូច្នេះ នឹងបានចែករំលែកដល់ក្មេងៗជំនាន់ក្រោយ ហើយរារាំងមិនឲ្យរបបនេះកើតមានសាជាថ្មីម្ដងទៀតនៅពេលអនាគត ។ អ្នកដែលនៅរស់រានមានជីវិតបានចែករំលែកនូវបទពិសោធ និងការចងចាំរបស់ខ្លួនដល់កូនៗ និងចៅៗជំនាន់ក្រោយ ការធ្វើបែបនេះនឹងធ្វើឲ្យក្មេងៗជំនាន់ក្រោយបានដឹង និងយល់ពីប្រវត្តិរបស់ក្រុម គ្រួសារខ្លួនក៏ដូចជាប្រទេសជាតិរបស់ខ្លួន ។ ក្មេងៗជំនាន់ក្រោយអាចចម្រាញ់យកផលប្រយោជន៍ពីបទពិសោធរបស់ចាស់ៗជំនាន់មុន និងសិក្សាពីរឿងទាំងអស់នេះដើម្បីជៀសវាង និងកសាងប្រទេសរបស់ខ្លួនទៅរកការអភិវឌ្ឍនាពេលអនាគត ។ ខ្ញុំនៅតែជឿជាក់ថាការចងចាំគឺបានដើរតួនាទីយ៉ាង សំខាន់ក្នុងការរឹតចំណងប្រជាជននិងជួយឲ្យប្រជាជនកម្ពុជាបោះជំហានទៅមុខដោយភាពក្លាហានលើសពីការផ្ដេកផ្ដួលខ្លួនថាជាជនរងគ្រោះក្នុងប្រវត្តិសាស្ត្រនៃវិនាសកម្មនេះ ។

**សា ហ្វាធីលី**

# គីម តែម : អតីតកាលតែងលង

គីម តែម បានរៀបរាប់អំពីការបំភ្លេចមិនបាននូវអ្វីដែលបានកើតឡើងចំពោះរូបគាត់ និងគ្រួសារនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ។ តែម មានឪពុកឈ្មោះ គីម ប៉ាវ បានស្លាប់ដោយសារជំងឺ ក្រោយពេលខ្មែរក្រហមទទួលជ័យជម្នះរយៈមួយខែ និងម្តាយឈ្មោះ ពេញ សេត ស្លាប់ដោយសារជរាពាធ ។ បងប្រុសរបស់គាត់ឈ្មោះ គីម ប៉ាន បានបាត់ខ្លួននៅក្នុងសមរភូមិ ។ តែម បន្តថា សូម្បីតែសព្វថ្ងៃនេះ គ្រប់ពេលដែលបានហូបបាយ និងជាពិសេសនៅពេលជួបមិត្តរួមការងារនៅសម័យខ្មែរក្រហម គាត់នាំគ្នានិយាយពីរឿងទុក្ខលំបាករៀងៗខ្លួន និងការបាត់បង់សាច់ញាតិរបស់ខ្លួន និងនឹកឃើញពីភាពអត់ឃ្លានក្នុងសម័យនោះ ។

កាលពីសម័យសង្គមរាស្ត្រនិយមដ៏រុងរឿង ក្រោមការដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ គីម តែម រស់នៅក្នុងភូមិកំពែង ឃុំកំពែង ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ សព្វថ្ងៃ តែម មានអាយុ ៥៥ឆ្នាំ ជាមេភូមិមួយរូបក្នុងភូមិកំពង់ហ្លួង ឃុំអង្គរបូរី ស្រុកអង្គរបូរី ខេត្តតាកែវ ។ គាត់មានប្រពន្ធ ឈ្មោះ ហឹង សង និងមានកូនចំនួនបួននាក់ ។

តែម តែងតែនិយាយរឿងរ៉ាវទាក់ទងនឹងរបបខ្មែរក្រហម ដែលបានផ្លាស់ប្តូរជីវិតរបស់គាត់ ។ គាត់បន្តថា ខ្មែរក្រហមបានចូលកាន់កាប់ភូមិឃុំកំពែង ចាប់តាំងពីឆ្នាំ១៩៧២-៧៣ ដែលនៅពេលនោះគាត់ទើបតែមានអាយុប្រហែល២១ឆ្នាំប៉ុណ្ណោះ ។ កាលនោះ អង្គការបានចាត់តាំងគាត់ឲ្យចូលក្នុងកងចល័ត ជីកព្រែកប្រឡាយ និងលើកទំនប់ នៅខេត្តកំពង់ស្ពឺ ដោយមានការដាក់កំហិតទៀត ។ កងចល័តត្រូវដើរពីខេត្តតាកែវទៅខេត្តកំពង់ស្ពឺដើម្បីធ្វើការ ព្រមទាំងឲ្យចល័តពីកន្លែងមួយទៅកន្លែងមួយតាមការដាក់ទិសរបស់អង្គការ ។ ចំពោះការបរិភោគអាហារវិញ គាត់ទទួលបានតែបបររាវៗមួយឆ្នាំងតូចសម្រាប់មនុស្សបួននាក់ ។ នៅពេលនោះ អង្គការនៅចែករបបអាហារទៅតាមចំនួនសមាជិកគ្រួសារនៅឡើយ ។ ប៉ុន្តែស្របពេលនោះ អង្គការចាប់ផ្តើមយកដង្ហោៗ និងអ្នកមានមុខមាត់ជាច្រើននៅក្នុងភូមិយកទៅសម្លាប់ចោល ក្រោមលេសថា យកទៅរៀនសូត្រ ដោយទុកតែប្រពន្ធ និងកូនប៉ុណ្ណោះឲ្យនៅផ្ទះ ។ នៅសម័យនោះ តែម មានបងប្រុសបង្កើតម្នាក់ឈ្មោះ គីម ប៉ាន ជាសិស្សរៀនថ្នាក់ទី៦ សង្គមចាស់ នៅសាលាកំពែង ។ នៅឆ្នាំ១៩៧០ បងរបស់គាត់បានចូលធ្វើជាទាហានខ្មែរក្រហម ហើយខ្មែរក្រហមបានចាត់តាំងគាត់ឲ្យទៅវាយជាមួយទាហានលន់ នល់ ។ ចាប់តាំងពីពេលនោះមក បងប្រុសគាត់បាត់ខ្លួនរហូត ។

ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានកាន់កាប់ប្រទេសទាំងស្រុង ខ្មែរក្រហមចាប់ផ្តើមបង្កើតរោងសហករណ៍ ដោយហាមមិនឲ្យមានការបរិភោគអាហារតាមផ្ទះបានដូចមុន ។ ការហូបចុកត្រូវស្ថិតនៅក្នុងរោងបាយរួម ។ តែម បន្តទៀតថា ការបង្កើតរោងសហករណ៍នេះត្រូវបានរៀបចំឡើង ដើម្បីរង់ចាំទទួលប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញ និងប្រជាជនមកពីតំបន់ផ្សេងៗទៀត ។ នៅពេលដែលមានប្រជាជនថ្មី ឬ អ្នក១៧មេសាចូលមករស់នៅក្នុងភូមិ អង្គការក៏ចាប់ជម្លៀសប្រជាជននៅក្នុងភូមិកំពែងឲ្យទៅរស់នៅខេត្តបាត់ដំបង ឬទៅនៅខាងទន្លេបាទីវិញ ។ ចំណែកឯប្រជាជននៅទន្លេបាទី ផ្លាស់មកនៅភូមិកំពែង ។ ប៉ុន្តែ តែម និងគ្រួសារមិនត្រូវបានផ្លាស់ទៅណាទេ ។ នៅចុងឆ្នាំ១៩៧៥ តាមន បានឡើងធ្វើជាគណៈស្រុកនៅព្រៃកប្បាស ។ តាមន ជាមនុស្សដែលមានចរិតកោងកាច ចំពោះប្រជាជន សូម្បីតែ តែម ក៏មិនហានមើលមុខគាត់ដែរ ។ អ្នកស្រុកខ្លាចគាត់គ្រប់គ្នា ។ តាមន បានបែងចែកវណ្ណៈប្រជាជន ដោយប្រើពាក្យ “ថ្មី” សម្រាប់ប្រជាជនដែលមានទ្រព្យសម្បត្តិច្រើន កាលពីសម័យសង្គមរាស្ត្រនិយម “ប្រជាជនត្រៀម” សម្រាប់ប្រជាជនដែលពីមុនក្រីក្រ និង “អ្នក ពេញសិទ្ធិ” សម្រាប់ប្រជាជនមូលដ្ឋាន ។ ចំណែកឯ “អ្នក១៧មេសា” ត្រូវបានហៅថាជា “ជនបញ្ញើ” ។ អង្គការបានចាត់តាំងឲ្យ “អ្នកពេញសិទ្ធិ” ធ្វើជាឈ្លបភូមិ ឬប្រធានសហករណ៍ ឬមានតួនាទីខ្ពស់ជាងនេះ ។ អ្វីដែល

គួរឲ្យកត់សម្គាល់នោះគឺថា អ្នកពេញសិទ្ធិមួយចំនួនបានធ្វើបាបប្រជាជនត្រៀម និងបញ្ញើ តាមរយៈការរាយការណ៍ជូនដល់ថ្នាក់លើដោយពន្លើសពីកំហុសស្រាលទៅជាកំហុសធំដុំដើម្បីឲ្យមានការដាក់ទោសធ្ងន់ធ្ងរ ។

នៅដើមឆ្នាំ១៩៧៦ អង្គការបានផ្លាស់ប្តូរគណៈស្រុកចាស់ តាមន ដោយតែងតាំង តាចុង មកជំនួសវិញ ។ តាចុង ជាប្អូនបង្កើតរបស់ តាម៉ុក ដែលត្រូវស្គាល់ជាទូទៅថាជាលេខាភូមិភាគនិរតី ។ តាចុង ជាមនុស្សស្លូតបូត និងមានចិត្តល្អជាមួយប្រជាជន ។ គាត់តែងតែចុះតាមមូលដ្ឋានដើម្បីសួរសុខទុក្ខប្រជាជន ។ នៅក្នុងរដូវច្រូតកាត់ តាចុង អនុញ្ញាតឲ្យប្រជាជនហូបបាយក្នុងមួយខែបីដង ។ ការហូបបាយបីដងនេះ គឺនៅ "ថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០" ។ ទោះបីជាគណៈស្រុករូប នេះហាក់ដូចជា ចិត្តល្អពិតមែន ប៉ុន្តែក៏មានការចាប់ប្រជាជនបញ្ញើ និងត្រៀមយកទៅរៀនសូត្រជាបន្តបន្ទាប់ដែរ ។ ចំណែកការធ្វើការងារគ្មានពេលសម្រាកគ្រប់គ្រាន់ កង្វះអាហារបរិភោគ បណ្តាលឲ្យប្រជាជនជាច្រើន ជាពិសេសប្រជាជនបញ្ញើ ធ្លាក់ខ្លួនឈឺ និងស្លាប់ ។

តែម បានបញ្ជាក់ថា អង្គការកាន់តែរឹតបន្តឹងជាងមុនទៅទៀត មកឆ្នាំ១៩៧៧ ។ តែម និងបងប្អូន ព្រមទាំងប្រជាជនទាំងអស់ស្ទើរតែមិនហ៊ាននិយាយរកគ្នា សូម្បីតែសួរសុខទុក្ខក្រុមគ្រួសារ និងបងប្អូនខ្លួនឯង ព្រោះឈ្លបតាមដានគ្រប់ពេលវេលាទាំងនៅក្នុងម៉ោងធ្វើការ និងពេលហូបអាហារ ហើយសូម្បីពេលត្រឡប់មកផ្ទះវិញក៏មានឈ្លបមកស៊ើបការណ៍ជាប់ជានិច្ចដែរ ។

ជារៀងរាល់យប់ តែម និងបងប្អូនមានអារម្មណ៍ភ័យខ្លាចដោយមិនដឹងថ្ងៃណាមួយអង្គការ នឹងកោះហៅឲ្យទៅរៀនសូត្រ ព្រោះពាក្យថា "ទៅរៀនសូត្រនោះ" មានន័យថា "ទៅហើយមិនដែលឃើញមាននរណាត្រឡប់មកផ្ទះវិញទេ" ។ ដូច្នេះហើយ តែមតែងតែព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួន និងគ្រួសារជានិច្ច ព្រោះគាត់សម្គាល់ឃើញថាមនុស្សនៅក្នុងក្រុមកងចល័តតែងតែបាត់ជារៀងរាល់ថ្ងៃ រហូតស្ទើរតែគ្មានមនុស្សមកធ្វើការ ។ ជាក់ស្តែងនៅចុងឆ្នាំ១៩៧៧ និងដើម ឆ្នាំ១៩៧៨ ប្រជាជនបញ្ញើ និងប្រជាជនត្រៀមបាត់ស្ទើរគ្មានសល់នៅក្នុងភូមិ ។ អ្នកទាំងនោះស្លាប់ដោយសារ ខ្មែរក្រហមចាប់យកទៅសម្លាប់ចោល និងស្លាប់ដោយសារការធ្វើការហួសកម្លាំង ។

តែម និយាយថា គាត់រួចរស់ជីវិតនៅពេលកងទ័ពវៀតណាមវាយផ្តួលរំលំរបបខ្មែរក្រហម នៅខែមករា ឆ្នាំ១៩៧៩ ។ ប៉ុន្តែអ្វីដែលគាត់សោកស្តាយនោះ គឺការបាត់បង់បងប្រុស និងមិត្តភក្តិជាច្រើននៅក្នុងកងចល័ត ។ ដូចប្រជាជនកម្ពុជាដទៃទៀតដែលបានបាត់បង់សាច់ញាតិដែរ តែម និងក្រុមគ្រួសារ តែងតែទន្ទឹងរង់ចាំបងប្រុសគាត់ដោយសង្ឃឹមថានៅរស់រានមានជីវិត ហើយថ្ងៃណាមួយនឹងវិលមកជួបជុំក្រុមគ្រួសារវិញ ។ **មីន សាណាស់**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធី "សំឡេងអំពើប្រល័យពូជសាសន៍ៈ យុត្តិធម៌ និងការអត់ឃ្លាន" ដែលចាក់ផ្សាយតាមស្ថានីយ៍វិទ្យុដូចខាងក្រោមរៀងរាល់ថ្ងៃអាទិត្យ ។

ប្រិយមិត្តដែលរស់នៅរាជធានីភ្នំពេញ និងនៅខេត្តអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំតាមរយៈ ៖

◆ វិទ្យុជាតិកម្ពុជា FM 105.75 MHz រាជធានីភ្នំពេញ វេលាម៉ោង១ រសៀល និងម៉ោង៧និង៣០នាទីល្ងាច ។

◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។

◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ព្រឹក និងម៉ោង៤រសៀល ។

◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៤រសៀល ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០៩២ ១៦៨ ៥៤៣ ។

***សូមអរគុណ!***

# «ខ្ញុំចង់បានយុត្តិធម៌ សម្រាប់ប្អូនស្រីខ្ញុំ»



ម៉ុក ស៊ិនហៀង

ខ្ញុំកើតក្នុងឆ្នាំ១៩៥២ នៅម្តុំទួលគោក ខាងលិចទីក្រុងភ្នំពេញ ។ ម៉ុក លៀន ដែលត្រូវជាឪពុកបង្កើតខ្ញុំ គឺជាវេជ្ជបណ្ឌិតផ្នែកចិត្តសាស្ត្រដំបូងគេបង្អស់ក្នុងប្រទេសកម្ពុជាមុនសម័យសង្គ្រាមស៊ីវិល ។ គាត់ជាគ្រូពេទ្យដែលធ្វើការមិនចេះនឿយហត់ ជួយព្យាបាល និងថែរក្សាអ្នកជំងឺដោយពុំគិតពីឋានៈ និងបុណ្យសក្តិអ្វីឡើយ ។ វេជ្ជបណ្ឌិត ម៉ុក លៀន ជាគ្រូពេទ្យដែលទទួលការស្រលាញ់គ្រប់គ្នាពីសំណាក់ប្រជាជនទាំងឡាយ ដោយសារតែគាត់បានជួយព្យាបាលអ្នកជំងឺជាច្រើននាក់ដោយមិនយកប្រាក់កម្រៃ ។ ប្រជាជនជាច្រើនដែលរស់នៅក្នុងខេត្តកំពង់ចាម តាខ្មៅ និងម្តុំទួលគោក នៅពេលនោះ សុទ្ធតែស្គាល់ និងស្រលាញ់គាត់គ្រប់ៗគ្នា ។

ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូនស្រីបីនាក់ ។ ម្នាក់ឈ្មោះ ម៉ុក ស៊ិនហុង ហៅក្រៅ ស្រីចាម និងម្នាក់ទៀតឈ្មោះ ម៉ុក ស៊ិនអ៊ូ ហៅក្រៅ ស្រីឡោះ ឬស្រីចិន ។ នៅពេលដែលឪពុកខ្ញុំ ចាកចេញទៅបំពេញការងារតាមខេត្ត ម្តាយរបស់ខ្ញុំក៏ធ្លាក់ខ្លួនឈឺ ហើយស្លាប់បាត់ទៅ ដោយសារជំងឺគាំងបេះដូងមិនអាចព្យាបាលបាន ដែលពេលនោះ ខ្ញុំមានអាយុត្រឹមតែប្រាំឆ្នាំ ជាបងធំ ត្រូវទទួលបន្ទុកមើលថែប្អូនៗ ។ ជាច្រើនឆ្នាំបន្ទាប់ពីម្តាយខ្ញុំស្លាប់ទៅ ឪពុកខ្ញុំបានរៀបការម្តងទៀត ហើយមានកូនថែមបីនាក់ទៀត គឺ ម៉ុក បណ្ឌិត ម៉ុក ស៊ិនហេង និង ម៉ុក ឫទ្ធិយ៉ា ។

ពេលដែលទាហានខ្មែរក្រហមវាយដណ្តើមបានទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ឪពុកខ្ញុំបានបញ្ជូនខ្ញុំ និងប្អូនៗស្រីឲ្យទៅស្នាក់នៅជាមួយមីង ដែលជាវេជ្ជបណ្ឌិតផ្នែកវះកាត់ ប្រចាំនៅមន្ទីរពេទ្យកាល់ម៉ែត្រ ។ ស្វាមីរបស់មីង និងកូនៗ ត្រូវបែកពីគាត់ តែបានរត់ទៅស្នាក់អាស្រ័យ នៅស្ថានទូតបារាំង ។ ខ្ញុំនិងប្អូនៗស្នាក់នៅជាមួយគាត់ក្នុងមន្ទីរពេទ្យកាល់ម៉ែត្រ អស់រយៈពេលជាច្រើនសប្តាហ៍ ដោយសារតែពួកទាហានខ្មែរក្រហមដាក់បម្រាមមិនឲ្យនរណាម្នាក់នៅក្នុងមន្ទីរពេទ្យនេះ ចេញចូលតាមអំពើចិត្តនោះទេ ។ យើងនៅទីនេះបានទទួលដំណឹងថា ពូ និងកូនៗរបស់គាត់ត្រូវបានបញ្ជូនទៅខេត្តបាត់ដំបង រួចបញ្ជូនទៅប្រទេសបារាំង ជាកន្លែងដែលពួកគាត់រស់នៅសព្វថ្ងៃនេះ ។

ចុងក្រោយ ខ្ញុំ មីងខ្ញុំ និងប្អូនៗ ត្រូវបង្ខំឲ្យចាកចេញពីមន្ទីរពេទ្យ តែពួកយើងមិនបានដឹង ថាតើពួកយើងនឹងទៅកន្លែងណាទេ ដឹងត្រឹមតែថា មីងខ្ញុំធ្វើដំណើរតាមគេដែលត្រូវបង្ខំឲ្យចាកចេញដូចគ្នា ។ មិនយូរប៉ុន្មាន យើងបានមកដល់ស្រុកកោះធំ ខេត្តកណ្តាល ហើយធ្វើដំណើរជាបន្តបន្ទាប់ រហូតទៅដល់ភូមិមួយនៅក្នុងខេត្តពោធិ៍សាត់ ។

## ប្អូនស្រីសុខចិត្តរៀបការជាមួយកម្មាភិបាលខ្មែរក្រហមដើម្បីជួយជីវិតបង

នៅខេត្តពោធិ៍សាត់ មីងរបស់ខ្ញុំ បានយល់ព្រមរៀបការប្អូនស្រីខ្ញុំ (ម៉ុកស៊ិនហុង ហៅស្រីចាម) ឲ្យកម្មាភិបាលខ្មែរក្រហមម្នាក់ ដែលមានដើមកំណើតមកពីទឹកដីកម្ពុជាក្រោម ។ ក្នុងនាមជាបងស្រីដែលត្រូវមើលថែទាំប្អូនៗ ខ្ញុំមិនចង់បង្ខំឲ្យប្អូនរៀបការជាមួយកម្មាភិបាលនោះទេ ។ ប៉ុន្តែប្អូនស្រីព្រមរៀបការជាមួយកម្មាភិបាលនោះ ព្រោះតែចង់ជួយជីវិតបងស្រីដើម្បីមានជីវិតព្រោះកាលនោះ ខ្ញុំជាអ្នកមានសុខភាពទន់ខ្សោយ ខស្សព្រាហ៍ឈឺជាញឹកញាប់

និងជាគោលដៅដែលខ្មែរក្រហមយកទៅសម្លាប់ ។ ប្អូនស្រីក៏រំពឹងថាចំណងជាមួយកម្មាភិបាលខ្មែរក្រហមធ្វើឲ្យលក្ខខណ្ឌជីវិតបងស្រីប្រសើរជាងមុន ។

ក្រោយពីរៀបការរួច គ្រួសារប្អូនស្រីរបស់គាត់ត្រូវបានបញ្ជូនទៅរស់នៅតំបន់ផ្សេងជាប់មាត់បឹងទន្លេសាប ហើយបានរស់នៅទីនោះអស់រយៈពេលជាច្រើនខែទើបត្រឡប់មកវិញ ជាមួយម្តាយក្មេក ។ នៅពេលប្អូនស្រីត្រឡប់មកភូមិវិញ កាលនោះគាត់កំពុងមានផ្ទៃពោះ តែប្តីរបស់គាត់មិនបានមកជាមួយទេ ព្រោះកាលនោះអង្គការមានបំណងចាប់ខ្លួនប្តីរបស់ប្អូនស្រីខ្ញុំ ព្រោះតែគាត់មានជាប់ពាក់ព័ន្ធសាច់ឈាមជាខ្មែរកម្ពុជាក្រោម ដែលត្រូវបានចាត់ទុកជាវៀតណាម ។ ពេលនោះខ្ញុំឮថា ខ្មែរក្រហមបានចាប់បងប្អូនជីដូនមួយរបស់ប្តីប្អូនខ្ញុំរួចទៅហើយ ហើយបន្ទាប់មកទៀត នឹងចាប់ប្តីប្អូនខ្ញុំហើយ ។ មួយថ្ងៃក្រោយមកទើបខ្ញុំឮដំណឹងថា ប្តីរបស់ប្អូនស្រី និងសាច់ញាតិផ្សេងទៀតត្រូវបានអង្គការចាប់ខ្លួនហើយ ។

ពីរថ្ងៃក្រោយមកនៅពេលព្រលប់ ខណៈពេលដែលប្អូនស្រីខ្ញុំកំពុងតែដងទឹកស្រោចដំណាំនៅខាងក្រោយផ្ទះ ឈ្លបបីនាក់បង់កក្រមាពណ៌ក្រហម បំពាក់ដោយអាវុធគ្រប់ដៃ បានមកដល់មាត់ទ្វារដោយប្រាប់ថា អ្នកដែលនៅក្នុងផ្ទះទាំងអស់ត្រូវរៀបចំឥវ៉ាន់ដើម្បីចាកចេញទាំងយប់ទៅទទួលការលត់ដំ ។ ពាក្យនេះធ្វើឲ្យខ្ញុំស្រឡាំងកាំង ព្រោះគិតថាសេចក្តីស្លាប់បានមកដល់ហើយ ។ គ្រាន់តែឮដូច្នេះ ប្អូនស្រីខ្ញុំឈប់រែកទឹកស្រោចដំណាំ ហើយចូលមកស្រវេស្រវាយកឥវ៉ាន់ ដើម្បីរៀបចំខ្លួនទៅជាមួយឈ្លបទាំងបីនាក់នោះ ។ អ្នកទាំងបី រួមមាន ខ្ញុំ ប្អូនស្រី និងម្តាយក្មេកចេញពីផ្ទះធ្វើដំណើរជាមួយឈ្លបទាំងបីនាក់នោះ រហូតដល់ភូមិមួយទៀតដែលមានឈ្មោះថាភូមិស្បូវ ឬភូមិសន្សា ។ បន្ទាប់មកទៀត ទៅដល់បឹងឈូក និងចុងក្រោយក៏មកដល់ភូមិក្បាលឈើពុក ។

នៅពេលមកដល់ភូមិក្បាលឈើពុក ប្អូនស្រីខ្ញុំ និងម្តាយក្មេកត្រូវកម្មាភិបាលខ្មែរក្រហមដាក់ក្នុងមន្ទីរឃុំឃាំងមួយ ចំណែកឯខ្ញុំត្រូវបានអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញ ។ ខ្ញុំសូមអង្វរកទៅកាន់កងឈ្លបខ្មែរក្រហមឲ្យដោះលែងប្អូនស្រីឲ្យត្រឡប់ទៅភូមិវិញជា



ផ្ទះរបស់ ម៉ុក ស៊ិនហៀង មុនរបបខ្មែរក្រហម ដែលបច្ចុប្បន្នមានម្ចាស់ផ្សេងរស់នៅ

មួយគ្នា តែពួកគេមិនព្រមស្តាប់ ហើយប្រាប់មកកាន់ខ្ញុំវិញថា "ស្ត្រីទាំងពីររូបនេះ (ស៊ិនហុង និងម្តាយក្មេក) ត្រូវតែនៅទីនេះ ដោយសារតែពួកគេជា យួន ឬវៀតណាម" ។ មុននឹងខ្ញុំត្រឡប់មកផ្ទះវិញ ស៊ិនហុង បានហៅខ្ញុំ ឲ្យទៅក្បែរ ហើយប្រគល់របស់មានតម្លៃមួយ ដោយប្រាប់ឲ្យយករបស់នេះទៅជាមួយ ហើយថែរក្សាខ្លួន ដោយសារតែខ្ញុំជាមនុស្សឈឺច្រើន ។

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំអាចបានត្រឹមតែផ្ញើសារ និងរបស់របរហូបចុកខ្លះៗតាមក្មេងប្រុសឃ្វាលគោម្នាក់ដែលរស់នៅក្នុងភូមិស្បា ។ ថ្ងៃមួយ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅភូមិផ្សេងដែលភូមិនោះនៅក្បែរភូមិស្បា ។ នៅទីនោះហើយដែលខ្ញុំ បានជួបជាមួយប្អូនស្រី ដែលត្រូវបានអង្គការបញ្ជាឲ្យទៅធ្វើការក្បែរគ្នាក្នុងនាមជាអ្នកទោស ។ ខ្ញុំសឹងតែមើលប្អូនស្រីមិនស្គាល់ព្រោះតែប្អូនស្រីមានសភាពស្គមស្គាំងខ្លាំងពេក ។ ខ្ញុំបានរត់ឱបប្អូនមួយសន្ទុះ ហើយក៏បែកគ្នាទៅ ។ នេះគឺជាលើកចុងក្រោយដែលខ្ញុំបានជួបមុខប្អូន ។ នាឱកាសមួយទៀត ខ្ញុំត្រូវបានកម្មាភិបាលខ្មែរក្រហមឲ្យធ្វើការនៅភូមិមួយទៀត ហើយឮដំណឹងថាប្អូនស្រីបានធ្វើការនៅក្នុងកងជិតនោះដែរ តែមិនបានជួបមុខគ្នាទេ ។ ប្អូនស្រីខ្ញុំបានយកមែកឈើដែលឆេះសល់មកសរសេរលើក្រដាសស៊ីម៉ងត៍ផ្ញើមកខ្ញុំ ដោយរៀបរាប់ថា គាត់កំពុងមានផ្ទៃពោះពីរខែហើយ គាត់ចង់ហូបអាហារឆ្ងាញ់ម្តង បើសិនជាថ្ងៃណាមួយមាន



ឪពុកម្តាយ និងប្អូនស្រីរបស់ ម៉ុក ស៊ិនហៀង ដែលស្លាប់ក្នុងរបបខ្មែរក្រហម

ឱកាស គាត់នឹងមកនៅជាមួយខ្ញុំនៅក្នុងភូមិវិញ ។ ដំណឹងនេះធ្វើឲ្យខ្ញុំមានកម្លាំងចិត្ត ខ្ញុំខិតខំដាំបន្លែផ្សេងៗ និងដំឡូងនៅជុំវិញផ្ទះដើម្បីរៀបចំទុកចម្អិនសម្រាប់ប្អូនស្រី ។ តែពេលវេលាចេះតែរំកិលទៅមុខ នៅតែមិនឃើញប្អូនស្រីត្រឡប់មកវិញទេ ។

ថ្ងៃមួយ ខ្ញុំបានឮដំណឹងពីអ្នកទោសម្នាក់ដែលបានជាប់ឃុំជាមួយប្អូនស្រីខ្ញុំ រៀបរាប់ថា ដោយសារឃ្លានខ្លាំងពេក ស៊ិនហុង បានលួចដីកទឹកត្នោតរបស់កម្មាភិបាលខ្មែរក្រហម ហើយត្រូវឈ្លបខ្មែរក្រហមសម្លាប់ ដោយអារកនឹងធាងត្នោតនៅចំពោះមុខ អ្នកទោសទាំងអស់ ដើម្បីទុកជាការព្រមាន ។

ចំណែកឯប្អូនស្រីទីបីម្នាក់ទៀតរបស់ខ្ញុំឈ្មោះ ម៉ុក ស៊ិនអ៊ូ ហៅក្រៅ (ស្រីខ្មោះ) ត្រូវបានកម្មាភិបាលខ្មែរក្រហមបង្ខំឲ្យធ្វើការយ៉ាងវេទនានិងធ្វើការរហូតដល់ស្លាប់ ។ ទោះជាឃ្លានយ៉ាងណាក៏ប្អូនស្រីទីបីរូបនេះ មិនហ៊ានហូបបបរដែលកម្មាភិបាលខ្មែរក្រហមចែកឲ្យគាត់ទេ សុខចិត្តទុកឲ្យខ្ញុំហូបជំនួសវិញ ព្រោះតែខ្ញុំមិនមានរាងកាយមាំមួន ។ ដោយសារតែការហូបចុកមិនគ្រប់គ្រាន់ ខ្វះជីវជាតិ ធ្វើឲ្យប្អូនស្រីមានគំនិតរវើរវាយ ឃើញចានទទេ ថាមានម្ហូប ចេះតែស្រមើស្រមៃថាបានញុំាម្ហូបឆ្ងាញ់ ។ ប្អូនស្រីប្រាប់ថា គាត់មានម្ហូបឆ្ងាញ់ៗ ទឹកមុខពោរពេញ ដោយស្នាមញញឹម និងសុភមង្គល តែតាមការពិតគាត់គ្មានអ្វីទាំងអស់ ។

ដោយសារមិនអាចអត់ទ្រាំជាមួយការងារ និងភាពហេវហត់បាន ប្អូនស្រីរូបនោះ ក៏ដួលសន្លប់បាត់ស្មារតីនៅលើទំនប់នៅពេលដែលគាត់កំពុងធ្វើការ ។ ឃើញដូច្នេះ ខ្ញុំក៏បានរត់ទៅបីត្រកងប្អូនស្រី ឃើញភ្នែករបស់ប្អូនស្រីនៅបើកព្រិចៗនៅឡើយ តែមិនបាននិយាយអ្វីទេ ព្រោះតែហេវហត់ខ្លាំង តែខ្ញុំមិនដឹងជាជួយដោយរបៀបណាទេ ។ ខ្ញុំបានលើកប្អូនស្រីមកផ្ទះ យប់នោះប្អូនស្រីដឹងខ្លួនវិញ និយាយខ្សាវៗមកកាន់ខ្ញុំ តែគាត់នៅតែរវើរវាយ ស្រែកថាឃ្លាន ។ ស៊ិនអ៊ូ ហាក់ដូចជាដឹងថាខ្លួនប្រុងនឹងស្លាប់ហើយ នៅពេលយប់ ប្អូនស្រីបានរំពុកអនុស្សាវរីយ៍ទាំងឡាយ ពីចំណីអាហារដែលធ្លាប់ហូប ពីពេលវេលាសប្បាយរស់នៅជាមួយគ្រួសារដែលធ្លាប់មាន និងអ្វីគ្រប់យ៉ាងដែលធ្លាប់មាន កាលពីមុនរបបខ្មែរក្រហម ។ ពេលភ្លឺឡើង ខ្ញុំបានក្រោកមើលប្អូនស្រី ព្យាយាមដាស់គាត់ តែគាត់មិនភ្ញាក់ ក្រោយមកទើបដឹងថាប្អូនស្រីស្លាប់បាត់ទៅហើយ ស្លាប់ពេលដែលគាត់កំពុងតែឱបប្អូនស្រីនៅឡើយ ។

**កេរ្តិ៍ដំណែលពីអតីត និងទស្សនៈយុត្តិធម៌**

ក្នុងចំណោមបងប្អូនបីនាក់ មានតែខ្ញុំទេដែលនៅមានជីវិតក្រោយរបបខ្មែរក្រហម ។ ស៊ិនហុង ត្រូវបានឈ្លបខ្មែរក្រហមសម្លាប់ដោយអារកនឹងធាងត្នោត ចំណែក ស៊ិនអ៊ូ វិញស្លាប់ដោយសារការហូបចុកមិនគ្រប់គ្រាន់ ។ ឪពុករបស់ខ្ញុំ និងកូនៗក្រោយរបស់គាត់ ប្រុសពីរ (ម៉ុក បណ្ឌិត និង ម៉ុក ឬទ្ធិយ៉ា) ស្រីមួយ (ម៉ុក ស៊ិនហេង) បាត់ខ្លួន ។ ការស្លាប់ប្អូនទាំងពីរនាក់ធ្វើឲ្យខ្ញុំ ទទួលរងនូវការឈឺចាប់ផ្លូវចិត្តយ៉ាងខ្លាំងរហូតដល់សព្វថ្ងៃ ។ នៅពេលដែលខ្ញុំនឹកគិតដល់ ស៊ិនហុង ខ្ញុំនៅតែស្តាយថាប្អូន ស្រីទីពីរបានស្លាប់ដោយសារតែបានរៀបការជាមួយកម្មាភិបាលខ្មែរក្រហមដែលមានដើមកំណើតមកពីកម្ពុជាក្រោម ។ ខ្ញុំនៅតែមានវិប្បដិសារីរហូតដល់សព្វថ្ងៃ ដែលមិនបានឃាត់ប្អូនស្រីមិនឲ្យរៀបការ ប្អូនស្រីខំរៀបការជាមួយកម្មាភិបាលខ្មែរក្រហមដែលជាខ្មែរកម្ពុជាក្រោម ព្រោះសង្ឃឹមនឹងបានជួយជីវិតខ្ញុំ ប្អូនស្រីរបស់ខ្ញុំមានសុខភាពល្អ និងមានកម្លាំងមាំមួនណាស់ មិនគួរស្លាប់សោះ ដោយសារតែរៀបការជាមួយនឹងកម្មាភិបាលខ្មែរក្រហមម្នាក់នោះ ។ ខ្ញុំនៅតែមិនអស់ចិត្តអំពីការស្លាប់របស់ប្អូនទាំងពីរ ដោយសារប្អូនស្រីទីបីបានស្លាប់នៅក្នុងរង្វង់ដៃរបស់ខ្ញុំ ។

សព្វថ្ងៃ ខ្ញុំមិនអាចបំភ្លេចអំពីព្រឹត្តិការណ៍នៃការស្លាប់របស់ប្អូនៗរបស់ខ្ញុំបានទេ ។ សព្វថ្ងៃ ខ្ញុំមិនចង់ឃើញដើមត្នោតទេ ព្រោះរាល់ពេលដែលឃើញដើមត្នោត ខ្ញុំតែងតែនឹកឃើញនូវការស្លាប់ របស់ប្អូនស្រីជានិច្ច ។ នៅរាល់ពេលដែល ខ្ញុំនឹកដល់ ស៊ិនអ៊ូ ខ្ញុំសឹងតែមិនជឿថា កូនស្រីម្នាក់របស់វេជ្ជបណ្ឌិតផ្នែកចិត្តសាស្ត្រដែលល្បីមួយរូបក្នុងប្រទេសកម្ពុជា ស្លាប់ដោយសារជំងឺផ្លូវចិត្ត ចេះតែស្រមើស្រមៃ ដោយសារភាពអត់ឃ្លាន ។

ខ្ញុំគ្រាន់តែចង់បានមកវិញនូវភាពយុត្តិធម៌ពីខាងសាលាក្តីខ្មែរក្រហម ជាកិច្ចតបស្នងដល់ប្អូនស្រីទាំងពីររបស់ខ្ញុំ និងជាការព្យាបាលរបួសផ្លូវចិត្តរបស់ខ្ញុំដិតដាមជាប់ខ្ញុំរហូត ។ ខ្ញុំនឹងចងចាំរឿងរ៉ាវដែលបានកើតឡើងលើប្អូនស្រីរបស់ខ្ញុំទាំងពីរ លុះដល់ថ្ងៃខ្ញុំលាចាកលោកនេះ ។

**ម៉ុក ស៊ិនហៀង**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 170, February 2014 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.